ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

# និក្ខេបបទ

# ឥរិយាបថឆ្លើយតប របស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ

ហៃ សុខអេង

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២០

MINISTRY OF EDUCATION, YOUTH AND SPORT

NATIONAL INSTITUTE OF EDUCATION

# THESIS

# TEACHERS' BEHAVIOR TOWARDS THE CURRICULUM IMPLEMENTATION AT SECONDARY SCHOOL IN KAMPONG SPEU PROVINCE

HAI SOKENG

ACCEPTED IN PARTIAL FULFILLMENT OF REQUIREMENT FOR MASTER'S DEGREE OF EDUCATIONAL ADMINISTRATION (MEA), BATCH 7

## MASTER OF EDUCATIONAL ADMINISTRATION (MEA)

2019-2020

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ឥរិយាបថឆ្លើយតប របស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ

ហៃ សុខអេង/ HAI SOKENG

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២០

គ្រូដឹកនាំបង្គោល៖ បណ្ឌិត ឈាង សង្វាត

គ្រូដឹកនាំរង៖ លោក ចាប រតនា

# សេចក្ដីអះអាងរបស់បេក្ខជន

នាងខ្ញុំឈ្មោះ **ហៃ សុខអេង** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ឥរិយាបថឆ្លើយតប របស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**ហៃ សុខអេង**

# លិខិតបញ្ជាក់

**បណ្ឌិត ឈាង សុទ្ធាត** គ្រូដឹកនាំបង្គោល

**លោក ចាប រតនា** គ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

កញ្ញា **ហៃ សុខអេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ឥរិយាបថឆ្លើយតប របស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ**" ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

..................................... .....................................

**បណ្ឌិត ឈាង សុទ្ធាត**
គ្រូឧទ្ទេស
វិទ្យាស្ថានជាតិអប់រំ

**លោក ចាប រតនា**
អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ: ៥៧០៧/៧ អយក.ឧក**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវពីឥរិយាបថឆ្លើយតបរបស់គ្រូបង្រៀនទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ មានគោលបំណងសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

វិធីសាស្ត្រស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ ក្នុងចំនួន៤ មធ្យមសិក្សាបឋមភូមិនៅខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប ៦១នាក់ លោកគ្រូ-អ្នកគ្រូចំនួន៥២នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន៩នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា គ្រូបង្រៀនមានឥរិយាបថក្នុងកម្រិតល្អឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។ ការអនុវត្តដំណើរការបង្រៀនរបស់គ្រូបង្រៀន តាមកម្មវិធីសិក្សាពិតជាមានសារៈសំខាន់ណាស់ នៅមធ្យមសិក្សាបឋមភូមិ សំដៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់រៀននីមួយៗ និងមុខវិជ្ជាវិទ្យាសាស្ត្រពិត ក៏ដូចជាមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ ឥរិយាបថជាវិជ្ជមានក្នុងការអនុវត្តតាមកម្មវិធីសិក្សា ក៏តម្រូវឱ្យគ្រូបង្រៀនផ្តោតការយកចិត្តទុកដាក់ទៅលើដំណើរការសិក្សារបស់សិស្សជាប្រចាំផងដែរ ព្រោះដំណើរការបង្រៀនអាចទទួលបានលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន អាស្រ័យលើការចូលរួមពីដំណើរការសិក្សារបស់សិស្សគ្រប់រូបផងដែរ។ លទ្ធផលនៃការសិក្សាបានបង្ហាញ ពីបញ្ហាប្រឈមមួយចំនួន ទាក់ទងទៅនឹងកង្វះសៀវភៅសិក្សាគោល ការប្រើប្រាស់គ្រូបង្រៀនមិនស្របតាមនិយាម និងសម្ភារឧបទេសពុំទាន់ឆ្លើយតបខ្លឹមសារមេរៀនជាដើម។ បញ្ហាប្រឈមដែលបានលើកឡើង គឺពិតជារាំងស្ទះដល់ដំណើរការបង្រៀនរបស់គ្រូ ប៉ះពាល់ដល់ការអនុវត្តកម្មវិធីសិក្សាពុំទាន់តាមកាលកំណត់ និងប្រសិទ្ធភាពក្នុងការសិក្សារបស់សិស្សផងដែរ។ ការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ ក្នុងការអនុវត្តតាមកម្មវិធីសិក្សាលើដំណើរការបង្រៀនរបស់គ្រូ គឺជាយន្តការដើម្បី

ពង្រឹងការធានាគុណភាព ឆ្លើយតបទៅនឹងកំណែទៅទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងរដ្ឋាភិបាល ក្នុងវិស័យអប់រំ លើសមត្ថភាព ចំណេះដឹង និងជំនាញរបស់សិស្សានុសិស្ស ដែលជាកម្លាំងពលកម្មបម្រើដល់វិស័យសេដ្ឋកិច្ច ក៏ដូចជាសង្គមជាតិផងដែរ។

ជារួមឥរិយាបថឆ្លើយតបជាវិជ្ជមានរបស់គ្រូបង្រៀនទៅលើកម្មវិធីសិក្សា បានបង្ហាញពីកម្រិតល្អប្រសើរនៃការអនុវត្តកម្មវិធីសិក្សាបានចប់តាមកាលកំណត់ ដែលបង្កលទ្ធភាពដល់ការប្រសើរឡើងនៃការសិក្សារបស់សិស្ស ការអនុវត្តបានតាមគន្លងអាជីពគ្រូបង្រៀន ការបន្តអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ និងប្រសិទ្ធភាពខ្ពស់នៃការគ្រប់គ្រង និងដឹកនាំសាលារៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។ គណៈគ្រប់គ្រងសាលារៀន និងភាគីពាក់ព័ន្ធគួរមានយន្តការបំប៉នកញ្ចប់សមត្ថភាពគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំ។

# Abstract

The purpose of this study was to examine the aimed at searching response behavior towards implementing academic curriculum, various challenges and board of education's monitoring and evaluation on teachers' curriculum implementation in Kampong Speu's secondary schools. This study is very important in improving the implementation of the curriculum, teaching and learning process. As well as student learning outcomes that make the quality of education more effective and better in response to the program reform and the vision of the Royal Government. In addition, this research is also important for future researchers who are relevant to the above topic and are relevant to the current educational situation.

The result of the research will also inform educators to continue to strengthen and participate in the implementation of the curriculum for continuous improvement. The current context of education reform and change in students' learning attitudes requires that teachers' behavior toward implementing the curriculum need the same changes to drive improvement of student learning outcomes. A study on the topic of "Teacher's Behavior towards the Curriculum Implementation at Secondary Schools in Kampong Speu Province" may yield results that explore teacher's response behavior and challenges on curriculum implementation as well as quality assurance of education at the lower secondary level in Kampong Speu province.

The research methodology applies the quantitative research method. Data collection was conducted via questionnaires used in 4 secondary schools in Kampong Speu Province with 61 samples, including 52 teachers and 9 boards of director. Data analysis is based on percentage of each variable and percentage of indicator section and 5 demonstration levels which are calculated with specific formula.

According to the result of research, teachers have good level of response behavior of practicing academic curriculum in secondary schools in Kampong Speu Province. The implementation of teachers' teaching process in accordance with academic curriculum is very important for secondary schools to upgrade the result of students' education in each room, including exact science subjects and social science subjects. Positive attitude in implementing academic curriculum requires teachers to focus frequently on students' constant studies as the process of teaching can receive either positive or negative result depending on every student's participation in study process. According to the result of research, some challenges are relevant to shortages of text books, usage of below standard teachers and irrelevance between teaching materials and context. The challenges mentioned above really barricade teachers' teaching process, affect the implementation of academic curriculum such as being later than schedule and students' effectiveness of study. Constant monitoring in teachers' implementation of curriculum

is a mechanism to strengthen education quality in order to respond to the Royal Government and the MoEYS's reform of education sector, including students' knowledge and skills as they are resource labors who will serve the economy and society.

In conclusion, teachers' positive response behavior towards academic curriculum shows good level of implementing academic curriculum in time, which brings the prosperity of students' education, the implementation in accordance with teachers' method, constant development of teachers' professional and high effectiveness of school management and leading in secondary schools in Kampong Speu Province. School Board of Directors and relevant stakeholders should have mechanism to strengthen teachers' capacity to meet the need of full education for all citizens and to guarantee education quality.

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF-Cambodia International Education Support Foundation) ដែលផ្តល់កិច្ចគាំទ្រ និងឱកាសដល់រូបនាងខ្ញុំបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណារ៉ា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ដល់នាងខ្ញុំ ក៏ដូចជាមិត្តភក្តិទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់**លោក ថន ថារិន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ លោកប្រធានការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិ ដែលបានចូលរួមសហការក្នុងការប្រមូលទិន្នន័យតាមកម្រងសំនួរនៅខេត្តកំពង់ស្ពឺ ធ្វើឱ្យការសិក្សាស្រាវ ជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណ ចំពោះ**លោកបណ្ឌិត ឈាង សទ្ធាត** ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត និងចំណេះដឹងល្អៗព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់នាងខ្ញុំទទួលបានជោគជ័យ និង ធានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ នាងខ្ញុំក៏សូមអរគុណដល់**លោក ចាប រតនា** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង និងចែករំលែកបទពិសោធន៍ជាច្រើន ដល់រូបនាងខ្ញុំ រហូតដល់សម្រេចបានជាលទ្ធផលល្អប្រសើរ។

នាងខ្ញុំសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូង ចំពោះក្រុមគ្រួសារ លោកពុក និងអ្នកម្តាយ ពូមីង បងប្អូន ដែលបានផ្តល់ការគាំទ្រជានិច្ច តែងតែលើកទឹកចិត្តរហូតមក និងផ្តល់ឱកាសឱ្យរូបនាងខ្ញុំបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់ តាមក្តីប្រាថ្នា។

សូមអរគុណ!

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ....................................................... i
**លិខិតបញ្ជាក់** ....................................................... ii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ....................................................... iii
**មូលន័យសង្ខេប** ....................................................... iv
Abstract ....................................................... vi
**សេចក្តីថ្លែងអំណរគុណ** ....................................................... iv
**មាតិកា** ....................................................... v
**បញ្ជីតារាង** ....................................................... vii
**បញ្ជីរូបភាព** ....................................................... ix
**បញ្ជីពាក្យកាត់** ....................................................... x
**ជំពូកទី១ សេចក្តីផ្តើម** ....................................................... 1
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................... 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ....................................................... 5
១.៣ គោលបំណងនៃការស្រាវជ្រាវ ....................................................... 7
១.៤ សំណួរស្រាវជ្រាវ ....................................................... 7
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ....................................................... 8
១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ....................................................... 8
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................................................... 9
**ជំពូកទី២ រំលឹកទ្រឹស្តី** ....................................................... 11
២.១ ព័ត៌មានទូទៅពីខេត្តកំពង់ស្ពឺ ....................................................... 11
២.២ និយមន័យ ....................................................... 12
២.៣ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា ....................................................... 12
២.៤ ទ្រឹស្តីពីការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ ....................................................... 13
២.៤.១ ការអនុវត្តកម្មវិធីសិក្សា ....................................................... 13
២.៤.២ កម្មវិធីសិក្សា៖ ការអប់រំពលរដ្ឋពេញលេញនៅមធ្យមសិក្សាបឋមភូមិ ....................................................... 15

២.៥ ទ្រឹស្តីពីបញ្ហាប្រឈម ការអនុវត្តកម្មវិធីសិក្សា ...... 18

២.៦ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ ...... 19

២.៧ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ...... 21

២.៨ គោលនយោបាយស្តីពីគ្រូបង្រៀន ...... 23

២.៩ ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ការបង្រៀន ...... 25

២.១០ ការរៀបចំនូវកិច្ចតែងការបង្រៀន ...... 26

២.១១ ប្រសិទ្ធភាពនៃការប្រើប្រាស់ពេលបង្រៀន ...... 28

២.១១.១ ការអនុវត្តម៉ោងបង្រៀន ...... 29

២.១១.២ ផលប៉ះពាល់នៃការអវត្តមានរបស់គ្រូ ...... 30

២.១១.៣ ការកំណត់និយាម ...... 30

២.១២ ក្របខណ្ឌវាយតម្លៃរបស់គណៈគ្រប់គ្រង់សាលារៀន ...... 31

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ...... 32

៣.១ គម្រោងវិភាគ ...... 32

៣.២ ការប្រមូលទិន្នន័យ ...... 32

៣.៣ ឧបករណ៍ស្រាវជ្រាវ ...... 33

៣.៣.១ កម្រិតចង្អុលបង្ហាញ ...... 34

៣.៣.២ កម្រងសំណួរ ...... 35

៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាបឋមភូមិ ...... 35

៣.៣.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន ...... 36

៣.៤ ការជ្រើសរើសភាគសំណាក ...... 37

៣.៥ ការវិភាគទិន្នន័យ ...... 38

**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** ...... 39

៤.១ ទិន្នន័យពីព័ត៌មានទូទៅរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង ...... 39

៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន ...... 39

៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង ...... 40

៤.២ ទិន្នន័យពីការឆ្លើយតបរបស់គ្រូ លើឥរិយាបថឆ្លើយតប ក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ...... 40

៤.២.១ ទិន្នន័យឆ្លើយតបរបស់គ្រូលើ ឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សា ...... 40

៤.២.២ ទិន្នន័យឆ្លើយតបរបស់គណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបការអនុវត្តកម្មវិធីសិក្សារបស់គ្រូ ............ 44

៤.៣ លទ្ធផលសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ........................................................................................................ 46

៤.៤ ទិន្នន័យឆ្លើយតបរបស់គ្រូទៅលើបញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សា ...............................................51

៤.៥ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការចុះពិនិត្យតាមដាន និងវាយតម្លៃពី ............................................... 57

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ...................................................................................... 62

**ឯកសារយោង** ........................................................................................................................ 66

**ឧបសម្ព័ន្ធ**............................................................................................................................. 70

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាមធ្យមសិក្សាបឋមភូមិនៅឆ្នាំ២០១៨ | 17 |
| ២.២ | សូចនាករបុគ្គលិកបង្រៀនតាមកម្រិតសិក្សា និងតាមកម្រិតសាលា | 22 |
| ២.៣ | ស្ថានភាពបុគ្គលិកបង្រៀនតាមមុខវិជ្ជានៅមធ្យមសិក្សានៅឆ្នាំ២០១៨ | 24 |
| ២.៤ | ភាគរយនៃការទទួលខុសត្រូវលើការរៀបចំប្លង់មេរៀន | 27 |
| ២.៥ | កត្តាដែលបណ្តាលឱ្យបាត់បង់ម៉ោងបង្រៀន និងរៀនមិនចប់កម្មវិធី | 29 |
| ៣.១ | ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រសំណួរ | 38 |
| ៤.១ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សា | 40 |
| ៤.២ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការអនុវត្តកម្មវិធីសិក្សា | 42 |
| ៤.៣ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនទៅលើដំណើរការសិក្សារបស់សិស្ស | 43 |
| ៤.៤ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ | 44 |
| ៤.៥ | ទិន្នន័យឆ្លើយតបរបស់គណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបរបស់គ្រូក្នុងការអនុវត្តកម្មវិធីសិក្សា | 44 |
| ៤.៦ | ទិន្នន័យសរុបលើការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាទៅលើឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សា | 46 |
| ៤.៧ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើបញ្ហាប្រឈមទៅលើការអនុវត្តកម្មវិធីសិក្សា | 52 |
| ៤.៨ | ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រង ទៅលើការអនុវត្តកម្មវិធីសិក្សា | 57 |

# បញ្ជីរូបភាព


| រូបភាព | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | ភាគរយនៃហេតុផលលោកគ្រូ-អ្នកគ្រូមិនបានរៀបចំប្លង់មេរៀន | 28 |
| ២.២ | ការប្រៀបធៀបម៉ោងបង្រៀនកម្ពុជា និងម៉ោងបង្រៀនអន្តរជាតិ | 30 |

# បញ្ជីពាក្យកាត់

- GDP : Gross Domestic Product
- MoEYS : Ministry of Education, Youth and Sport
- NEP : NOG Education Partnership
- PLC : Professional Learning Community
- UNESCO : United Nations Education, Scientific and Culture Organization
- UNICEF : United Nations Children´s Fun

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំ គឺជាគន្លឹះដ៏សំខាន់ក្នុងការកសាងនូវរាល់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងមានគុណភាពពិតប្រាកដដែលក្នុងនោះ រួមមានការកសាងធនធានបញ្ញាដែលពោរពេញដោយចំណេះដឹង ចំណេះធ្វើ និងឥរិយាបថល្អក្នុងសង្គម (គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា, ២០១១)។ "ការអប់រំល្អគឺជាកូនសោរសម្រាប់ដោះស្រាយនូវរាល់បញ្ហាសង្គមសេដ្ឋកិច្ច" ដើម្បីចូលរួមចំណែកទ្រទ្រង់ និងបង្កើននូវកំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាក្នុងគ្រួសារឱ្យមានលក្ខណៈល្អប្រសើរ ក្នុងការប្រកួតប្រជែងទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងដើម្បីឆ្លើយតបទៅនឹងនិន្នាការភាពក្នុងការកសាងធនធានមនុស្ស ចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យទៅលើផ្នែកពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំទាំងមូលដែលមានដូចជា សមត្ថភាពគ្រូបង្រៀនប្រកបដោយគុណភាព ការបង្រៀនសមស្របទៅនឹងកម្មវិធីសិក្សា លទ្ធផលសិក្សារបស់សិស្ស ការត្រួតពិនិត្យ និងវង្វាយតម្លៃលើកិច្ចការបង្រៀន និងការគោរពតាមក្របខ័ណ្ឌគតិយុត្តិផ្សេងៗ សំដៅសម្រេចឱ្យបាននូវគោលនយោបាយអប់រំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ការអប់រំ រឹតតែមានសារៈសំខាន់ថែមទៀតសម្រាប់ការស្តារ និងការកសាងប្រទេសឡើងវិញក្រោយការដួលរលំនៃរបបខ្មែរក្រហម ក្នុងចំណោមគ្រូបង្រៀនចំនួន២២.០០០នាក់ ទូទាំងប្រទេសក្នុងឆ្នាំ១៩៦៨ គ្រូបង្រៀនដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហមសល់តែ ៧.០០០នាក់ប៉ុណ្ណោះ ក្នុងឆ្នាំ១៩៧៩ ហើយក្នុងចំណោមនេះ មានគ្រូបង្រៀនតែ ៥.០០០ នាក់ប៉ុណ្ណោះដែលត្រឡប់មកបង្រៀនវិញ និងសល់តែបញ្ញវន្តចំនួន ៣០០ នាក់ប៉ុណ្ណោះ ដែលនៅមានជីវិតក្រោយថ្ងៃរំដោះ ០៧ កមរា ឆ្នាំ ១៩៧៩ គឺជាទិវាវសាននៃរបបប៉ុលពត (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៨០)។ ថ្វីបើមានកង្វះខាតធនធានមនុស្សក្នុងវិស័យអប់រំខ្លាំង ប៉ុណ្ណាក៏របបដឹកនាំប្រទេសថ្មីប្រឹងរូតរះក្នុងការកសាងសមត្ថភាពអប់រំនៅគ្រប់ភូមិសិក្សា (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងការអប់រំសម្រាប់មនុស្សពេញវ័យ) ដើម្បីឱ្យកុមារ និងមនុស្សពេញវ័យទទួលបានការអប់រំដូចគ្នា។ ចាប់តាំងពី

ឆ្នាំ១៩៩៣ មកការអប់រំទទួលរងឥទ្ធិពលពីសាកលភាវូបនីយកម្ម និងតំបន់ភាវូបនីយកម្មក្នុងការផលិតធនធានមនុស្ស សម្រាប់បម្រើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ ដើម្បីសម្រេចបាននូវកិច្ចការនេះ ក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យ "បង្កើត និងអភិវឌ្ឍធនធានមនុស្សដែលមានគុណភាព និងសីលធម៌ខ្ពស់បំផុត ដើម្បីអភិវឌ្ឍកម្ពុជាជាសង្គមពុទ្ធិមួយឱ្យបាន"(ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០១៤)។ចក្ខុវិស័យសង្គមពុទ្ធិនេះ គឺជាសង្គមដែលមានការអភិវឌ្ឍលឿន និងប្រកបដោយចីរភាពដែលនៅក្នុងនោះ មនុស្សរស់នៅមានចំណេះដឹងពេញលេញផ្នែកបច្ចេកវិទ្យា ការយល់ដឹងស៊ីជម្រៅអំពីវប្បធម៌ និងបទដ្ឋានរស់នៅសមស្របប្រកបដោយសុភមង្គល សន្តិភាព និងសេចក្ដីថ្លៃថ្នូរ។ សង្គមថ្មីក្រោមចក្ខុវិស័យដ៏វែងឆ្ងាយនេះ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី០៣ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ ដែលមានគោលបំណងអភិវឌ្ឍន៍កម្ពុជាពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០។ ក្នុងនោះដែរប្រព័ន្ធអប់រំ ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបានចក្ខុវិស័យនេះ តាមរយៈការផលិតឱ្យបាននូវធនធានមនុស្សដែលមានជំនាញ ដើម្បីបម្រើពុទ្ធិ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួនណារ៉ុន ដែលឯកឧត្តមបានធ្វើជារដ្ឋមន្ត្រីអប់រំ ចាប់តាំងពីឆ្នាំ២០១៣ រៀងមកវិស័យអប់រំនៅកម្ពុជាបានផ្លាស់ប្ដូរទៅជាមានប្រព័ន្ធការងារត្រឹមត្រូវជាងមុនយ៉ាងច្រើន។ កំណែទម្រង់អប់រំអាទិភាពចំនួនប្រាំបី រួមមាន៖ (១) ការកែលម្អគុណភាពបង្រៀន និងរៀន (២) ការបង្កើនមុខងារសាធារណៈ និងបៀវត្សរ៍គ្រូបង្រៀន និងការដាក់បញ្ចូលការតែងតាំងដោយផ្អែកលើឧបនិស្ស័យ (៣) ការផ្ដល់ធនធានបន្ថែមទៅអ្នកផ្ដល់សេវានៅជួរមុខ (៤) កំណែទម្រង់ប្រព័ន្ធប្រឡង (៥) ការបង្កើនធនាគារបញ្ញវន្តគោលនយោបាយអប់រំ (៦) កំណែទម្រង់កម្មវិធីយុវជន និងបំណិនមុខរបរ (៧) ការអនុវត្តកំណែទម្រង់ការអប់រំនៅឧត្តមសិក្សា និងប្រឹក្សាការងារដល់សិស្សនិស្សិត និង (៨)កំណែទម្រង់វិស័យកីឡា ដើម្បីត្រៀមរៀបចំកម្ពុជាធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០៣០ ខាងមុខនេះ។ អាទិភាពកំណែទម្រង់ទាំងប្រាំបីនេះ មានគោលបំណង ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពសេវាសាធារណៈដែលក្រសួងអប់រំ យុវជន និងកីឡាផ្ដល់ជូន។ អាទិភាពកំណែទម្រង់នេះមានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤ - ២០១៨ ដែលមានចែងអំពី

កម្មវត្ថុគោលនយោបាយអប់រំសំខាន់ៗ ចំនួនបី ៖ "ធានាការទទួលបានការអប់រំសម្រាប់ទាំងអស់គ្នាដោយស្មើភាព ការពង្រឹងគុណភាព និងប្រសិទ្ធភាពការសិក្សា និងការធានាភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងបុគ្គលិកអប់រំគ្រប់ភូមិសិក្សាឱ្យមានភាពស័ក្តិសិទ្ធិខ្ពស់"។ ជាលទ្ធផល រាជរដ្ឋាភិបាល និងក្រសួងអប់រំបានបង្កើនការប្តេជ្ញាចិត្តក្នុងការពង្រីកការអប់រំនៅគ្រប់ភូមិសិក្សា ជាពិសេសនៅកម្រិតមូលដ្ឋាន និងក្នុងការកែលម្អគុណភាព និងប្រសិទ្ធភាពអប់រំ ជាលទ្ធផលនៃការពង្រីកវិស័យអប់រំនេះ បានបង្កើនចំនួនថ្នាក់រៀនសាលារៀន និងតម្រូវការគ្រូបង្រៀនដែលមានសមត្ថភាពកាន់តែខ្លាំងថែមទៀត ដើម្បីកែលម្អគុណភាពអប់រំ និងកម្មវិធីសិក្សាថ្មី ក្រសួងបានអនុវត្តវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល។ នាពេលបច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលលើចក្ខុវិស័យកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនលើផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ឆ្លើយតបនឹងចក្ខុវិស័យពីរចំណុចគឺ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញជីវិត និងធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០១៩)។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបាន គឺត្រូវពឹងផ្អែកទៅលើសសរស្តម្ភទាំង៥រួមមាន ការអនុវត្តផែនការសកម្មភាព គោលនយោបាយគ្រូបង្រៀន ការពិនិត្យឡើងវិញ កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថាន ការដាក់ឱ្យអនុវត្តអធិការកិច្ច ការពង្រឹងវង្វាយតម្លៃសិក្សាដូចជា ការប្រឡងវង្វាយតម្លៃថ្នាក់ជាតិ តំបន់និងអន្តរជាតិ និងការកែទម្រង់ឧត្តមសិក្សា។ ហើយសមត្ថភាពរបស់គ្រូបង្រៀនមានសារៈសំខានណាស់ ក្នុងការលើកកម្ពស់គុណភាពសិក្សា និងលទ្ធផលសិក្សារបស់សិស្ស ទើបបានជាក្រសួងបានដាក់ចេញ ឱ្យគ្រឹះស្ថានសិក្សាគ្រប់លំដាប់ថ្នាក់អនុវត្តគោលការណ៍អធិការកិច្ច (ផ្ទៃក្នុង) ដើម្បីជាការធ្វើស្វ័យវាយតម្លៃ ផ្លាស់ប្តូរនូវវិធីសាស្ត្របង្រៀន បច្ចេកទេសផ្ទេរចំណេះដឹងដល់សិស្ស និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនក្នុងអង្គភាពផងដែរ ជាពិសេសដើម្បីឱ្យធាតុចេញដែលផលិតបានមកប្រកបដោយគុណភាព (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០១៤)។ កិច្ចការនេះត្រូវផ្តោតទៅលើការងារទាក់ទងនឹងគុណភាពអប់រំផ្ទៃក្នុងកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានផ្ទៃក្នុង ឬធនធានមូលដ្ឋាន។ ការធ្វើអធិការកិច្ចផ្ទៃ

ក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំដោយមានការកែតម្រូវផ្សេងៗទៅលើការងារគ្រប់គ្រង កិច្ចការបង្រៀន ការរៀបចំឯកសាររដ្ឋបាលសម្រាប់ការបង្រៀនជាដើម ក្នុងអំឡុងពេលនៃការសិក្សា (បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងការអប់រំចំណេះទូទៅនៅកម្ពុជា, ២០១៥)។

ក្រោមការដឹកនាំថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ការកែលម្អសំខាន់ៗជាច្រើនបានកើតមានឡើង ប៉ុន្តែប្រព័ន្ធអប់រំរបស់កម្ពុជា នៅតែមានវិបត្តិនៅឡើយជាពិសេសបញ្ហាគុណភាពអប់រំ។ យោងតាមវង្វាយតម្លៃជាតិថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៨ ធ្វើឡើងដោយនាយកដ្ឋានធានាគុណភាពអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា រកឃើញថាសិស្សរៀនខ្សោយក្នុងមុខវិជ្ជាភាសា គណិតវិទ្យា និងវិទ្យាសាស្ត្រ។ វង្វាយតម្លៃនោះបង្ហាញថា មានសិស្សក្រោម៤០ភាគរយ អាចប្រឡងយកពិន្ទុជាប់ក្នុងមុខវិជ្ជាទាំងនេះ។ នេះក៏បានបង្ហាញថា គុណភាពអប់រំកើតមានអាស្រ័យលើការមានគ្រូគ្រប់គ្រាន់ និងពោរពេញដោយសមត្ថភាពនៅតាមសាលារៀន។ ការរៀបចំគ្រូបង្រៀនឱ្យមានគ្រប់គ្រាន់ និងពោរពេញដោយសមត្ថភាពនៅតាមសាលារៀននឹងនាំឱ្យសម្រេចបាននូវគុណភាពអប់រំស្របតាម គោលដៅទី៤នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ កម្ពុជាមានការរីកចម្រើនល្អក្នុងការសម្រេចបានទាំងបរិមាណ និងគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលគរុកោសល្យ ទោះបីមានការទទួលស្គាល់ពីសារៈសំខាន់នៃការដំឡើងថ្នាក់គុណវុឌ្ឍិគ្រូបង្រៀនយ៉ាងណាក៏ដោយក៏គ្រូបង្រៀននៅកម្ពុជាទទួលបានវគ្គអភិវឌ្ឍវិជ្ជាជីវៈគ្រូបន្តតិចតួចនៅឡើយ។ យ៉ាងណាក៏ដោយ វិធីសាស្ត្រទាំងនេះ នៅមិនទាន់មានភាពស័ក្តិសិទ្ធិនៅឡើយ ដោយសារតែមិនបានធ្វើឱ្យមានការផ្លាស់ប្តូរទម្លាប់អនុវត្តនៅក្នុងថ្នាក់រៀន ព្រមទាំងការបង្រៀន និងរៀនផងដែរ។ ដោយកម្មវិធីនៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូបច្ចុប្បន្ន នៅមិនទាន់បានផ្តល់កម្មវិធីអភិវឌ្ឍន៍ត្រឹមត្រូវ ឬបានជួយគ្រូបង្រៀនឱ្យចេះអនុវត្តកម្មវិធីសិក្សាថ្មីបានល្អនៅឡើយទេ នៅតែធ្វើតាមរបៀបចាស់ មានលក្ខណៈជាសិក្ខាសាលា ហើយនៅតែមិនបានផ្លាស់ប្តូរអាកប្បកិរិយាគ្រូ ឬលទ្ធផលសិក្សារបស់សិស្សទេ (Hang Chuon, 2017)។ ដោយហេតុនេះ គ្រូបង្រៀនជាពិសេស គ្រូដែលធ្លាប់បានទទួលការបណ្តុះបណ្តាលក្នុងប្រព័ន្ធពីមុន នៅមិនទាន់ស្ទាត់ជំនាញក្នុងមុខវិជ្ជាដែលខ្លួនបង្រៀន និងនៅខ្វះបំណិនគរុកោសល្យក្នុងការបង្រៀនសិស្សនៅឡើយ ជាពិសេសសម្រាប់គ្រូនៅក្នុងតំបន់ដែលមិនមានលក្ខខណ្ឌល្អ។ ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូសំដៅលើភាពនានានៃ

បទពិសោធន៍អប់រំ ពាក់ព័ន្ធនឹងកិច្ចការរបស់បុគ្គលណាម្នាក់ ហើយដែលគ្រូបានរៀបចំឡើងដើម្បីកែលម្អកិច្ចប្រតិបត្តិ និងលទ្ធផលសិក្សារបស់សិស្ស (Parker & Tannehill, 2015)។ ដើម្បីសម្រេចបានគោលបំណងនេះ កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូ ត្រូវតែផ្លាស់ប្តូរទម្លាប់បង្រៀនរបស់គ្រូ និងទម្លាប់រៀនសូត្រក្នុងសាលា។ បន្ថែមលើនេះក៏ត្រូវតែមានការអនុវត្តគោលការណ៍អធិការកិច្ចផ្ទៃក្នុងនៅតាមសាលារៀនដែលពុំទាន់អនុវត្តបានល្អប្រសើរនៅឡើយទេ ជាកត្តាមួយជះឥទ្ធិពលដល់ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស ព្រមទាំងឈានទៅដល់លទ្ធផលសិក្សាផងដែរ ជាពិសេសនៅថ្នាក់មធ្យមសិក្សាបឋមភូមិ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

តម្រូវការចាំបាច់នៃការអភិវឌ្ឍន៍ប្រទេស គឺការកសាងធនធានមនុស្សប្រកបដោយគុណសម្បត្តិគ្រប់ផ្នែកដែលត្រូវផ្តើមចេញពីវិស័យអប់រំជាគោល។ ប៉ុន្តែស្ថានភាពអប់រំនៅកម្ពុជានៅមានកម្រិត បើផ្តោតទៅលើគុណភាព និងប្រសិទ្ធភាព ហើយភារកិច្ចមួយផ្នែកធំនៃការកសាងធនធានមនុស្សជាកាតព្វកិច្ចមួយដែលធ្លាក់ទៅលើគ្រូបង្រៀន។ ពិតណាស់បញ្ហាប្រឈមរបស់វិស័យអប់រំដែលត្រូវបន្តដោះស្រាយបន្ទាន់នោះគឺ គុណភាពអប់រំដោយជានាឱ្យមាន គុល្យភាពរវាងការពង្រឹងគុណភាពអប់រំ និងការពង្រីកបរិមាណអប់រំ។ ជាក់ស្តែងតាមរយៈការស្រាវជ្រាវរបស់ World Bank(2008) បញ្ជាក់ឱ្យឃើញថា ការអនុវត្តកម្មវិធីសិក្សាក្នុងវិស័យអប់រំ ក្នុងប្រទេសកម្ពុជានៅមានបញ្ហានៅឡើង ព្រោះបញ្ហានេះកើតឡើងដោយសារគ្រូមិនបានយកចិត្តទុកដាក់បង្រៀន និងផ្តល់ចំណេះដឹងទៅឱ្យសិស្សដោយមិនបានគិតពីប្រសិទ្ធភាព និងគុណភាពអប់រំ។ ជាទូទៅយើងសង្កេតឃើញថា សាលារៀនជាច្រើនមានបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា ព្រមទាំងការបង្រៀនមិនស្របតាមបំណែងចែកកម្មវិធីសិក្សានៅក្នុងសាលា ដែលជះឥទ្ធិពលមិនល្អដល់ការសិក្សារបស់សិស្ស និងគុណភាពអប់រំ។ ការគ្រប់គ្រងធូរលុងក្នុងការពិនិត្យតាមដានលើការបង្រៀន និងរៀន ការប្រើប្រាស់វិធីសាស្ត្របង្រៀនមិនបានសមស្រប និងមិនស៊ីសង្វាក់គ្នាពីមេរៀនមួយទៅមេរៀនមួយទៀត ការធ្វើអធិការកិច្ចផ្ទៃគ្រូបង្រៀនមិនបានទៀងទាត់ ការបណ្តុះបណ្តាលកម្មវិធីសិក្សាលើក្របខណ្ឌបច្ចេកទេសតាមមុខវិជ្ជា ការអនុវត្តនិយាមម៉ោងកំណត់ក៏ប៉ះពាល់អវិជ្ជមានដល់ការអនុវត្តកម្មវិធីសិក្សា ធនធានសម្ភារៈប្រើប្រាស់ពុំទាន់មានភាពសម្បូរបែបក្នុង ការផ្ទេរចំណេះដឹងដល់សិស្ស សមត្ថភាព

វិជ្ជាជីវៈរបស់គ្រូនៅមានកម្រិត បានធ្វើឱ្យមានគម្លាតរវាងគោលដៅចង់បានគុណភាពអប់រំខ្ពស់។

ការផ្លាស់ប្តូរឥរិយាបថសិក្សារបស់សិស្ស គឺជាបញ្ហាដែលកំពុងប្រឈមក្នុងបរិបទនៃសាកលភាវូបនីយកម្មការអប់រំនាពេលបច្ចុប្បន្ន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាចាំបាច់បំផុតដើម្បីជំរុញឱ្យមានភាពប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្ស។ គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ទេរចំណេះដឹង ជំនាញ និងអប់រំឥរិយាបថសិស្ស ដោយស្របទៅតាមកម្មវិធីសិក្សានៃកូមិសិក្សានីមួយៗ ដែលបានកំណត់ច្បាស់លាស់រវាងមុខវិជ្ជាវិទ្យាសាស្ត្រពិត និងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ គោលនយោបាយស្តីពីគ្រូបង្រៀនបាននឹងកំពុងទាក់ទាញបុគ្គលដែលមានសមត្ថភាពឲ្យចាប់យកវិជ្ជាជីវៈជាគ្រូបង្រៀន ដើម្បីប្រែក្លាយគុណភាពនៃការអប់រំគ្រូ កាន់តែមានប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈ ក៏ដូចជាការបង្រៀនសិស្សានុសិស្ស។ គ្រូបង្រៀនជាបុគ្គលគន្លឹះ ក្នុងការរក្សានូវគុណតម្លៃថ្នាក់រៀនដែលមានគុណភាពពិតប្រាកដ និងសំដៅដល់ការដំណើរការបង្រៀនមានប្រសិទ្ធផល។ ក្នុងគោលនយោបាយអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) បានកែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅគ្រប់កម្រិតទាំងអស់មានការរឹតបន្តឹងជាងមុន ក្នុងពេលធ្វើកម្មសិក្សា បង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសនៅតាមមជ្ឈមណ្ឌលគរុកោសល្យ លើកកម្ពស់វប្បធម៌នៃការរៀនសូត្រពេញមួយជីវិត បង្កើនគុណវុឌ្ឍិគ្រូតាមរយៈកម្មវិធីពន្លឿនការអប់រំបរិញ្ញាបត្រ(BA-Fast Track Program) កែលំអលក្ខខណ្ឌការងារ និងលើកកម្ពស់ជីវភាពរស់នៅរបស់គ្រូបង្រៀនជាដើម។ លើសពីនេះទៅទៀតនោះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែសម្រួលកម្មវិធីសិក្សានៅគ្រប់កម្រិតទាំងអស់លើកម្មវិធីអប់រំ កម្មវិធីសិក្សា និងបរិយាកាសក្នុងសាលារៀន ដោយពិនិត្យឡើងវិញលើកម្មវិធីសិក្សានៅគ្រប់កម្រិតទាំងអស់ កែសម្រួលសៀវភៅសិក្សា និងរៀបចំសៀវភៅណែនាំសម្រាប់គ្រូថ្មីៗ (មុខវិជ្ជាជាអាទិភាព៖ គណិតវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរ) ជាដើម។ ដើម្បីឆ្លើយតប កំណែទម្រង់របស់ក្រសួងទទួលបន្ទុកអប់រំ ក៏ដូចជាកំណែទម្រង់របស់រាជរដ្ឋាភិបាល ទទួលបានភាពវិជ្ជមានក្នុងក្របខណ្ឌអប់រំពលរដ្ឋពេញលេញឥរិយាបថរបស់គ្រូបង្រៀន ទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាចំណេះទូទៅ គឺជាកត្តាអាទិភាព ក្នុងការធានាបាននូវភាពស័ក្តិសិទ្ធនៃកិច្ចការធានាគុណភាពអប់រំនៅព្រះរាជាណាចក្រកម្ពុជា។ ដោយមើលឃើញពីភាពចាំបាច់ និងឥទ្ធិពលនៃឥរិយាបថរបស់គ្រូបង្រៀនទៅ

លើការអនុវត្តកម្មវិធីសិក្សាក្នុងក្របខណ្ឌការអប់រំនៅកម្រិតមធ្យមសិក្សាចំណោះទូទៅ ការសិក្សាស្រាវជ្រាវលើប្រធានបទ "ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ" គឺបានចូលរួមចំណែកក្នុងការបង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រសិទ្ធផលនៃឥរិយាបថអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ក៏ដូចជាបញ្ហាប្រឈមនានា ដែលអាចជាចំណុចរាំស្ទះដល់កំណែទម្រង់វិស័យអប់រំ និងគុណភាពនៃការប្រតិបត្តិការរៀននិងបង្រៀនក្នុងភូមិសិក្សារបស់ខេត្តកំពង់ស្ពឺ សំដៅធានាបានគុណភាពនៃការអប់រំសិស្សានុសិស្ស ក៏ដូចជាគុណភាពនៃការអភិវឌ្ឍកញ្ចប់សមត្ថភាពរបស់គ្រូបង្រៀនផងដែរ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានគោលបំណងដើម្បី ៖

១. សិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សា បឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

២. រកឱ្យឃើញនូវបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។

៣. ឆ្លុះបញ្ចាំងពីការចុះពិនិត្យតាមដាននិងវាយតម្លៃពីគណៈគ្រប់គ្រងសាលារៀនទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិរបស់លោកគ្រូ-អ្នកគ្រូក្នុងខេត្តកំពង់ស្ពឺ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើសំណួរស្រាវជ្រាវចំនួន០៣ ត្រូវបានលើកឡើង៖

១. តើលោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ មានឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សាយ៉ាងដូចម្តេចខ្លះ?

២. តើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិរបស់លោកគ្រូ-អ្នកគ្រូក្នុងខេត្តកំពង់ស្ពឺ បានជួបបញ្ហាប្រឈមយ៉ាងដូចម្តេចខ្លះ?

៣. តើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិរបស់លោកគ្រូ-អ្នកគ្រូក្នុងខេត្តកំពង់ស្ពឺ

បានទទួលការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងសាលារៀនយ៉ាងដូចម្ដេចខ្លះ ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ដោយយកចិត្តទុកដាក់ខ្ពស់ និងការប្រើប្រាស់នូវវិធីសាស្ត្រសមស្រប លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងក្លាយទៅជាព័ត៌មានដ៏មានសារៈសំខាន់មួយ សម្រាប់អ្នករៀបចំគោលនយោបាយអប់រំ និងអ្នកពាក់ព័ន្ធនានាក្នុងវិស័យអប់រំ ជាពិសេសគណៈគ្រប់គ្រងសាលា គ្រូបង្រៀន ដឹងពីសារៈសំខាន់នៃឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សា និងបង្ហាញពីបញ្ហាប្រឈមនានាដែលកើតមានចំពោះគ្រូបង្រៀនក្នុងការអនុវត្តកម្មវិធីសិក្សា គឺជាសញ្ញាណក្នុងការធ្វើឱ្យមានការផ្លាស់ប្ដូរ និងត្រូវបំពេញបន្ថែមដែលអាចធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា។ ក្នុងនោះដែរការចុះពិនិត្យតាមដាន និងវាយតម្លៃក៏បានចូលរួមចំណែកក្នុងការឆ្លុះបញ្ចាំងនូវការធានាគុណភាពអប់រំនៅក្នុងសាលារៀននាពេលបច្ចុប្បន្ននេះ។ លោកគ្រូ អ្នកគ្រូអាចយកលំនាំតាមការសិក្សានេះទៅកែលម្អឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សា ក៏ដូចជាការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួននៅក្នុងថ្នាក់រៀនរបស់លោកគ្រូ អ្នកគ្រូផ្ទាល់ ព្រមទាំងទទួលបានបទពិសោធន៍ល្អៗសម្រាប់បង្រៀន និងឥរិយាបថក្នុងការផ្ទេរចំណេះដឹងឱ្យទៅសិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ដែលស្របតាមកំណែទម្រង់វិស័យអប់រំ និងការអភិវឌ្ឍកម្មវិធីសិក្សារបស់កម្ពុជានាពេលបច្ចុប្បន្ន។

ឆ្លើយតបទៅនឹងកម្មវត្ថុដែលបានកំណត់ខាងលើ អ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា ការសិក្សាមួយនេះនឹងអាចរួមចំណែកលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សាធ្វើឱ្យគុណភាពអប់រំមានប្រសិទ្ធភាពឱ្យកាន់តែមានភាពល្អប្រសើរឡើង។ លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ផងដែរ សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តបន្ទាប់ទៅមុខទៀត ដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ ហើយមានការស៊ីសង្វាក់ទៅនឹងស្ថានភាពអប់រំបច្ចុប្បន្ន។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសតែក្រុង ស្រុកចំនួន២ ក្នុងចំណោមក្រុង ១ ស្រុក៧ ត្រូវបានជ្រើសរើសចេញពីខេត្តកំពង់ស្ពឺដែលរួមមាន ១) ក្រុងច្បារមន ២) ស្រុកភ្នំស្រួច និង

កំណត់យកមធ្យមសិក្សាបឋមភូមិចំនួន៤ ក្នុងចំណោម៩៤ មធ្យមសិក្សាបឋមភូមិ។ ផ្អែកលើលក្ខណៈភូមិសាស្ត្រខុសៗគ្នាគឺ មធ្យមសិក្សាបឋមភូមិ ដែលស្ថិតនៅក្នុងក្រុងច្បារមននៅតំបន់ធម្មតា និងមធ្យមសិក្សាបឋមភូមិដែលស្ថិតក្នុងស្រុកភ្នំស្រួចដែលនៅតំបន់លំបាក ដើម្បីធ្វើការសិក្សា។ អ្នកស្រាវជ្រាវបានកំណត់យកតែអ្នកពាក់ព័ន្ធចំនួន ៦១នាក់ដែលក្នុងនោះរួមមាន គណៈគ្រប់គ្រងសាលាចំនួន ៩នាក់ និងលោកគ្រូអ្នកគ្រូចំនួន ៥២នាក់ដែលកំពុងបង្រៀន នៅក្នុងមធ្យមសិក្សាបឋមភូមិដែលបានកំណត់។ ហើយការសិក្សាស្រាវជ្រាវនេះក៏នឹងផ្តោតតែ ឥរិយាបថរបស់គ្រូបង្រៀនទៅលើការអនុវត្តកម្មវិធីសិក្សា រីឯលទ្ធផលដែលទទួលបានអំពីការសិក្សាស្រាវជ្រាវនេះ ក៏មានតែចំពោះឥរិយាបថឆ្លើយតបរបស់គ្រូលើការអនុវត្តកម្មវិធីសិក្សាដែលកំពុងបង្រៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺនេះដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា៥ ជំពូកដូចខាងក្រោម៖

- ***ជំពូកទី១៖ សេចក្តីផ្តើម:*** ពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហា បញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ***ជំពូកទី២៖ រំឭកទ្រឹស្តី:*** ធ្វើការបង្ហាញ និងពន្យល់យ៉ាងលម្អិតទៅលើទ្រឹស្តីទាំងឡាយដែលជាប់ទាក់ទងទៅនឹងឥរិយាបថឆ្លើយតបរបស់គ្រូលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ។
- ***ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ:*** ជំពូកនេះលើកឡើងពីគម្រោងនៃការវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។
- ***ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា:*** ជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគយ៉ាងលម្អិតទៅលើកម្រង សំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែងដើម្បីរកឱ្យឃើញពីឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា បញ្ហាប្រឈមនៃការអនុវត្តកម្មវិធីសិក្សា ព្រមទាំងបង្ហាញពីយន្តការចុះពិនិត្យតាមដាន និងវាយតម្លៃរបស់គណៈគ្រប់គ្រងសាលាទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាបឋមភូមិ ក្នុង

ខេត្តកំពង់ស្ពឺ។

❖ ***ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរៈ*** ធ្វើសេចក្តីសន្និដ្ឋាន ឆ្លើយតបទៅលើសំនួរស្រាវជ្រាវ ដោយបង្ហាញលទ្ធផលតាមរយៈទិន្នន័យដែលបានពីកម្រងសំណួរ និងការសង្ខេបខ្លឹមសារពិភាក្សា តាមរយៈការឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និង ចំណុចត្រូវកែលម្អ។ លើកសំណូមពរតាមរយៈប្រធានបទសិក្សា ដល់ភាគីពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវបន្តនៅថ្ងៃអនាគត ដើម្បីពង្រីកវិសាលភាពនៃលទ្ធផលលើប្រធានបទដែលបានលើកយកមកសិក្សាស្រាវជ្រាវរួច។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១ ព័ត៌មានទូទៅពីខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺ ជាខេត្តដែលមានចម្ងាយ ៤៨គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ព្រំប្រទល់ខាងកើតជាប់ខេត្តតាកែវ និងខេត្តកណ្តាល ខាងត្បូងជាប់ខេត្តតាកែវ និងខេត្តកំពត ខាងលិចជាប់ខេត្តព្រះសីហនុ និងខេត្តកោះកុង ខាងជើងជាប់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ តំបន់រដ្ឋបាលរួមមាន ស្រុក៧ និងក្រុង១ ឃុំ៨២ សង្កាត់៥ និងមានភូមិចំនួន ១.៣៧៩ភូមិ។ ផ្ទៃដីសរុបមានចំនួន៦.៩៦៥,៦៣គ.ម$^{២}$ ដែលមានគ្រួសារសរុបចំនួន ១៨៧.៨៣៥គ្រួសារ ប្រជាពលរដ្ឋចំនួន ៨៧២.២១៩នាក់ ស្ត្រី ៤២៦.០៥៥នាក់ អាយុ ១៨ឆ្នាំឡើងមាន ៥៧៣.៦៤២នាក់ ដង់ស៊ីតេប្រជាពលរដ្ឋជាមធ្យម ១២៣នាក់/គ.ម$^{២}$ ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំរបស់ប្រជាជនខេត្តកំពង់ស្ពឺ (GDP) ចំនួន ១.៦៩៣ ដុល្លា (GDP ថ្នាក់ជាតិ ចំនួន ១.៦៤៣,១ ដុល្លា)។ ពលរដ្ឋចំណាកស្រុកទៅក្រៅប្រទេសមានចំនួន ៧.១៩៣នាក់។ ក្នុងនោះដែរ វិស័យអប់រំក្នុងខេត្តកំពង់ស្ពឺ មានវិទ្យាល័យចំនួន ២៤កន្លែង អនុវិទ្យាល័យ ៧២កន្លែង បឋមសិក្សា ៣១៤កន្លែង និង មត្តេយ្យសិក្សារដ្ឋ ២០៩កន្លែង វិទ្យាស្ថាន ២ ដែលមានបុគ្គលិកទូទាំងខេត្តសរុបចំនួន ៥.៣៥១នាក់ ស្រី ២.១០១នាក់ និងមានសាកលវិទ្យាល័យឯកជន១។ ឆ្នាំសិក្សា ២០១៩-២០២០ គ្រឹះស្ថានមធ្យមសិក្សារដ្ឋមាន៩៦ ក្នុងនោះមានអនុវិទ្យាល័យ ៧២ និងវិទ្យាល័យ ២៤ (វិទ្យាល័យធនធាន ២កន្លែង)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ពី៧ ដល់ទី១២ មាន២២ និងកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១០ ដល់ទី១២ មាន ២កន្លែង។ គ្រឹះស្ថានសិក្សាឯកជនមាន ៨ក្នុងនោះអនុវិទ្យាល័យ៣ និងវិទ្យាល័យ៥។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ៥កន្លែង។ ឃុំសង្កាត់ ២លើ ៨៧ ស្មើនឹង ២,៣% ពុំទាន់មានអនុវិទ្យាល័យ នៅស្រុកគងពិសី និងស្រុកបរសេដ្ឋ។ អនុវិទ្យាល័យ ៧០កន្លែង ស្មើនឹង ៩៧,២២% និងវិទ្យាល័យ ២៤ ស្មើនឹង ១០០% មានបង្គន់ និងទឹកស្អាតប្រើប្រាស់។ បុគ្គលិកអប់រំមាន ២.២៦៦នាក់ ស្រី ៧៤១នាក់ ហើយបុគ្គលិកបង្រៀនមាន ១.៩៧៩នាក់ ស្រី ៦៩៧នាក់។ ក្នុងនោះបុគ្គលិកមធ្យមសិក្សាបឋមភូមិសរុប ១.៦០៨នាក់ ស្រី ៥៣៤នាក់ ហើយបុគ្គលិកបង្រៀនមាន ១.៤០៩នាក់ ស្រី ៥០៦នាក់ សិស្សមានចំនួន

៣៤.១៧៩នាក់ ស្រី ១៧.៩០០នាក់ (សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៩-២០២០)។

## ២.២ និយមន័យ

ឥរិយាបថ ជាផ្លូវ ឬ គន្លងនៃឥរិយាបថ គឺការដើរ ឈរ ដេក អង្គុយ។ ហើយសម្រេចឥរិយាបថ គឺប្រើឥរិយាបថ ឧទាហរណ៍ សម្រេចឥរិយាបថដេក គឺសម្រេចការដេក (សម្តេចព្រះសង្ឃរាជ ជួន ណាត, ១៩៦៨)។

ឥរិយាបថឆ្លើយតប ជាការបង្ហាញនូវលក្ខណៈនៃការយល់ដឹងដែលបង្កប់នូវអារម្មណ៍ និងមនោញ្ចេតនា ហើយជះឥទ្ធិពលដល់ការសម្រេចចិត្តថាតើត្រូវធ្វើ ឬមិនធ្វើ (Bastug, 2014)។ ឥរិយាបថឆ្លើយតបជានិន្នាការមួយក្នុងការឆ្លើយតបជាវិជ្ជមានឆ្ពោះទៅរកគំនិត វត្ថុ មនុស្ស ឬស្ថានភាពជាក់លាក់ណាមួយ។ ឥរិយាបថមានឥទ្ធិពលលើជម្រើសសកម្មភាពរបស់បុគ្គល និងឆ្លើយតបទៅនឹងគ្រឿងរំញោចនានា ដូចជាបញ្ហាប្រឈម និងការលើកទឹកចិត្តជាដើម។ សមាសធាតុសំខាន់ទាំងបួននៃឥរិយាបថរួមមាន (១)អារម្មណ៍ (២)ជំនឿ ឬ គំនិតប្រកបដោយមនសិការ (៣)ទំនោរសម្រាប់សកម្មភាព និង (៤)ការឆ្លើយតបជាវិជ្ជមាន ឬអវិជ្ជមានទៅនឹងរំញោច (ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។ ចំណែកក្នុងការបង្រៀន និងរៀន ឬ ក្នុងការសិក្សាចិត្តវិទូខាងអប់រំនិយមលោក Benjamin S. Bloom (1956) បានចែកវត្ថុបំណងនៃការរៀនដោយផ្អែកតាមវិស័យទាំងបីនៃជីវិតផ្លូវចិត្តរបស់មនុស្សគឺ វិស័យពុទ្ធិ ឬ ចំណេះដឹង (Cognitive) វិស័យសញ្ចេតនា (Affective) វិស័យឆន្ទៈ ឬចិត្តចលនា (Psychomotor)។

សរុបមក ឃើញថា ឥរិយាបថឆ្លើយតប គឺជាការសិក្សាពីសកម្មភាព ឬទង្វើដែលស្តែងឡើងដោយឆ្លុះបញ្ចាំងពីអារម្មណ៍របស់បុគ្គលម្នាក់ៗ។

## ២.៣ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា

នៅក្នុងការសិក្សានេះ អ្នកសិក្សានឹងពិនិត្យទៅលើឥរិយាបថឆ្លើយតបដែលកើតមាន ចំពោះការអនុវត្តកម្មវិធីសិក្សា ទង្វើរបស់គ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ ចំពោះការអនុវត្តកម្មវិធីសិក្សាយោងតាម ចិត្តវិទូខាងអប់រំនិយមប្រើចំណាត់ថ្នាក់របស់លោកប្លូម (Benjamin S. Bloom) ក្នុងការចាត់ថ្នាក់វត្ថុបំណងនៃការរៀន (Bloom's Taxonomy of Learning Objective) ត្រូវបានចែកជាបីផ្នែក គឺ

វិស័យពុទ្ធិ ឬចំណេះដឹង( Cognitive Domain) វិស័យសញ្ចេតនា(Affective Domain) និងវិស័យធន្ទៈ ឬ ចិត្តចលនា( Psychomotor Domain) ផ្នែកទាំងបីនៃវត្ថុបំណង ឬភារកិច្ចនៃការបង្រៀន និងរៀននេះ ត្រូវបានអ្នកបណ្តុះបណ្តាលគ្រូ និងអ្នកអប់រំនិយមហៅថា KSA ដែល Kមកពីពាក្យ Knowledge គឺចំណេះដឹង ឬពុទ្ធិដែលស៊ីគ្នា នឹងវិស័យពុទ្ធិ ឬចំណេះដឹង (Cognitive Domain) S មកពីពាក្យ Skills គឺបំណិនដែលស៊ីគ្នានឹងវិស័យធន្ទៈ ឬចិត្តសាស្ត្រ (Psychomotor Domain) និងA ជាអក្សរកាត់នៃ Attitude គឺឥរិយាបថដែលស៊ីគ្នានឹងវិស័យ សញ្ចេតនា (Affective Domain)។

កម្មវិធីមធ្យមសិក្សាបឋមភូមិ សំដៅលើចំណេះដឹង បំណិន និងឥរិយាបថដែលរំពឹងថាសិស្សបានរៀន ក្នុងនោះរួមមាន ស្តង់ដារសិក្សា ឬវត្ថុបំណងសិក្សាដែលរំពឹងថាសិស្សនឹងចេះឯកតា និងមេរៀននានាដែលគ្រូបង្រៀន កិច្ចការដែលបានដាក់ឱ្យសិស្សធ្វើ សៀវភៅ សម្ភារៈ វីដេអូ បទបង្ហាញ និងការអានដែលប្រើប្រាស់ នៅក្នុងមធ្យមសិក្សាបឋមភូមិ ព្រមទាំងតេស្តវង្វាយតម្លៃនានា និងវិធីសាស្ត្រផ្សេងទៀតដែលគេប្រើ ដើម្បីវាយតម្លៃការលទ្ធផលសិក្សារបស់សិស្ស។

ដូច្នេះការសិក្សានេះនឹងពិនិត្យទៅលើទង្វើ ឬចិត្តចលនានៃឥរិយាបថឆ្លើយតបដែលជាកត្តាដ៏សំខាន់មួយសម្រាប់ភាពជោគជ័យក្នុងការអនុវត្តកម្មវិធីសិក្សា។ ជាពិសេសការសិក្សានេះនឹងពិនិត្យទៅលើឥរិយាបថឆ្លើយតបរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិចំពោះការអនុវត្តកម្មវិធីសិក្សាដោយសង្កេតទៅលើផ្នែកមួយនៃ វត្ថុបំណងរបស់ Bloom's Taxonomy គឺ ចិត្តចលនា ឬបំណិន (Psychomotor) ។ បន្ថែមពីលើនេះផងដែរការសិក្សានេះក៏នឹងរកឱ្យឃើញនូវបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញពីយន្តការនៃការចុះពិនិត្យតាមដាន និងវាយតម្លៃរបស់គណៈគ្រប់គ្រងសាលាទៅលើការ អនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺផងដែរ។

## ២.៤ ទ្រឹស្តីពីការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ

### ២.៤.១ ការអនុវត្តកម្មវិធីសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមកែទម្រង់ប្រព័ន្ធអប់រំជាពិសេសពិនិត្យ និងកែលម្អឡើងវិញនូវកម្មវិធីសិក្សា ការរៀននិងបង្រៀន រៀបចំក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា បុគ្គលិកលក្ខណៈពេញលេញ និងមានលទ្ធភាពចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។ កម្មវិធីសិក្សាចំណេះទូទៅជានាអប់រំពលរដ្ឋ ឱ្យមានលក្ខណសម្បត្តិពេញលេញប្រកប ដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។ ដើម្បីសម្រេចបាននូវការអនុវត្តកម្មវិធីសិក្សាគ្រូបង្រៀនត្រូវផ្តោតលើចំណុចសំខាន់ៗដូចជា៖១) គ្រូបង្រៀនត្រូវមានចំណេះដឹងច្បាស់លាស់ និងស៊ីជម្រៅលើកម្មវិធីសិក្សា មុខវិជ្ជាបង្រៀន និងវិធីសាស្ត្របង្រៀន ២) គ្រូបង្រៀនត្រូវមានបំណិន ក្នុងការវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់ និងសាលារៀន ប្រើប្រាស់លទ្ធផលដើម្បីកែលម្អវិធីសាស្ត្របង្រៀននិងរៀន ការបំពេញជាតុចូលទៅតាមតម្រូវការពិសេសរបស់សិស្ស។ ៣) គាំទ្រគ្រូបង្រៀនទាំងផ្នែកបច្ចេកទេស សម្ភារឧបទេស និងស្មារតីដើម្បីលើកទឹកចិត្ត ពួកគាត់ ឱ្យអនុវត្តវិធីសាស្ត្របង្រៀនផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌលដើម្បីឆ្លើយតបនឹងក្របខណ្ឌកម្មវិធីថ្មី និងបរិបទពិភពលោក។ ៤) គ្រូបង្រៀនត្រូវមានភាពច្នៃប្រឌិត និងបង្កើតស្នាដៃក្នុងការសិក្សាស្រាវជ្រាវប្រតិបត្តិសម្រាប់ប្រើប្រាស់ក្នុងការរៀន និងបង្រៀនពេញមួយជីវិត (ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។

គុណភាពអប់រំបានទទួលរងឥទ្ធិពលពីកត្តាជាច្រើន ជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធ ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅអនុវត្តសម្ភារឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពសិស្ស។ ឯកសារទាំងនេះរៀបចំឡើងគឺ ដើម្បីជានាប្រសិទ្ធភាពនៃការរៀន និងបង្រៀន និងការពាក់ព័ន្ធនៃចំណេះដឹងសម្រាប់បម្រើការរស់នៅប្រចាំថ្ងៃ។ លើពិភពលោក ប្រទេសនីមួយៗតែងមានកម្មវិធីសិក្សាប្លែកៗពីគ្នា ទោះបីជាយ៉ាងណាក៏កម្មវិធីសិក្សាទាំងនោះតែងតែមានចំណុចរួមដូចគ្នាគឺ គោលបំណង វិសាលភាព និងលំដាប់លំដោយវិធីសាស្ត្ររៀន បង្រៀន លទ្ធផលរំពឹងទុក និងការវាយតម្លៃ។ នៅក្នុងឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលឆ្នាំ(២០២០) របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីទស្សនៈរបស់

លោក JESUS C.PALMA បានបំភ្លឺឱ្យយើងយល់ច្បាស់ថា "Curriculum" មិនមែនមានន័យត្រឹមតែបញ្ជីមុខវិជ្ជា ឬខ្លឹមសារមេរៀន ឬសេចក្តីណែនាំសង្ខេបអំពីមេរៀនដែលគ្រូត្រូវបង្រៀន ឬខ្លឹមសារដែលមាននៅក្នុងសៀវភៅនោះទេ។ លោក PAY បានសរសេរថា "កម្មវិធីសិក្សាជាបទពិសោធទាំងអស់ ដែលសិស្សម្នាក់ៗទទួលបានពីកម្មវិធីអប់រំ" ក្នុងនោះមានគោលបំណងត្រឹមត្រូវចំគោលដៅ ដើម្បីសម្រេចគោលបំណងបាន និងវត្ថុបំណងជាក់លាក់មួយចំនួនដែលពាក់ព័ន្ធ ព្រមទាំងត្រូវបានរៀបចំផែនការមួយតាមរយៈបណ្តាញទ្រឹស្តីនៃការស្រាវជ្រាវ និងការប្រតិបត្តិវិជ្ជាជីវៈកន្លងមក និងបច្ចុប្បន្ន។ ដូច្នេះ ការអនុវត្តកម្មវិធីសិក្សា ជាបណ្តុំចំណេះដឹង បំណិន ឥរិយាបថ ដែលត្រូវបានគ្រូបង្រៀនជាអ្នកអនុវត្ត និងផ្ទេរទៅកាន់សិស្សគ្រប់ៗរូប។

### ២.៤.២ កម្មវិធីសិក្សា៖ ការអប់រំពលរដ្ឋពេញលេញនៅមធ្យមសិក្សាបឋមភូមិ

កម្មវិធីសិក្សាតម្រូវឱ្យគរុសិស្សទាំងអស់ត្រូវស្វែងយល់ឱ្យបានច្បាស់អំពីគោលដៅអប់រំជាតិ ក៏ដូចជាយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានលើកឡើង ដើម្បីឱ្យគរុសិស្សទាំងអស់ដែលអនាគតក្លាយទៅជាគ្រូបង្រៀននោះដើរចំទិសដៅនៃការរំពឹងទុករបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកសាងនិងអភិវឌ្ឍគុណភាពអប់រំឱ្យរឹតតែទទួលបាននូវភាពល្អប្រសើរឡើងថែមទៀត ឆ្លើយតបបានទៅនឹងតម្រូវការនិងសំណូមពរចាំបាច់របស់សង្គមក៏ដូចជាពិភពលោក ដែលកំពុងតែត្រូវការនូវធនធានមនុស្ស។ ក្នុងបរិបទនេះ ការអប់រំនៅប្រទេសកម្ពុជាមានគោលដៅកសាងមនុស្សមានលក្ខណៈពេញលេញជាពលរដ្ឋតាមលក្ខខណ្ឌដូចជា ១). ពលរដ្ឋល្អជាពលរដ្ឋដែលមានចំណេះដឹងលើគ្រប់វិស័យ វប្បធម៌ សង្គមធម៌ បច្ចេកទេស និងវិទ្យាសាស្ត្រ ២). ពលរដ្ឋថ្លៃថ្នូរជាពលរដ្ឋដែលមានការអភិវឌ្ឍទាំងស្មារតី សញ្ចេតនា និងឥរិយាបថដូចជា មានសាមគ្គីភាព សហការ ស្រលាញ់យុត្តិធម៌ ស្មារតីទទួលខុសត្រូវ ៣). ពលករជំនាញជាពលរដ្ឋមានសមត្ថភាពគ្រប់គ្រាន់ និងមានបំណិន ដូចជា មានការចេះច្នៃប្រឌិត ចេះប្រើប្រាស់ចំណេះដឹងដើម្បីដោះស្រាយជីវភាពរស់នៅ។

ម្យ៉ាងវិញទៀត ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកទេសទំនើបនាពេលបច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សដោយខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើកំណែទម្រង់កម្មវិធីសិក្សាក្នុងវិស័យអប់រំ ហើយនិងបានកំណត់

យុទ្ធសាស្ត្រ៣ ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍនោះគឺ៖១). សកលកម្មអប់រំចំណេះទូទៅមូលដ្ឋាន៩ឆ្នាំ និង បង្កនូវលក្ខណៈងាយស្រួលសម្រាប់អក្ខរកម្មវិជ្ជាជីវៈ ដោយផ្សារភ្ជាប់ទៅនឹងជីវភាពជាក់ស្តែងចំពោះពលរដ្ឋ ទាំងឡាយ ដែលគ្មានលទ្ធភាពចូលរៀនក្នុងសាលាចំណេះទូទៅ។ ២). ទំនើបកម្មកំណែលម្អគុណភាពនៃ ប្រព័ន្ធអប់រំទាំងមូលឱ្យមានប្រសិទ្ធភាព ឆ្លើយតបបានត្រឹមត្រូវ ទៅនឹងតម្រូវការសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។ ៣). ផ្សារភ្ជាប់ការងារបណ្តុះបណ្តាលទៅនិងទីផ្សារពលកម្ម ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពរបស់ យុវវ័យឱ្យយកចំណេះដឹង និងបំណិនរបស់ខ្លួនទៅប្រើប្រាស់ក្នុងជីវភាពសង្គម។ ក្នុងន័យនេះក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែលម្អគ្រប់ផ្នែកអប់រំ ជាពិសេសផ្នែកអប់រំទូទៅ ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ សិស្សឱ្យក្លាយទៅជាពលរដ្ឋមានលក្ខណៈសម្បត្តិអាចចូលរួមគ្រប់សកម្មភាពជាពិសេសក្នុងផលិតកម្មអភិវឌ្ឍ សង្គមជាតិ ដោយឈរលើស្មារតីសហការសាមគ្គី អធ្យាស្រ័យ ច្នៃប្រឌិត ទទួលខុសត្រូវចេះពិចារណា មាន ឥរិយាបថ និងអាកប្បកិរិយាសមរម្យថ្លៃថ្នូរ ដើម្បីរួមចំណែកក្នុងការអភិឌ្ឍសង្គមជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តកម្មវិធីសិក្សា លម្អិតគ្រប់មុខវិជ្ជាគ្រប់កម្រិតសិក្សានៅឆ្នាំ២០១៨ ដែលផ្តោតលើបញ្ញត្តិ និងគោលវិធីសិស្សមជ្ឈមណ្ឌលដោយ ប្រើវិធីសាស្ត្របង្រៀនតាមបែបរិះរក និងវិធី សាស្ត្រផ្សេងៗទៀត។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីកម្រិតសិក្សា ដាច់ដោយឡែកពីគ្នា តែប្រទាក់ក្រឡា និងគាំទ្រគ្នាពីកម្រិតសិក្សាមួយទៅកម្រិតសិក្សាមួយទៀតពីមុខវិជ្ជាមួយទៅ មុខវិជ្ជាមួយទៀត និងភាពឆ្លើយតប នៃកម្មវិធីសិក្សាពីមធ្យមសិក្សាទៅឧត្តមសិក្សា។ ម៉ោងសិស្សប្រចាំឆ្នាំនៅ កម្រិតមធ្យមសិក្សាបឋមភូមិមាន ១៤០០ម៉ោង (៤០ម៉ោងក្នុងមួយសប្តាហ៍) មុខវិជ្ជាមួយចំនួនត្រូវបាន សម្រួលបញ្ចូល និងបំបែកដូចជា មុខវិជ្ជា បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ភាសាបរទេស បំណិនជីវិត តាមមូលដ្ឋាន និងមុខវិជ្ជាអប់រំសុខ ភាព ជាពិសេសការលើកកម្ពស់មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ការកែទម្រង់កម្ម វិធីសិក្សាទាំងបីកម្រិតសំដៅបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែល មានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។ ក្រសួងក៏មានយុទ្ធសាស្ត្រ ឬអន្តរាគមន៍នានាត្រូវបង្កើនបន្ថែមទៀតដូចជា កម្មវិធីផ្តល់អាហារូបករណ៍ កម្មវិធីប្រព័ន្ធរំលឹកជាមុន ដើម្បី

ទប់ស្កាត់ការបោះបង់ការសិក្សា ការអនុវត្តការគ្រប់គ្រងសាលារៀនក៏ដូចជា ការគ្រប់គ្រងថ្នាក់រៀន និងការអនុវត្តកម្មវិធីសិក្សា ព្រមទាំងជំរុញឱ្យសិស្សរៀនសូត្រកាន់តែសកម្មក្នុងថ្នាក់រៀន (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០១៩)។ កម្មវិធីសិក្សាលម្អិតនៅមធ្យមសិក្សាភូមិមាន ១).ចក្ខុវិស័យ ៖ ជានាអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាង វិជ្ជាសម្បទា បំណិន សម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិកាស្នេហាជាតិដើម្បីអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ២). ប្រព័ន្ធអប់រំ ៖ ១២ឆ្នាំ (៦ + ៣ + ៣ ) ដែលចែកចេញជាបឋមសិក្សាមានរយៈពេល ៦ឆ្នាំ មធ្យមសិក្សាបឋមភូមិមានរយៈពេល ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិមានរយៈពេល ៣ឆ្នាំ(ចំណេះទូទៅអប់រំបច្ចេកទេស)។ ទម្រង់កម្មវិធីសិក្សារួមមាន ប្រធានបទ ខ្លឹមសារ លទ្ធផលរំពឹងទុក ដែលមានចំនួន ៣៥សប្តាហ៍ ក្នុង១ឆ្នាំសិក្សា ចំនួនម៉ោងសិក្សា១ឆ្នាំសិក្សា ១៤០០ម៉ោង និងចំនួនម៉ោងសរុបប្រចាំសប្តាហ៍ ៖ ៤០ម៉ោង។

| **ល.រ** | **មុខវិជ្ជា** | **ថ្នាក់** | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

តារាង២.១៖ កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាក្នុងមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ២០១៨

សម្គាល់ ៖ ៦ថ្ងៃ(មួយសប្តាហ៍) ៤ម៉ោង-៥ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០

នាទី ហើយជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ២.៥ ទ្រឹស្តីពីបញ្ហាប្រឈម ការអនុវត្តកម្មវិធីសិក្សា

ដោយសារតែភាពរីកចម្រើន និងការវិវត្តនៃសង្គមសេដ្ឋកិច្ចនៅកម្ពុជា តំបន់ និងពិភពលោកនាពេលបច្ចុប្បន្នទាមទារឱ្យពលរដ្ឋកម្ពុជាមានការអភិវឌ្ឍនូវសមត្ថភាព ក្លាយជាពលរដ្ឋពេញលេញ ដោយផ្សារភ្ជាប់ទៅនិងបទពិសោធរបស់ពួកគាត់ និងការអនុវត្តជាក់ស្តែងនៅក្នុងជីវភាពរស់នៅ។ កម្មវិធីសិក្សា ដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្សឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម សេដ្ឋកិច្ច។

យោងតាមលោកBuczynski & Hansen (2010) បានរកឃើញថា បញ្ហាប្រឈមជាច្រើនដែលគ្រូបានរាយការណ៍រួមមាន៖ កង្វះខាតការបែងចែកពេលវេលាតាមកម្មវិធីបង្រៀនដែលត្រូវការប្រើប្រាស់ចំណេះដឹង និងជំនាញថ្មី ការតម្រូវឱ្យបង្រៀនមេរៀនទៅតាមកម្មវិធីសិក្សាជាជំណាក់ៗ កង្វះខាតធនធាន(ដូចជាសម្ភារះបម្រើឱ្យកម្មវិធីសិក្សា គ្រឿងបម្រុងបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ) ព្រមទាំងបញ្ហាការគ្រប់គ្រងថ្នាក់។ ការសិក្សានោះបានសន្និដ្ឋានថា កង្វះធនធាន គឺជាឧបសគ្គដ៏ធំបំផុត ដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈ។ យោងតាមលោក Badri (2016) បានរកឃើញបញ្ហាប្រឈមបន្ថែមទៀតដែលគ្រូបានជួបប្រទះមានដូចជា៖ កង្វះខាតការជួយជ្រោមជ្រែងពីនិយោជក ការជាន់គ្នានឹងកាលវិភាគបំពេញការងារ កង្វះខាតពេលវេលាព្រោះរវល់ជាមួយគ្រួសារ និងកង្វះខាតការផ្តល់វគ្គអភិវឌ្ឍវិជ្ជាជីវៈដែលប្រើការបានសម្រាប់ការងាររបស់ខ្លួន។ ការសិក្សាផ្សេងមួយទៀតដោយ (Ros & Oleksiyenko, 2017) បានរកឃើញថាស្ថាប័នគ្រប់គ្រងគ្មានធនធានគ្រប់គ្រង និងទឹកចិត្តក្នុងការរៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដល់បុគ្គលិក។ យោងតាមឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ឆ្នាំ២០២០ បង្ហាញថាកម្មវិធីសិក្សា មុខវិជ្ជាសិក្សាសង្គម បច្ចុប្បន្នបានបណ្តុះកុមារកម្ពុជាឱ្យមានសមត្ថភាពចងចាំ តាមរយៈកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលដោយផ្តោតលើខ្លឹមសារ នាំឱ្យកុមារកម្ពុជាភាគច្រើនទទួលបានត្រឹមតែវិជ្ជាសម្បទា ដោយហេតុនេះហើយ ធ្វើឱ្យគ្រូបង្រៀនភាគច្រើន អនុវត្តកម្មវិធី ផ្តោតទៅលើវិធីសាស្ត្របង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល។ តាមរយៈកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាដែលសម្បូរបែបទៅដោយខ្លឹមសារ បានធ្វើឱ្យកុមារដែលបញ្ចប់ការសិក្សាតាមភូមិសិក្សានីមួយៗ ប្រឈមនឹងបញ្ហាជាច្រើនដូចជា៖

- គ្រូបង្រៀនភាគច្រើន ប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបឧទ្ទេស (គ្រូមជ្ឈមណ្ឌល)
- សកម្មភាពរៀនសូត្ររបស់សិស្សភាគច្រើនមានតែនៅក្នុងថ្នាក់រៀន
- សកម្មភាពរៀន និងបង្រៀន មិនមានអន្តរកម្មរវាងសិស្ស និងសិស្ស និងរវាងគ្រូនិងសិស្ស ដើម្បីជំរុញការរៀនសូត្រ
- ចំណេះដឹង បំណិនដែលសិស្សទទួលបានមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ
- មិនបានបណ្តុះស្មារតីសិស្សឱ្យមានភាពក្លាហាន និងគំនិតសិក្សាស្រាវជ្រាវដំណើរការតាមដានលើការអនុវត្តកម្មវិធីសិក្សា មុខវិជ្ជាសិក្សាសង្គម នៅមានកម្រិត។

## ២.៦ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១

គ្រូបង្រៀន ជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ ការងាររបស់គ្រូបង្រៀន គឺជាការងារសាំញ៉ាំដែលមានលក្ខណៈមិនច្បាស់លាស់ ប្រែលប្រួលជាប្រចាំ និងភាពស្រពិចស្រពិល ហើយទាមទារនូវគំនិតផ្តួចផ្តើម ការគិត សុភវិនិច្ឆ័យ និងជំនាញកម្រិតខ្ពស់ ដើម្បីជានាតួនាទីនេះប្រកបដោយគុណភាព។ សម្រាប់ការអប់រំនាសតវត្សរ៍ទី២១ គ្រូបង្រៀនលែងដើរតួនាទីសំខាន់ជាអ្នកផ្តល់ចំណេះដឹងដល់សិស្សដោយផ្ទាល់ដូចកាលពីមុនទៀត ហើយមានព័ត៌មានល្អៗ ជាច្រើនដែលសិស្សអាចទទួលបានមកពីប្រភពក្រៅ។ តួនាទីគ្រូពេលនេះលែងជាអ្នកផ្តល់ចំណេះដឹងដល់សិស្សដោយផ្ទាល់ទៀតហើយ ប៉ុន្តែត្រូវដើរតួជាអ្នកជួយសម្របសម្រួលសិស្សក្នុងដំណើរការវិភាគ វាយតម្លៃការសិក្សារៀនសូត្រ តាមរយៈមធ្យោបាយជំរុញឱ្យមានការច្នៃប្រឌិត ការគិតល្អិតល្អន់ ស៊ីជម្រៅ កិច្ចសហការ និងជំនាញទំនាក់ទំនង។ គោលវិធីសិស្សមជ្ឈមណ្ឌល ជាបេះដូងនៃការអប់រំនាសតវត្សរ៍ទី២១ ដែលតួនាទីគ្រូ គឺត្រូវជួយសិស្សក្នុងការផ្ទៀងផ្ទាត់សំយោគព័ត៌មាន ចំណេះដឹងអំពីមេរៀន សហការគ្នាស្វែងរកព័ត៌មានចំណេះដឹង និងដោះស្រាយរាល់បញ្ហាដែលបានកើតឡើង។ ក្នុងរយៈពេល១៥ឆ្នាំនៃសម័យសតវត្សរ៍ទី២១នេះ យើងហាក់ដូចជាមិនទាន់បានធ្វើអ្វីច្រើនទាក់ទងនឹងការអប់រំ ឱ្យមានការផ្លាស់ប្តូរឆ្លើយតបគោលការណ៍នេះទេ (Dewey, 2015)។

គ្រូបង្រៀនត្រូវបានកំណត់ថាជាមនុស្សដ៏សំខាន់ ដែលធ្វើសកម្មភាពក្នុងស្មារតីខិតខំធ្វើយ៉ាងណាឱ្យ

សិស្សទទួលបាននូវការរីកចម្រើនខាងបញ្ញា ស្មារតី និងសុខភាពរាងកាយយ៉ាងល្អប្រសើរ។ វិធីសាស្ត្របង្រៀនសម្រាប់ការអប់រំសតវត្សទី២១ មានចរិកលក្ខណៈសហការ និងផ្តល់ពហុជំនាញខុសៗគ្នាជាច្រើនដល់សិស្ស។ ទម្រង់រៀន និងបង្រៀនបែបនេះ គ្រូបង្រៀនក៏អនុវត្តជានិច្ចក្នុងសហគមន៍រៀនអាជីព ដែលហៅថា PLC ដែលផ្តោតសំខាន់ទៅលើដំណើរការសិក្សា និងលទ្ធផល ការសម្រេចចិត្តលើព័ត៌មានសិក្សា ការចែករំលែកចំណេះដឹងអំពីមេរៀន វិធីសាស្ត្រ និងជំនាញក្នុងចំណោមគ្រូបង្រៀន ជំនាញសម្រាប់គ្រូបង្រៀន ដើម្បីបង្រៀនក្នុងថ្នាក់រៀននៃសតវត្សរ៍ទី២១ គឺជាបញ្ហាដ៏ស្មុគស្មាញ ក្នុងប្រទេសជាច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច។ បច្ចុប្បន្ននេះ ពេលដែលអ្នករៀនភាគច្រើន អាចស្វែងរកប្រភពមេរៀនដោយប្រើបច្ចេកវិទ្យាបាន និងនៅពេលដែលចំណេះដឹងដែលយើងប្រើជម្មតាសព្វថ្ងៃនេះមានគេធ្វើឌីជីថលរូបនីយកម្ម ឬផ្គត់ផ្គង់ពីក្រៅ និងនៅពេលដែលរបៀបរបបធ្វើការងារមានការប្រែប្រួលយ៉ាងឆាប់រហ័ស គ្រូបង្រៀនត្រូវជួយជំរុញសិស្ស ក្លាយជាអ្នកសិក្សាពេញមួយជីវិត ដើម្បីគ្រប់គ្រងរបៀបគិតស្មុគស្មាញដែលគ្មានវិធានច្បាស់លាស់ និងរបៀបនៃការធ្វើការដ៏ស្មុគស្មាញរបស់មនុស្ស ដែលម៉ាស៊ីនកុំព្យូទ័រមិនអាចជំនួសដោយស្រួលបាន។

ប្រព័ន្ធគ្រប់គ្រងការអប់រំ រួមមានការគ្រប់គ្រងគោលនយោបាយអប់រំ ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន និងសាលារៀន។ លោកHoy and Miskel (2008) បានសំយោគរបៀបគ្រប់គ្រងការអប់រំនៅកម្រិតសាលារៀនថា ជាប្រព័ន្ធសង្គមបើកចំហមួយដែលមានធាតុផ្សំប្រាំ ឬឧបសម្ព័ន្ធប្រាំះ រចនាសម្ព័ន្ធ បុគ្គល វប្បធម៌ នយោបាយ និងគរុកោសល្យ។ ឥរិយាបថស្ថាប័ន កើតចេញពីបន្សំនៃអន្តរកម្មនៃធាតុទាំងប្រាំពេល គឺកើតចេញពីបរិបទនៃការបង្រៀន និងរៀន។ ដំណើរការបង្រៀន និងរៀនជាសកម្មភាពស្នូលនៃប្រព័ន្ធសង្គមសាលារៀន។ សូនាកវាស់វែងប្រសិទ្ធភាពអាចនឹងត្រូវបានយកមកប្រើសម្រាប់ដំណាក់កាលនីមួយៗនៃប្រព័ន្ធបើកចំហវដ្តនៃធាតុចូល (មនុស្ស និងហិរញ្ញវត្ថុ) រំរូបកម្ម(ដំណើរការខាងក្នុង និងរចនាសម្ព័ន្ធ) និងគុណផល។ ការចាត់ទុកសាលារៀនជាប្រព័ន្ធបើកចំហមួយមានន័យថា គេបានមើលឃើញពីបណ្តុំនៃធាតុធ្វើឱ្យមានអន្តរកម្មក្នុងប្រព័ន្ធសាលារៀន គឺមានន័យថាប្រព័ន្ធសាលារៀនទទួលធនលាភពីខាងក្រៅ និងការផ្លាស់ប្តូរ(transformation) និងវិបរិតកម្ម (conversion) ជាតុចូលឱ្យទៅជាផលសម្រេច សម្រាប់

បរិយាកាសសាលារៀន(មនុស្ស វត្ថុធាតុដើម ព័ត៌មាន និងថវិកា ជាធាតុចូលធម្មតាសម្រាប់សាលារៀន)។ ក្នុងដំណើរការនិម្មិតកម្មនេះ ជាតុចេញទាំងអស់ត្រូវបំប្លែងឱ្យទៅជាគុណតម្លៃមួយថ្មី ហៅថាផលសម្រេច ហើយត្រូវបានយកទៅប្រើក្នុងសាលារៀន។ ផលសម្រេច ជាទូទៅជាផលិតផល និងសេវាកម្ម ប៉ុន្តែត្រូវរាប់បញ្ចូលទាំងសោមនស្សភាពរបស់បុគ្គលិក និងអនុផលផ្សេងៗទទួលបានពីដំណើរនិម្មិតកម្មផងដែរ។ បន្ទប់រៀនកុំព្យូទ័រ សៀវភៅសិក្សា គ្រូបង្រៀន និងសិស្ស គឺជាធាតុចូលយ៉ាងសំខាន់សម្រាប់សាលារៀន។

លក្ខខណ្ឌវិនិច្ឆ័យក្នុងដំណើរការនិម្មិតកម្ម សំដៅដល់បរិមាណ គុណភាព និងសង្គតិភាពនៃដំណើរការ និងរចនាសម្ព័ន្ធផ្ទៃក្នុង និងមានតួនាទីក្នុងការនិម្មិតធាតុចូលឱ្យទៅជាផល។ ឧទាហរណ៍អំពីលក្ខខណ្ឌវិនិច្ឆ័យក្នុងដំណើរការនិម្មិតកម្ម រួមមាន រចនាសម្ព័ន្ធ និងមាតិកានៃកម្មវិធីសិក្សា សុខភាពនៃអន្តរទំនាក់ទំនងមនុស្ស កម្រិតនៃការលើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ភាពជាអ្នកដឹកនាំក្នុងចំណោមគ្រូបង្រៀន និងមន្ត្រីរដ្ឋបាល គុណភាព និងបរិមាណនៃការបង្រៀន និងនីតិវិធីគ្រប់គ្រងគុណភាព។

## ២.៧ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

គន្លងអាជីពគ្រូបង្រៀន ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡាផ្អែកតាមនិន្នាការនៃការអនុវត្តគន្លងអាជីពនៅប្រទេសអភិវឌ្ឍ និងក្នុងតំបន់ក្នុងគោលដៅពង្រឹងគុណភាពបុគ្គលិកអប់រំ ជាពិសេសគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ដើម្បីឆ្លើយតបនឹងការប្រែប្រួលសង្គមសេដ្ឋកិច្ចជាតិ និងអន្តរជាតិ និងដោះស្រាយក្នុងវិស័យអប់រំ (ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។ ហើយក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនមានចក្ខុវិស័យកសាងគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។ នៅប្រទេសកម្ពុជា គ្រូបង្រៀនបានតម្រូវឱ្យមានកម្រិតសញ្ញាបត្រខ្ពស់ជាងកម្រិតភូមិសិក្សាបង្រៀន សំដៅបង្កើនគុណភាពនៃការរៀន និងបង្រៀន ដែលទាមទារឱ្យគ្រូបង្រៀនភាគច្រើននៅមធ្យមសិក្សាបឋមភូមិ ត្រូវបន្តឬទទួលការបណ្តុះបណ្តាលបន្ថែម ដើម្បីទទួលបានកម្រិតសញ្ញាបត្របរិញ្ញាបត្រ។ ក្នុងឆ្នាំ ២០១៦-២០១៧ ការបណ្តុះបណ្តាលគ្រូបង្រៀនអនុវត្តប្រព័ន្ធ ១២+២ ទាំងអស់សម្រាប់គ្រប់កម្រិតសិក្សា លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិដែលអនុវត្តប្រព័ន្ធបរិញ្ញាបត្រ+១។ ដើម្បីឆ្លើយតបនឹងការរៀន

និងបង្រៀន ក្នុងសម័យបច្ចេកវិទ្យាទំនើប កម្ពុជាត្រូវការគ្រូបង្រៀនគ្រប់កម្រិតមានសញ្ញាបត្រយ៉ាងហោចណាស់បរិញ្ញាបត្រ ដើម្បីបង្រៀនចាប់ពីមត្តេយ្យរហូតដល់មធ្យមសិក្សាទុតិយភូមិ។ ថ្វីបើមានការផ្តួចផ្តើមគោលនយោបាយ និងមានកម្មវិធីដំឡើងថ្នាក់គ្រូបង្រៀន ដែលគ្មានគុណភាពទាំងអស់ទៅជាគ្រូបង្រៀនដែលមានគុណភាពតាមរយៈការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យការជ្រើសរើសសម្រាប់គ្រូបង្រៀនថ្មី និងការដាក់បញ្ចូលកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈរយៈពេលខ្លីក៏ដោយគ្រូបង្រៀនភាគច្រើននៅពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រដែលតម្រូវដោយផែនការសកម្មភាពគោលនយោបាយគ្រូថាត្រឹមឆ្នាំ២០២០ គ្រូទាំងអស់ត្រូវតែមានសញ្ញាបត្រយ៉ាងហោចណាស់ក៏ត្រឹមកម្រិតបរិញ្ញាបត្រដែរ។ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម គ្រូបង្រៀនប្រមាណជា ៨០ភាគរយ មានសញ្ញាបត្រទាបជាងបរិញ្ញាបត្រ។

| កម្រិតសិក្សាដែលបង្រៀនដោយគ្រូ | សាលាមត្តេយ្យ | បឋមសិក្សា | អនុវិទ្យាល័យ | សរុប(%) |
|---|---|---|---|---|
| បឋមសិក្សា | ១៨១ | ១,១០៤ | ៤៩៤ | ១,៧៧៩ (១.៩៣) |
| មធ្យមសិក្សាបឋមភូមិ | ១,៦៦២ | ១២,៥២១ | ៥,០៨៤ | ១៩,២៦៧ (២០.៩៤) |
| មធ្យមសិក្សាទុតិយភូមិ | ២,៨១៤ | ២៨,៧០១ | ២០,៣០៥ | ៥១,៨២០ (៥៦.៣២) |
| បរិញ្ញាបត្រ | ២១៨ | ៣,៥៨៥ | ១៤,២៣១ | ១៨,០៣៤ (១៩.៦០) |
| បរិញ្ញាបត្រជាន់ខ្ពស់ | ២ | ៩៥ | ៩៩៥ | ១,០៩២ (១.១៩) |
| បណ្ឌិត | ០ | ៣ | ១២ | ១៥ (០.០២) |
| សរុប | ៤,៨៧៧ | ៤៦,០០៩ | ៤១,១២១ | ៩២.០០៧ (១០០) |

តារាង២.២៖ សូចនាករបុគ្គលិកបង្រៀនតាមកម្រិតសិក្សា និងតាមកម្រិតសាលា (MoEYS, 2017)

ផ្អែកលើទិន្នន័យនេះ ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូបង្រៀនគឺជា កត្តាដែលត្រូវយកចិត្តទុកដាក់ដោយហេតុថា ការអភិវឌ្ឍវិជ្ជាជីវៈគ្រូ មានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹង

គុណភាពបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គ្រូចាំបាច់ត្រូវបន្តអភិវឌ្ឍវិជ្ជាជីវៈបន្តលើកកម្ពស់សមត្ថភាព ចំណេះដឹង បន្តការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីឆ្លើយតបទៅនឹងត្រូវការ និងការរីកចម្រើនឥតព្រំដែនក្នុងវិស័យអប់រំនាពេលបច្ចុប្បន្ន ក៏ដូចជានាពេលអនាគត។

ការរៀនវិជ្ជាជីវៈបង្រៀនឱ្យមានប្រសិទ្ធភាព ត្រូវផ្សារភ្ជាប់ជាមួយប្រព័ន្ធលាភការ ឬប្រព័ន្ធរង្វាន់ ដើម្បីលើកតម្កើងការបង្រៀន និងការរៀនរបស់គ្រូ។ គន្លងអាជីពគ្រូបង្រៀន ជាប្រព័ន្ធតម្រង់ទិសវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នករដ្ឋបាល ឬជាប្រព័ន្ធនាំគ្រូបង្រៀន នាយក និងអ្នករដ្ឋបាលអប់រំឱ្យជ្រើសរើសគន្លងអាជីព និងអភិវឌ្ឍអាជីព។ គន្លងអាជីពគ្រូបង្រៀន ជួយជំរុញឡើងបៀវត្សរ៍របស់បុគ្គលិកអប់រំ តាមវិជ្ជាជីវៈ ដើម្បីជានាសម្រេចគោលដៅនៃការអភិវឌ្ឍបំណិនវិជ្ជាជីវៈ។ ក្រៅពីខ្វះគ្រូដែលមានគុណសម្បទា សាលារៀនមួយចំនួនមានខ្វះ ឬលើសគ្រូបង្រៀន ឬយ៉ាងហោចណាស់មានបញ្ហាលើស ឬខ្វះគ្រូបង្រៀនតាមមុខវិជ្ជា មានចំនួនសិស្សច្រើនពេកក្នុងមួយថ្នាក់ៗ។ កត្តាមួយក្នុងចំណោមកត្តាលើស ឬខ្វះគ្រូបង្រៀន គឺកង្វះការលើកទឹកចិត្តឱ្យគ្រូបង្រៀនទៅបំពេញភារកិច្ចនៅកន្លែងដែលខ្វះខាត។

គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ គុណសម្បទារបស់គ្រូបង្រៀន ដើម្បីធានាប្រសិទ្ធភាពការងារ ដែលមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន រួមបញ្ចូលទាំងចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ ក្នុងដំណើរឆ្ពោះទៅសង្គមពុទ្ធិ បដិវត្តន៍ឧស្សាហកម្មទី៤ និងពលរដ្ឋសកល កម្ពុជាត្រូវពង្រឹងវិស័យអប់រំ ដើម្បីឱ្យពលរដ្ឋដែលឆ្លងកាត់ប្រព័ន្ធអប់រំមានកញ្ចប់សមត្ថភាព នៃសតវត្សរ៍ទី២១ ដូច្នេះគ្រូបង្រៀនត្រូវត្រៀមខ្លួន ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្ស។

## ២.៨ គោលនយោបាយស្តីពីគ្រូបង្រៀន

ដើម្បីសម្រេចបានជោគជ័យស្របទៅតាមគោលដៅអប់រំជាតិ ក៏ដូចជាសម្រេចបាននូវយុទ្ធសាស្ត្រទាំងបីរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានរៀបរាប់មកខាងលើនេះ គឺទាមទារជាសំខាន់នូវការបង្កើតនូវថ្នាក់អនុវិទ្យាល័យបន្ថែមពីលើថ្នាក់បឋមសិក្សាដែលមានស្រាប់ ដើម្បីបង្កនូវលក្ខណៈងាយស្រួល ឬផ្តល់នូវឱកាសឱ្យសិស្សានុសិស្សបានបន្តការសិក្សានៅថ្នាក់អនុវិទ្យាល័យ បន្ទាប់ពីបានបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សា។ ដោយមើលឃើញអត្រាបោះបង់ការសិក្សានៅថ្នាក់អនុវិទ្យាល័យមានកម្រិតខ្ពស់

ដោយសារសាលារៀននៅឆ្ងាយពីផ្ទះរបស់សិស្សនោះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្រ្តកាត់បន្ថយអត្រាបោះបង់ចោលការសិក្សានៅថ្នាក់អនុវិទ្យាល័យនេះ តាមរយៈការដាក់ចេញនូវផែនការកសាងសាលារៀនថ្នាក់អនុវិទ្យាល័យបន្ថែមពីលើសាលាបឋមសិក្សា ដែលមានស្រាប់នៅគ្រប់ខេត្ត ក្រុងទូទាំងប្រទេសកម្ពុជា (ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា, ២០០៣) ។

ស្របជាមួយគ្នានេះដែរ ធនធានគ្រូបង្រៀនគឺជា បញ្ហាសំខាន់បំផុតដែលទាមទារឱ្យគិតគូរជាចាំបាច់ ព្រោះដំណើរការងារអប់រំនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានរបស់គ្រូបង្រៀន។ ដោយមើលឃើញពីកង្វះខាតគ្រូបង្រៀននៅតាមថ្នាក់អនុវិទ្យាល័យតាមតំបន់ឆ្ងាយពីទីប្រជុំជន និងតំបនដាច់ស្រយាល ទើបនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសំណើសុំរាជរដ្ឋាភិបាល ដើម្បីរៀបចំវគ្គវិក្រឹតការគ្រូបឋមសិក្សាដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិរយៈពេល៣ខែ លើមុខវិជ្ជាចិត្ត-គរុកោសល្យ វិធីសាស្រ្តបង្រៀន និងមុខវិជ្ជាឯកទេស ក្រោយពេលបញ្ចប់វគ្គដោយជោគជ័យ គ្រូបឋមសិក្សាទាំងនេះត្រូវបានអនុញ្ញាតឱ្យស្នើសុំតែងតាំងជាគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយស្តីពីគ្រូបង្រៀន ដែលបានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដែលជាទស្សនទានថ្មីសម្រាប់អភិវឌ្ឍគ្រូបង្រៀនឈានទៅរក ការពង្រឹងគុណភាពនៃការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព។ ខាងក្រោមនេះជាស្ថានភាពបុគ្គលិកបង្រៀនតាមមុខវិជ្ជាជាលក្ខណៈរួមផ្អែកតាមចំនួនគ្រូដែលមាន និងកំពុងបង្រៀន និងចំនួនសិស្សនៅមធ្យមសិក្សា នៅឆ្នាំ២០១៨ ដោយឈរលើនិយាមសិស្ស 45នាក់/គ្រូ និងម៉ោងបង្រៀនតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី។

| មុខវិជ្ជា | គ្រូកម្រិតឧត្តម | គ្រូបឋមភូមិ | សរុប | តម្រូវការជាក់ស្តែង | លើស/ខ្វះ |
|---|---|---|---|---|---|
| គណិតវិទ្យា | 2018 | 6541 | 8559 | 6901 | 1658 |
| គីមីវិទ្យា | 1038 | 763 | 1801 | 2300 | -499 |
| ជីវវិទ្យា | 927 | 3210 | 4137 | 2300 | 1837 |
| រូបវិទ្យា | 1155 | 2898 | 4053 | 2300 | 1753 |

| | | | | | |
|---|---|---|---|---|---|
| ភាសាអង់គ្លេស | 865 | 3067 | 3932 | 4601 | -669 |
| ភាសាបារាំង | 115 | 615 | 730 | 2300 | -1570 |
| អក្សរសាស្ត្រខ្មែរ | 1913 | 8534 | 10447 | 6901 | 3546 |
| បច្ចេកវិទ្យា | 305 | 1112 | 1417 | 2300 | -883 |
| កសិកម្ម | 170 | 21 | 191 | 1150 | -959 |
| ផែនដី-បរិស្ថាន | 361 | 68 | 429 | 2300 | -1871 |
| កីឡា | 14 | 2044 | 2058 | 2300 | -242 |
| ប្រវត្តិវិទ្យា | 734 | 3120 | 3854 | 2300 | 1554 |
| ពលរដ្ឋ | 769 | 128 | 897 | 2300 | -1403 |
| សិល្បៈ | 51 | 775 | 826 | 1150 | -324 |
| សរុបរួម | 10435 | 32896 | 43331 | 41403 | 1928 |

តារាង២.៣៖ ស្ថានភាពបុគ្គលិកបង្រៀនតាមមុខវិជ្ជានៅមធ្យមសិក្សា នៅឆ្នាំ២០១៨( MoEYS, 2018 )

ធនធានមនុស្ស ជាកម្លាំងចលករក្នុងការប្រកួតប្រជែងផលិតផល និងសេវាកម្មក្នុងសម័យកាលរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការស្វែងរកឧត្តមភាពនៅលើពិភពលោក។ គ្រូបង្រៀនត្រូវបានគេទទួលស្គាល់ និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។ ទើបគោលនយោបាយស្តីពីគ្រូបង្រៀនបង្កើតចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម។ ហើយក៏មានបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

## ២.៩ ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ការបង្រៀន

ការបង្រៀន និងការសិក្សាដែលមានប្រសិទ្ធភាពតម្រូវឱ្យមានសម្ភារៈសិក្សាសមរម្យ និងសម្បូរបែប។ ស្ថានភាពទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ដែលក្នុងនោះមានដូចជា ការគិតគូរអំពីគោលនយោ

បាយគ្រប់គ្រងផលិកម្ម និងការបែងចែកសៀវភៅសិក្សារួមទាំងសម្ភារសិក្សាដទៃទៀត និងការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពី របៀបប្រើប្រាស់សម្ភារសិក្សាឱ្យមានប្រសិទ្ធភាពឱ្យស្របទៅតាមការអនុវត្តការបង្រៀនល្អ។ ជាញឹកញាប់កង្វះ សៀវភៅសិក្សាគឺជាលទ្ធផល នៃប្រព័ន្ធបែងចែក សៀវភៅគ្មានប្រសិទ្ធភាព សៀវភៅសិក្សាគោលគឺជាសៀវភៅ ដែលនិពន្ធចងក្រងឡើងស្របតាមកម្មវិធីសិក្សាជាតិ ដើម្បីជាជំនួយដល់ការរៀននិងបង្រៀន ដែលមានពីរប្រភេទគឺសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ។ ជាគោលការណ៍ការផ្គត់ផ្គង់សៀវភៅសិក្សាគោលសម្រាប់ពីថ្នាក់ទី១-៩ គឺ១/១ សៀវភៅមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់ សិស្សម្នាក់ និងសម្រាប់ពីថ្នាក់ទី១០-១២គឺ១/២ សៀវភៅមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់សិស្សពីរនាក់លើកលែងតំបន់ភូមិភាគឦសាន។នាយក/នាយិកាត្រូវត្រួតពិនិត្យនិងធ្វើតុល្យការសៀវភៅឱ្យបានទៀងទាត់ដើម្បី គ្រោងតម្រូវការសៀវភៅសិក្សា គោលប្រចាំឆ្នាំឱ្យត្រឹមត្រូវទាន់ពេល និងឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្ស។ បណ្ណារក្សត្រូវរាយការណ៍ជាប្រចាំជូននាយក/នាយិកាអំពីស្ថានភាពសៀវភៅអំពីការខូចខាត និងការបាត់បង់ដើម្បីរកវិធីដោះស្រាយបន្ទាន់ (ស្នើពីសាលាលើស សប្បុរសជន ថវិកាសាលា...) ចៀសវាងសិស្សខ្វះសៀវភៅប្រើប្រាស់ច្រើនពេក។ កង្វះសៀវភៅសិក្សាគោលដោយសារការបែងចែក ការប្រើប្រាស់នៅ មានចន្លោះប្រហោងទៅតាមតម្រូវការរបស់សាលារៀន អ្នកគ្រប់គ្រងខាងផ្នែកសៀវភៅសិក្សានៅតាមសាលា មានការផ្លាស់ប្តូរញឹកញាប់ ខ្វះការថែទាំទុកដាក់សៀវភៅ ពុំមានការពិនិត្យតាមដានពីសាលារៀនចំពោះការប្រើប្រាស់របស់សិស្ស។

## ២.១០ ការរៀបចំនូវកិច្ចតែងការបង្រៀន

តាមការស្រាវជ្រាវរបស់ NEP (2005)បានចង្អុលបង្ហាញថាគ្រូភាគច្រើនបានទទួលនូវការលើកទឹកចិត្តតិចតួច និងប្រាក់បៀវត្សរ៍មានកម្រិតទាប ដូចនេះពួកគាត់ក៏គ្មានជម្រើសក្រៅពីស្វែងរកមុខរបរទីពីក្នុងគោលបំណង បង្កើនប្រាក់ចំណូលចិញ្ចឹមគ្រួសារដែលជា ហេតុបណ្តាលឱ្យប្រសិទ្ធភាពក្នុងពេលបង្រៀននៅតែមានកម្រិត និងមានចន្លោះច្រើនក្នុងការរៀបចំកិច្ចតែងការបង្រៀន។ ការស្រាវជ្រាវបានបញ្ជាក់ទៀតថានៅ ប្រទេសកម្ពុជាគ្រូមធ្យមសិក្សាបឋមភូមិប្រមាណជា៣០% បាននិយាយថាពួកគាត់មកកាន់សាលារៀនកម្រនឹងរៀបចំប្លង់មេរៀនណាស់ ។ នៅតំបនដាច់ស្រយាលមានភាគរយកើនជាងនេះរហូតដល់ ៤៣%

នេះជា លទ្ធផលមួយដែលអ្នកអប់រំទាំងអស់មានក្ដីបារម្ភ និងត្រូវយកចិត្តទុកដាក់បំផុតលើការងាររៀបចំកិច្ចតែងការបង្រៀន សម្រាប់ជាគុណប្រយោជន៍ដល់ការបង្កើនប្រសិទ្ធភាពបង្រៀន និងសម្រេចវត្ថុបំណងរបស់មេរៀននីមួយៗដែលក្រសួងបានកំណត់។

តើគ្រូរៀបចំប្លង់មេរៀនសម្រាប់បង្រៀនបានកម្រិតណា?

| តំបន់ | ចំនួន/ ភាគរយ | ស្ទើតែគ្រប់ មេរៀន | ជាងពាក់ កណ្ដាលមេរៀន | តិចជាងពាក់ កណ្ដាល | ស្ទើរតែទាំង ស្រុងមិនមាន | សរុប |
|---|---|---|---|---|---|---|
| ប្រជាជន | ចំនួន | ៩០ | ៩០ | ២៧ | ៤ | ២១១ |
| | ភាគរយ | ៤៣.៧០ | ៤២.៧០ | ១២.៨០ | ១.៩០ | ១០០% |
| ជនបទ | ចំនួន | ៧៨ | ១១៤ | ៨០ | ១២ | ២៨៤ |
| | ភាគរយ | ២៧.៥០ | ៤០.១០ | ២៨.២០ | ៤.២០ | ១០០% |
| ដាច់ស្រយាល | ចំនួន | ១៤ | ៣៧ | ២១ | ៥ | ៧៧ |
| | ភាគរយ | ១៨.២០ | ៤៨.១០ | ២៧.៣០ | ៦.៥០ | ១០០% |
| សរុប | ចំនួន | ១៨២ | ២៤១ | ១២៨ | ២១ | ៥៧២ |
| | ភាគរយ | ៣១.៨០ | ៤២.១០ | ២២.៤០ | ៣.៧០ | ១០០% |

តារាង២.៤៖ ភាគរយនៃការទទួលខុសត្រូវលើការរៀបចំប្លង់មេរៀន(NEP, 2005)

ស្របពេលនេះដែរការស្រាវជ្រាវបានបង្ហាញ ឱ្យឃើញទៀតថាហេតុផលដែលជួនកាលពេលខ្លះគ្រូមិនបានរៀបចំប្លង់មេរៀនបានពេញលេញដូចមាននៅក្នុងតារាងខាងលើ បានបង្ហាញថាប្រមាណជាពាក់កណ្ដាលនៃគ្រូបង្រៀនបាននិយាយថាមកពីប្រាក់បៀវត្សរ៍តិចនិងជាប់រវល់ជាមួយការងារផ្ទះ។ ការទទួលបានប្រាក់បៀវត្សរ៍ទាបមានន័យថា លោកគ្រូ/អ្នកគ្រូគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំកិច្ចតែងការបង្រៀនពីព្រោះពួកគាត់មានការមមាញឹកនឹងការរកចំណូលជាមួយសកម្មភាពផ្សេងៗទៀត ក្រៅពីបង្រៀនមានកត្តាពីរយ៉ាងដែល ទាក់ទងជាមួយរឿងនេះ ទី១៖ ទម្រង់/លក្ខណៈនៃការរៀបចំកិច្ចតែងការបង្រៀនមានការពិបាកទី២៖ លោកគ្រូ អ្នកគ្រូប្រមាណជា១០%គាត់បានយល់ដឹងពីមេរៀនកាលពីពេលដែលពួក

គាត់នៅជាគរុសិស្សគរុនិស្សិត ហើយសម្រេចមិនត្រូវការរៀបចំប្លង់មេរៀន។

| ហេតុផល | ភាគរយ |
|---|---|
| ប្រាក់បៀវត្សរ៍ទាប | ៥៥.៦០ |
| រវល់ជាមួយការងារផ្ទះ | ៤៨.១០ |
| កម្រងនៃកិច្ចតែងការមិនច្បាស់ | ២៣.៤០ |
| គ្មានពេលវេលាគ្រប់គ្រាន់ | ១៨.១០ |
| ប្លង់មេរៀនមានការពិបាក | ១១.១០ |
| ចាំមេរៀនកាលពីឆ្នាំមុន | ៩.២០ |
| រវល់ជាមួយការរកចំណូលបន្ថែម | ៦.៤០ |
| រវល់ជាមួយការងារសាលាផ្សេង | ១.០០ |
| ខ្ជិលធ្វើ | ០.២០ |

រូបភាព២.១ ភាគរយនៃហេតុផលលោកគ្រូ/អ្នកគ្រូ មិនបានរៀបចំប្លង់មេរៀន( NEP, 2005 )

## ២.១១ ប្រសិទ្ធភាពនៃការប្រើប្រាស់ពេលម៉ោងបង្រៀន

ប្រទេសកម្ពុជាបានកំណត់គោលដៅសម្រាប់ការអប់រំទាំងអស់គ្នាឆ្នាំ២០១៥គឺ ធានាឱ្យកុមារកម្ពុជាយ៉ាងហោចណាស់ក៏ទទួលបានការអប់រំកម្រិតមូលដ្ឋាន។ ដើម្បីធានាសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នាវាមិនមែនជាបញ្ហាងាយស្រួលទេសម្រាប់ធ្វើឱ្យកុមារមកសាលារៀន ហើយវាក៏ជាបញ្ហាផងដែរក្នុងចំណាយពេលវេលាជាមួយនឹងការសិក្សាប្រកបដោយពេលបង្រៀនមានប្រសិទ្ធភាព។ ការសិក្សាក្នុងផ្នែកនេះសំដៅទៅលើប្រសិទ្ធភាពនៃពេលសម្រាប់បង្រៀន (១)ចំនួនពេលវេលានៃថ្នាក់រៀនគិតជាមធ្យមដែលគ្រូចំណាយពេលបង្រៀន សិស្សទទួលយកបានមានន័យសំដៅទៅលើទិដ្ឋភាពបរិមាណ (២) គុណភាពនៃការអប់រំ គឺអ្វីដែលកើតឡើងលើការបង្រៀនមានប្រសិទ្ធភាពក្នុងថ្នាក់រៀនសំដៅលើទិដ្ឋភាពគុណភាព ( NEP, 2005 )។

### ២.១១.១ ការអនុវត្តម៉ោងបង្រៀន

យោងតាមក្រសួងអប់រំ យុវជន និងកីឡា (MoEYS, 2008) បានរកឃើញថាមានកត្តាជាច្រើនដែលធ្វើឱ្យបាត់បង់ម៉ោងបង្រៀន និងរៀនមិនបាន ចប់កម្មវិធីសិក្សាដែលក្រសួងបានកំណត់។ តួយ៉ាងក្នុងចំណោម ២៧សាលា មាន៤៨% បាត់បង់ និង ៤៣%រៀនមិនចប់កម្មវិធីសិក្សាបណ្តាលមកពីបិទសាលារៀនមាន ពិធីបុណ្យផ្កា ពិធីប្រកួតកីឡាការយកសាលាធ្វើជាមណ្ឌលប្រឡង ការចូលរួមប្រជុំក្នុងពេលម៉ោងសិក្សា (ចំម៉ោងពួកគាត់ត្រូវបង្រៀន) ដោយគិត ចាប់ពី១ដង រហូតដល់៤ដងក្នុងមួយខែ។ ដូចនាពេលបច្ចុប្បន្នប្រទេសកម្ពុជាក៏បានរងផលប៉ះពាល់ពីជំងឺកូវីដ១៩ ធ្វើឱ្យក្រសួងបង្ខំចិត្តត្រូវបិទគ្រឹះស្ថានសិក្សាគ្រប់កម្រិតទូទាំងប្រទេសដោយឱ្យវិស្សមកាលតូចមុនកាលកំណត់ វាជាបញ្ហាប្រឈម ដែលគ្រូមិនបានបង្រៀនបញ្ចប់លើមុខវិជ្ជារបស់ខ្លួនដោយស្រួល។

កត្តាដែលបាត់បង់ម៉ោងបង្រៀន និងមិនចប់កម្មវិធីបណ្តាលមកពី

| ចម្លើយ | បិទសាលា | | បង្រៀនមិនគ្រប់ម៉ោង | | គ្រូអវត្តមាន | | គ្រូប្រជុំប្រចាំខែ | | កត្តាផ្សេងៗទៀត | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួននាយក | ភាគរយ | ចំនួនថ្នាក់ | ភាគរយ | ចំនួនគ្រូ | ភាគរយ | ចំនួនគ្រូ | ភាគរយ | ចំនួនសាលា | ភាគរយ |
| បាត់បង់ | ១៣ | ៤៨.១ | ៥០ | ៦៥.៨ | ១៣៣ | ៧៩.៦ | ៨៤ | ៥០.៣ | ២៧ | ១០០ |
| មិនបាត់បង់ | ១៤ | ៥១.៩ | ២៦ | ៣៤.២ | ៣៤ | ២០.៤ | ៨៣ | ៤៩.៧ | ០ | ០ |

តារាង២.៥ កត្តាដែលបណ្តាលឱ្យបាត់បង់ម៉ោងបង្រៀន និងរៀនមិនចប់កម្មវិធី(MoEYS, 2008)

បើយោងតាមការអង្កេតរបស់អង្គការយូនីសេហ្វ បានបញ្ជាក់ថាបើធៀបនឹងម៉ោងសិក្សាកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គ្រូម្នាក់ត្រូវបង្រៀនឱ្យបាន៦៨៤ ម៉ោងសិក្សា ស្មើនឹង៥៧០ម៉ោងក្នុងមួយឆ្នាំសិក្សាតែលទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថាម៉ោងបង្រៀនជាក់ស្តែងដែលគ្រូម្នាក់ៗ បានបង្រៀននៅសល់ត្រឹមតែ ៥៥៣ ម៉ោងសិក្សា ស្មើនឹង៤៦១ ម៉ោងប៉ុណ្ណោះជាហេតុធ្វើឱ្យអត្រាបាត់បង់មានរហូតដល់ ១៩.១៥% ស្មើនឹង ១៣១ម៉ោងសិក្សា ។ ជាមួយគ្នានេះដែរ បើប្រៀបធៀបចំនួនម៉ោងដែលត្រូវអនុវត្តនៃ

ព្រះរាជាណាចក្រកម្ពុជាទៅនឹងម៉ោងសិក្សាអន្តរជាតិឃើញថា ប្រទេសកម្ពុជាមានម៉ោងបង្រៀនប្រហាក់ប្រហែលនឹងម៉ោងសិក្សានៅបណ្តាប្រទេសផ្សេងទៀតផងដែរ។




រូបភាព២.២ ការប្រៀបធៀបម៉ោងបង្រៀនកម្ពុជា និងម៉ោងបង្រៀនអន្តរជាតិ (UNICEF, 2008)

### ២.១១.២ ផលប៉ះពាល់នៃការអវត្តមានរបស់គ្រូ

អវត្តមានញឹកញាប់របស់គ្រូដែលជាបញ្ហាកើតឡើងនៅក្នុងគ្រឹះស្ថានសិក្សាជាច្រើន នោះធ្វើឱ្យមានការធ្លាក់ចុះនូវគុណភាពអប់រំ បណ្តាលឱ្យមានការខាតបង់ធនធាន និងថវិកាជាតិផងដែរ។ កម្រិតអវត្តមានខ្ពស់របស់គ្រូ ជាទូទៅគូសបង្ហាញអំពីដំណើរការមិនល្អដ៏ធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធអប់រំ ប៉ុន្តែវាអាចនឹងមានបុព្វហេតុផ្ទាល់ខុសៗគ្នា បទដ្ឋានវិជ្ជាជីវៈធូរលុង និងកង្វះការជួយគាំទ្រ និងការត្រួតពិនិត្យពីសំណាក់អាជ្ញាធរអប់រំ គឺជា បញ្ហាចំបងនៅក្នុងប្រទេសជាច្រើន ភាពខ្វះចន្លោះនៅក្នុងគោលនយោបាយអប់រំក៏ដើរតួនាទីសំខាន់ផងដែរ គឺជាបញ្ហាចំបងនៅក្នុងប្រទេសទាំងមូល។

### ២.១១.៣ ការកំណត់និយាម

យោងតាមការសិក្សាស្រាវជ្រាវករណីការអនុវត្តម៉ោងបង្រៀន ក្នុងខេត្តកំពង់ស្ពឺ ព្រះវិហារ ក្រចេះ និងរាជធានីភ្នំពេញឆ្នាំ២០០៩ របស់ក្រសួងអប់រំ យុវជន និងកីឡាបានបង្ហាញថា តាមនិយាមគ្រូម្នាក់បង្រៀន ១៨ម៉ោងសិក្សាក្នុងមួយសប្តាហ៍ តែក្នុងករណីសិក្សានេះម៉ោងជាក់ស្តែងដែលគ្រូម្នាក់បង្រៀនគិតជាមធ្យមបានត្រឹមតែ ១៦ម៉ោងសិក្សាក្នុងមួយសប្តាហ៍ប៉ុណ្ណោះ។ តាមការស្រាវជ្រាវបានបញ្ជាក់ទៀតថាល្បាយម៉ោងបង្រៀនសម្រាប់គ្រូគោលដៅមុខវិជ្ជានីមួយៗមិនដូចគ្នាទេអាស្រ័យដោយទំហំសាលារៀន និង

តម្រូវការគ្រូធ្វើឱ្យគ្រូចំនួន ១១០នាក់ ស្មើនឹង ៦០% បង្រៀនក្រោមនិយាម ១៨ម៉ោងក្នុងមួយសប្តាហ៍ ហើយនឹងមានគ្រូចំនួន ៥៦នាក់ ស្មើនឹង៣០% បង្រៀនលើសនិយាម និងចំនួន ១៩នាក់ទៀត ស្មើនឹង ១០% ត្រឹមត្រូវតាមនិយាម។ ដូច្នេះ បើសិក្សាលើបីករណីគឺ ក្រោមនិយាម លើសនិយាម និងត្រឹមត្រូវតាមនិយាម ឃើញថាការបាត់បង់ម៉ោងបង្រៀនដោយសារការកំណត់និយាមបង្រៀន ជាមធ្យមបាត់អស់ប្រហែល ២ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ឬ៨៣ម៉ោងសិក្សាក្នុងមួយឆ្នាំសិក្សា។ ការអនុវត្តកម្មវិធីសិក្សាមិនបានពេញលេញនេះ មិនបានគិតទៅលើការបាត់បង់នៃការបិទសាលារៀន និងថ្ងៃបូកសរុបពិន្ទុប្រឡងឆមាសឡើយ។

## ២.១២ ក្របខណ្ឌវាយតម្លៃរបស់គណៈគ្រប់គ្រងសាលារៀន

ការវាយតម្លៃគឺ សំដៅរកព័ត៌មាន ឬភស្តុតាងដើម្បីសន្និដ្ឋានសម្រេចចិត្តរកវិធី និងផ្តល់ជាតុចូលជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងស្តង់ដាលទ្ធផលសិក្សា រំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ។ ការវាយតម្លៃនេះធ្វើឡើងក្នុងគោលបំណងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីសិក្សានៅក្នុងសាលារៀន ដែលត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនសម្រាប់បង្កើន គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា។ ក្នុងការប្រមូលព័ត៌មានមូលដ្ឋាន និងបទពិសោធន៍របស់គ្រូយកទៅវាស់ស្ទង់ប្រសិទ្ធភាពនៃការបង្រៀន និងកែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពបង្រៀន និង ការអនុវត្តកម្មវិធីសិក្សា។

ការវាយតម្លៃគ្រូបង្រៀនគឺ សំដៅលើការជួយគ្រូបង្រៀនតាមរយៈការសង្កេតថ្នាក់ និងសម្ភាសន៍ផ្ទាល់ជាមួយគ្រូបង្រៀនក្នុងគោលបំណងពិនិត្យមើលលើវិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើ។ ចំណុចដែលត្រូវធ្វើ អធិការកិច្ចមានដូចជា ការផ្តោតលើមុខវិជ្ជា មានន័យថាអធិការម្នាក់ពិនិត្យមើលគ្រូបង្រៀនមុខវិជ្ជាគីមីវិទ្យា ហើយអធិការម្នាក់ទៀតពិនិត្យមើលគ្រូបង្រៀនគណិតវិទ្យាជាដើម ការផ្តោតលើឥរិយាបថគ្រូបង្រៀនប្រើប្រាស់សៀវភៅសិក្សា និងសម្ភារឧបទេសការផ្តោតលើសមត្ថភាពរបស់គ្រូបង្រៀន។ បន្ទាប់ពីការធ្វើអធិការកិច្ចគ្រូ បង្រៀនម្នាក់ៗនឹងទទួលបាននូវព័ត៌មានត្រឡប់មកវិញទាក់ទងនឹងការបំពេញការងាររបស់ខ្លួនព្រមទាំងអនុសាសន៍សម្រាប់ធ្វើការកែលម្អផងដែរ។ ដូច្នេះហើយទើប ទាមទារអោយមានការធ្វើការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំនៅតាមគ្រឹះស្ថានសិក្សា។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ" មានគោលបំណងសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺ អនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ ២ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សីគ្នាជាមួយសំណួរស្រាវជ្រាវទាំងបី នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅមធ្យមសិក្សាបឋមភូមិចំនួន ៤ អនុវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន ២ប្រភេទ គឺគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

## ៣.២ ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ១៩ គ្រូបង្រៀនតាមសាលារដ្ឋ បានចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សឱ្យរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វដអ.ផក ចុះថ្ងៃពុធ ១០រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE Google Form) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំនួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំនួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាត ជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរ ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ដោយមានកំណត់ពេលវេលាជាក់លាក់។ ការចុះប្រមូលទិន្នន័យ គឺមានភាពបត់បែនទៅតាមទីតាំងភូមិសាស្ត្ររបស់សាលារៀន និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានា៖ Google form, តេលេក្រាម, ទូរស័ព្ទ និង Facebook ជាដើម។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរ មានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតប ទៅតាមពេលកំណត់ជាក់លាក់។ ក្នុងអន្តរកាលនៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេស បណ្តាញទំនាក់ទំនងសង្គម និងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូលទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំនួរទាំងអស់ពី គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវត្រូវបានបង្កើតឡើងតាមរយៈគោលនយោបាយស្តីពីគ្រូបង្រៀន ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្របខណ្ឌធានាគុណភាពអប់រំ ទ្រឹស្តីពាក់ព័ន្ធលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ទ្រឹស្តីពីបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីសិក្សា ព្រមទាំងអត្ថបទមួយចំនួនទៀតរួមមាន តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ កម្មវិធីសិក្សាស្តីពីការអប់រំពលរដ្ឋពេញលេញ និងការឆ្លងយោបល់សម្រេចពីគ្រូដឹកនាំបង្គោល ដើម្បីប្រើប្រាស់សូចនាករនៅក្នុងកម្រងសំណួរប្រកបដោយសង្គត់ភាព។ ដើម្បីឆ្លើយតបទៅនឹងការកសាងកម្រងសំណួរទាំង២ប្រភេទខាងលើ ព្រមទាំងទទួលបានទិន្នន័យជាក់លាក់ឆ្លើយតបទៅនឹងប្រធានបទ គោលបំណង និងសំណួរស្រាវជ្រាវ។

ការសិក្សាស្រាវជ្រាវលើប្រធានៈ ឥរិយាបថឆ្លើយតបរបស់គ្រូបង្រៀនទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ អ្នកសិក្សាស្រាវជ្រាវ ប្រើប្រាស់កម្រងសំណួរចំនួន ២ប្រភេទក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានា ដែលមានដូចជាៈ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា ការអនុវត្តកម្មវិធីនៅមធ្យមសិក្សាបឋមភូមិ បញ្ហាប្រឈមការអនុវត្តកម្មវិធីសិក្សា តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន គោលនយោបាយស្តីពីគ្រូបង្រៀនជាដើម ដើម្បីសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំនួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោមៈ

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត-ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

### ៣.៣.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ ដំណើរការបង្រៀន និងរៀន។ ទិន្នន័យដែលប្រមូលបានគឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។

#### ៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាបឋមភូមិ

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង ដែលចែកចេញជា ២ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៦សំណួរ ទាក់ទងទៅនឹងតួនាទី កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ។

**ផ្នែកទី២៖ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់គ្រូបង្រៀន**

មានសមាសភាគចំនួន២គឺ កសាងសមត្ថភាពគ្រូ (១១សំណួរ) និងធានាគុណភាពអប់រំ (៧សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃឥរិយាបថរបស់ថ្នាក់ដឹកនាំនិងគ្រប់គ្រងសាលារៀន ដែលអាចឆ្លុះបញ្ចាំងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គណៈគ្រប់គ្រងនៅផ្នែកទី២ ស្តីពី "តើលោក-លោកស្រី មានជួបប្រទះការលំបាកអ្វីខ្លះក្នុងការអនុវត្តកម្មវិធីសិក្សា?" និង "ពេលជួបការលំបាកខាងលើ តើលោក-លោកស្រី បានដោះស្រាយបញ្ហាទាំងយ៉ាងដូចម្តេចខ្លះ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**៣.៣.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន**

កម្រងសំនួរគ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនផ្នែកមធ្យមសិក្សាបឋមភូមិដែលកំពុងបង្រៀនពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ដែលចែកចេញជា ៤ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

មាន៧សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅមធ្យមសិក្សាបឋមភូមិ កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស និងបង្រៀនថ្នាក់ទីប៉ុន្មាន។

**ផ្នែកទី២៖ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់គ្រូបង្រៀន**

មានសមាសភាគចំនួន៣ គឺឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូ (១៣សំណួរ) ការអនុវត្តកម្មវិធីសិក្សា (៨សំណួរ) ដំណើរការសិក្សារបស់សិស្ស (៩សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពងស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់លោកគ្រូ-អ្នកគ្រូនៅផ្នែកទី២ ស្តីពី "ការអនុវត្តកម្មវិធីសិក្សា ការរៀបចំសម្ភារៈឧបទ្ទេសសម្រាប់បង្រៀន ការគ្រប់គ្រងថ្នាក់រៀន និងឥរិយាបថសិក្សារបស់សិស្ស" ដើម្បីឱ្យការចុះ

ប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៣៖ បញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សា**

មានសមាសភាគចំនួន១ គឺកត្តាគ្រូ (១០សំណួរ) ជាឧបករណ៍សម្រាប់រកឱ្យឃើញនូវបញ្ហាប្រឈម ដែលរាំងស្ទះដល់ដំណើរការបង្រៀនរបស់គ្រូ ប៉ះពាល់ដល់ការអនុវត្តកម្មវិធីសិក្សាពុំទាន់តាមកាលកំណត់ និងប្រសិទ្ធភាពក្នុងការសិក្សារបស់សិស្ស។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី៣ ស្តីពី "តើមានចំនុចខុសគ្នាអ្វីខ្លះទៀត ដែលលោកគ្រូ អ្នកគ្រូជួបប្រទះក្នុងពេលបង្រៀន?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៤៖ ការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់ក្នុងការអនុវត្តកម្មវិធីសិក្សា**

មានសមាសភាគចំនួន១ គឺកត្តាគ្រូ (១១សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំពីការចុះពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ ក្នុងការអនុវត្តតាមកម្មវិធីសិក្សាលើដំណើរការបង្រៀនរបស់គ្រូ គឺជាយន្តការដើម្បីពង្រឹងការធានាគុណភាព ឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងរដ្ឋាភិបាល ក្នុងវិស័យអប់រំ លើសមត្ថភាព ចំណេះដឹង និងជំនាញរបស់សិស្សានុសិស្សដែលជាកម្លាំងពលកម្មបម្រើដល់វិស័យសេដ្ឋកិច្ច ក៏ដូចជាសង្គមជាតិ ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី៤ ស្តីពី "តើគណៈគ្រប់គ្រង និងប្រធានមុខវិជ្ជា មានផ្តល់យោបល់កែលម្អលើវិធីសាស្រ្តបង្រៀនដល់លោកគ្រូ អ្នកគ្រូអ្វីខ្លះ? និង តើមានចំណុចខ្វះខាតអ្វីខ្លះទៀត ដែលលោកគ្រូ អ្នកគ្រូធ្លាប់បានទទួល?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងចំនួន៤ មធ្យមសិក្សាបឋមភូមិ នៅខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប ៦១នាក់ លោកគ្រូ អ្នកគ្រូ ចំនួន៥២នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន៩នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ឋិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺកូវីដ១៩

។ អនុវិទ្យាល័យមួយចំនួននៅក្នុងខេត្តកំពង់ស្ពឺ មានស្ថានភាពទីតាំងភូមិសាស្ត្រខុសគ្នា ទៅតាមក្រុង ស្រុកនីមួយៗ ដោយអនុវិទ្យាល័យបិតក្នុងក្រុងមានភាពរីកចម្រើន អនុវិទ្យាល័យខ្លះមានកម្រិតមធ្យម ហើយក៏មានអនុវិទ្យាល័យខ្លះទៀតស្ថិតនៅក្នុងតំបន់ជួបការលំបាក។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន ២ ក្នុងខេត្តកំពង់ស្ពឺ គឺ៖ ក្រុងច្បារមន និងស្រុកភ្នំស្រួច។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរនៅមធ្យមសិក្សាបឋមភូមិចំនួន៤ មានសំណាកសរុបចំនួន ៦១នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងសាលារៀនចំនួន៩នាក់ និងគ្រូបង្រៀនបឋមភូមិចំនួន៥២នាក់។

| ល.រ | ឈ្មោះស្រុក | ចំនួនសំណាកគណៈគ្រប់គ្រង | ចំនួនសំណាកគ្រូបង្រៀន |
|---|---|---|---|
| ១ | ក្រុងច្បារមន | ៦ | ៣០ |
| ២ | ស្រុកភ្នំស្រួច | ៣ | ២២ |
| **សរុប** | | **៩** | **៥២** |

តារាង ៣.១៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដារ ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ការវិភាគលើមតិយោបល់បន្ថែម គឺអ្នកសិក្សាបានចាប់ក្រុមពាក្យទៅតាមទស្សនៈយល់ឃើញនីមួយៗ ពីការបំពេញកម្រងសំណួរអាចធ្វើការឆ្លុះបញ្ចាំងទៅ និងមធ្យមភាគដែលទទួលបាន ព្រមទាំងស្រង់ធាតុចូលមួយចំនួនពីអ្នកឆ្លើយតប ដាក់ក្នុងសំណូមពរ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសន៍លើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន គណៈគ្រប់គ្រងសាលា និងលោកគ្រូ-អ្នកគ្រូ។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺនាពេលកន្លងមកត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា។

## ៤.១ ទិន្នន័យពីព័ត៌មានទូទៅរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកសាលាចំនួន ៤ ក្នុងក្រុង/ស្រុក ចំនួន ៨ ក្នុងខេត្តកំពង់ស្ពឺ ជាគោលដៅនៃការសិក្សាស្រាវជ្រាវដោយ ១ ក្រុង/ស្រុកយកសាលាចំនួន ២ ដែលចែកជាពីរតំបន់ គឺ ក្រុងច្បារមនចំនួន២ មធ្យមសិក្សាបឋមភូមិ ជាតំបន់ធម្មតា និងស្រុកភ្នំស្រួចចំនួន២ មធ្យមសិក្សាបឋមភូមិ ជាតំបន់ជួបការលំបាក។ យោងលិខិតលេខៈ ២៦០៣ អយក.ប្រក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ប្រកាសស្តីពីការកំណត់អង្គភាព និងសាលារៀនស្ថិតក្នុងតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

### ៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

តាមរយៈទិន្នន័យទទួលបានពីគ្រូបង្រៀនលើព័ត៌មានទូទៅ ក្នុងឧបសម្ព័ន្ធ "ខ" បង្ហាញថាគ្រូបង្រៀនភាគច្រើន គឺបង្រៀនថ្នាក់ទី៨ ហើយក្រៅពីនេះបង្រៀនថ្នាក់ទី៧ និងទី៩ ដែលមានចំនួន ៥០% ជាភេទប្រុសក្នុងចំនួនសរុប៥២នាក់ ក្រៅពីនេះជាគ្រូដែលមានភេទស្រី។ ក្នុងនោះដែរ ភាគច្រើនមានអាយុលើសពី ៣៥ឆ្នាំ និងភាគតិចមានអាយុចន្លោះពី ២៤ ដល់ ២៩ឆ្នាំ ក្រៅពីនេះគឺអាយុចន្លោះពី ៣០ ដល់ ៣៥ឆ្នាំ ចំពោះសញ្ញាបត្របរិញ្ញាបត្រមានភាគច្រើន ហើយសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានភាគតិចក្រៅពីនេះគឺគ្រូបង្រៀនដែលមានសញ្ញាបត្រចប់ត្រឹមថ្នាក់ទី១២ ចំណែកឯបទពិសោធន៍បង្រៀនវិញ ភាគច្រើនគឺលើសពី ១៥ឆ្នាំ មានចំនួន ៥៩.៦២% នៃចំនួនសរុប ៥២នាក់ ហើយភាគតិចគឺ ចន្លោះពី១ ដល់ ៥ឆ្នាំ ក្រៅពីនេះគឺ

គ្រូដែលមានបទពិសោធន៍បង្រៀនចន្លោះពី ៦ ដល់ ១៥ ឆ្នាំ។ ក្នុងនោះភាគច្រើនជាមុខវិជ្ជាឯកទេសផ្នែកវិទ្យាសាស្ត្រ មានចំនួន ៣០.៧៧% នៃចំនួនសរុប ៥២នាក់ និងភាគតិចមានមុខវិជ្ជាឯកទេសភាសាបរទេស និងគណិតវិទ្យា ក្រៅពីនេះ គឺគ្រូបង្រៀនដែលមានមុខវិជ្ជាឯកទេសភាសាខ្មែរ និងសិក្សាសង្គម។

#### ៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង

តាមរយៈទិន្នន័យទទួលបានពីគណៈគ្រប់គ្រងលើព័ត៌មានទូទៅ ក្នុងឧបសម្ព័ន្ធ "ឃ" បង្ហាញថាគណៈគ្រប់គ្រងចំនួន ៧៧.៧៨% ជាភេទប្រុសនៃចំនួនសរុប ៩នាក់ ក្រៅពីនេះជាភេទស្រី ហើយភាគច្រើនមានអាយុលើសពី ៤០ឆ្នាំ និងអាយុចន្លោះពី ៣១ ដល់ ៤០ឆ្នាំមានភាគតិច។ ក្នុងនោះដែរ ភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ ឯសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានភាគតិច ក្រៅពីនេះគឺគណៈគ្រប់គ្រងដែលមានសញ្ញាបត្រចប់ត្រឹមថ្នាក់ទី១២។ ចំពោះបទពិសោធន៍បង្រៀនវិញ ភាគច្រើនសុទ្ធតែមានបទពិសោធន៍បង្រៀនយូរឆ្នាំ ក្នុងនោះលើសពី ១៥ឆ្នាំ មានចំនួន ៨៨.៨៩% នៃចំនួនសរុប ៩នាក់ និងមានបទពិសោធន៍បង្រៀនភាគតិច គឺចន្លោះពី១១ ដល់ ១៥ឆ្នាំ។

## ៤.២ ទិន្នន័យពីការឆ្លើយតបរបស់គ្រូ លើឥរិយាបថឆ្លើយតប ក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ

#### ៤.២.១ ទិន្នន័យឆ្លើយតបរបស់គ្រូលើ ឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សា

ឥរិយាបថរបស់គ្រូក្នុងការអនុវត្តកម្មវិធីសិក្សាគឺជា បញ្ហាសំខាន់ណាស់ដើម្បីជម្រុញឱ្យមានប្រសិទ្ធភាពនៅក្នុងការបង្រៀន និងរៀនរបស់សិស្ស។ ព្រោះឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សារបស់គ្រូផ្តើមចេញពីដំណើរការបង្រៀន និងការអនុវត្តកម្មវិធីសិក្សារបស់ទៅកាន់សិស្ស ករណីដែលការបង្រៀនបានល្អធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាបានល្អ នោះនាំឱ្យដំណើរនៃការសិក្សារបស់សិស្សមានភាពល្អប្រសើរផងដែរ។

តារាង៤.១៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើឥរិយាបថ ក្នុងការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មានទស្សនៈវិស័យ និងគោលដៅសំខាន់ៗក្នុងការបង្រៀន | 4.25 | 0.44 | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| ២ | មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន (ការគោរពម៉ោងពេលចេញ ចូល) | 4.35 | 0.48 | ល្អណាស់ |
| ៣ | មានស្មារតី និងភាពជឿជាក់លើការបង្រៀន ដើម្បីការអប់រំមានគុណភាព និងប្រសិទ្ធភាពខ្ពស់ | 4.29 | 0.46 | ល្អណាស់ |
| ៤ | បង្រៀនតាមកិច្ចតែងការដែលបានរៀបចំ | 4.29 | 0.50 | ល្អណាស់ |
| ៥ | មានលំហាត់ ឬលើកឧទាហរណ៍ ក្នុងការពន្យល់ និងបំណកស្រាយ | 4.13 | 0.40 | ល្អ |
| ៦ | បានរៀបចំសម្ភារៈឧទ្ទេសដែលឆ្លើយតបនឹងខ្លឹមសារមេរៀន | 4.15 | 0.46 | ល្អ |
| ៧ | មានឆន្ទៈចូលរួមប្រជុំបច្ចេកទេសជាប្រចាំ | 4.27 | 0.45 | ល្អណាស់ |
| ៨ | បានរៀបចំផែនការបង្រៀនជាប្រចាំ (សប្តាហ៍ ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ) | 4.35 | 0.52 | ល្អណាស់ |
| ៩ | ការបង្រៀន មានភាពជាប់ពាក់ពន្ធគ្នាពីមួយមេរៀនទៅមួយមេរៀន | 4.04 | 0.66 | ល្អ |
| ១០ | សំឡេងគ្រូច្បាស់ៗទៅកាន់សិស្សនៅពេលបង្រៀនខ្លឹមសារមេរៀន | 4.27 | 0.49 | ល្អណាស់ |
| ១១ | មានស្មារតីសហការចូលរួមធ្វើការជាក្រុម | 4.13 | 0.34 | ល្អ |
| ១២ | បានទទួលការបំប៉នសមត្ថភាពលើកម្មវិធីសិក្សា | 3.79 | 0.85 | ល្អ |
| ១៣ | ការសម្រេចចិត្ត ដោយផ្អែកលើភស្តុតាងជាក់ស្តែងច្បាស់លាស់ | 4.02 | 0.37 | ល្អ |
| **សរុប** | | **4.18** | **0.49** | **ល្អ** |

តារាងខាងលើបានបង្ហាញពីមធ្យមភាគ ដែលបង្ហាញពីឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.១៨ )។ សូចនាករ "គ្រូមានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន( ការគោរពម៉ោងពេលចេញ ចូល)" និងសូចនាករ "បានរៀបចំផែនការបង្រៀនជាប្រចាំ (សប្តាហ៍ ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ)" ទទួលបាន

ការយល់ស្របខ្ពស់ជាងគេ ទៅលើឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ=៤.៣៥) ហើយសូចនាករ "បានទទួលការបំប៉នសមត្ថភាពលើកម្មវិធីសិក្សា" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៣.៧៩ )។

តារាង៤.២៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បង្រៀនចប់ខ្លឹមសារមេរៀនតាមកម្មវិធីសិក្សា | 4.23 | 0.55 | ល្អណាស់ |
| ២ | មានវិធីសាស្ត្រថ្មីត្រឹមត្រូវតាមគរុកោសល្យ ក្នុងការបង្រៀនសិស្ស | 4.13 | 0.53 | ល្អ |
| ៣ | បានរៀបចំ និងអនុវត្តតាមកាលវិភាគបង្រៀនយ៉ាងត្រឹមត្រូវ | 4.23 | 0.43 | ល្អណាស់ |
| ៤ | បានធ្វើថ្នាក់និទស្សន៍ ដើម្បីចែករំលែកបទពិសោធន៍ | 4.04 | 0.52 | ល្អ |
| ៥ | បង្រៀនតាមកាលវិភាគ និងម៉ោងកំណត់ | 4.29 | 0.50 | ល្អណាស់ |
| ៦ | ការគ្រប់គ្រងថ្នាក់រៀន | 4.12 | 0.38 | ល្អ |
| ៧ | បានស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន | 4.08 | 0.48 | ល្អ |
| ៨ | បានអនុវត្តតាមកម្មវិធីសិក្សា និងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ | 4.27 | 0.49 | ល្អណាស់ |
| **សរុប** | | **4.17** | **0.48** | **ល្អ** |

តារាងខាងលើបង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីបទពិសោធន៍នៃការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.១៧ )។ សូចនាករ "បង្រៀនតាមកាលវិភាគ និងម៉ោងកំណត់" ទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ=៤.២៩) ទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូអ្នកគ្រូ និងសូចនាករ "បានធ្វើថ្នាក់និទស្សន៍ ដើម្បីចែករំលែកបទពិសោធន៍" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.០៤)។

តារាង៤.៣៖ ទិន្នន័យការឆ្លើយតបរបស់គ្រូបង្រៀនលើដំណើរការសិក្សារបស់សិស្ស

| ល.រ | បរិយាយ | មធ្យម ភាគ | គម្លាត ស្តង់ដា | កម្រិតចង្អុល បង្ហាញ |
|---|---|---|---|---|
| ១ | ការឆ្លើយតប និងបកស្រាយចម្ងល់សិស្ស បានក្បោះក្បាយ | 4.17 | 0.47 | ល្អ |
| ២ | បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | 4.33 | 0.47 | ល្អណាស់ |
| ៣ | មានចំណាប់អារម្មណ៍លើសិស្សគ្រប់រូប | 4.02 | 0.31 | ល្អ |
| ៤ | ទាញចំណាប់អារម្មណ៍សិស្ស ផ្តោតលើមេរៀន ពេលសិស្សបាត់បម្រុងប្រយ័ត្ន | 4.13 | 0.63 | ល្អ |
| ៥ | តាមរយៈការប្រឡង បង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន | 4.00 | 0.40 | ល្អ |
| ៦ | គ្រូ និងសិស្ស មានទំនាក់ទំនងល្អក្នុងដំណើរការបង្រៀន | 4.17 | 0.51 | ល្អ |
| ៧ | ផ្តល់ការការណែនាំដល់សិស្សឡើងវិញពេលគ្រូសង្កេតឃើញសិស្សមិនចូលរួម | 4.12 | 0.58 | ល្អ |
| ៨ | បានបង្កើតបរិយាកាសរៀនសូត្រ ដែលផ្តល់ការលើកទឹកចិត្តដល់សិស្សក្នុងថ្នាក់រៀន | 4.17 | 0.38 | ល្អ |
| ៩ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | 4.17 | 0.43 | ល្អ |
| **សរុប** | | **4.14** | **0.47** | **ល្អ** |

តារាងខាងលើបង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីដំណើរការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៤.១៤)។ សូចនាករ "បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សារបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ= ៤.៣៣) និងសូចនាករ "តាមរយៈការប្រឡង បង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.០០ )។

តារាង៤.៤៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនទៅលើឥរិយាបថឆ្លើយតប ក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ក | ឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូ | 4.18 | 0.49 | ល្អ |
| ខ | ការអនុវត្តកម្មវិធី | 4.17 | 0.48 | ល្អ |
| គ | ដំណើរការសិក្សារបស់សិស្ស | 4.14 | 0.47 | ល្អ |
| **សរុប** | | **4.16** | **0.48** | **ល្អ** |

តាមតារាងទិន្នន័យ៤.៤ខាងលើ បានបង្ហាញថាឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.១៦)។ សូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ"(មធ្យមភាគ=៤.១៨)គឺ "ឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូ" ហើយសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.១៤)គឺ "ដំណើរការសិក្សារបស់សិស្ស"។

**៤.២.២ ទិន្នន័យឆ្លើយតបរបស់គណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបការអនុវត្តកម្មវិធីសិក្សារបស់គ្រូ**

ការឆ្លើយតបរបស់គណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ គឺមានសារៈសំខាន់ណាស់ក្នុងការឆ្លុះបញ្ចាំងពីដំណើរការនៃការបង្រៀន និងរៀន ក៏ដូចជាប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ។

តារាង៤.៥៖ទិន្នន័យការឆ្លើយតបរបស់គណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបរបស់គ្រូក្នុងការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | គ្រូបង្រៀន មានទស្សនៈវិស័យក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន | 4.56 | 0.53 | ល្អណាស់ |
| ២ | គ្រូបង្រៀន មានឆន្ទៈចូលរួមប្រជុំបច្ចេកទេសជាប្រចាំ | 4.22 | 0.44 | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| ៣ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើមុខវិជ្ជាកំពុងបង្រៀន | 4.22 | 0.44 | ល្អណាស់ |
| ៤ | គ្រូបង្រៀន បានបង្រៀនមេរៀន ស្របតាមកម្មវិធីសិក្សា | 4.44 | 0.53 | ល្អណាស់ |
| ៥ | គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់ | 4.67 | 0.50 | ល្អណាស់ |
| ៦ | គ្រូបង្រៀន មានស្មារតីសហការចូលរួមធ្វើការជាក្រុម | 4.11 | 0.33 | ល្អ |
| ៧ | គ្រូបង្រៀន មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន | 4.11 | 0.33 | ល្អ |
| ៨ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន( ការគោរពម៉ោងពេលចេញ ចូល) | 4.22 | 0.44 | ល្អណាស់ |
| ៩ | គ្រូបង្រៀនមានស្មារតី និងភាពជឿជាក់លើការបង្រៀន ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ | 4.22 | 0.44 | ល្អណាស់ |
| ១០ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | 4.00 | 0.00 | ល្អ |
| ១១ | គណៈគ្រប់គ្រង បានផ្តល់មតិយោបល់ កែលម្អ ក្នុងការធ្វើថ្នាក់និទស្សន៍របស់គ្រូបង្រៀន | 4.22 | 0.67 | ល្អណាស់ |
| ១២ | គណៈគ្រប់គ្រង បានជួយគាំទ្រលើកទឹកចិត្តក្នុងការបំពេញការងារ ដល់បុគ្គលិកក្នុងអង្គភាព | 4.33 | 0.50 | ល្អណាស់ |
| ១៣ | គណៈគ្រប់គ្រង បានពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូ ជាប្រចាំ | 4.33 | 0.50 | ល្អណាស់ |
| ១៤ | គណៈគ្រប់គ្រង បានផ្តល់វគ្គបំប៉នសមត្ថភាព ដល់គ្រូបង្រៀនលើការអនុវត្តកម្មវិធីសិក្សា | 3.78 | 0.83 | ល្អ |
| ១៥ | គណៈគ្រប់គ្រងបានចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាល ទៅដល់លោកគ្រូ-អ្នកគ្រូផ្សេងទៀត | 4.00 | 0.00 | ល្អ |
| ១៦ | សហគមន៍បានចូលរួម ជាមួយសាលារៀនលើការសិក្សារបស់សិស្ស | 4.00 | 0.00 | ល្អ |
| ១៧ | ជារួម លោកគ្រូ-អ្នកគ្រូ គឺមានការពេញចិត្ត និងភាពច្បាស់លាស់ ទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ | 4.00 | 0.00 | ល្អ |
| **សរុប** | | **4.20** | **0.38** | **ល្អ** |

តារាងខាងលើ បានបង្ហាញពីមធ្យមភាគទៅលើការយល់ឃើញរបស់គណៈគ្រប់គ្រងដែលឆ្លុះបញ្ចាំង

ការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.២០)។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ=៤.៦៧) គឺ "គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សាច្បាស់លាស់" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៣.៧៨ )គឺ "គណៈគ្រប់គ្រង បានផ្តល់វគ្គបំប៉នសមត្ថភាពដល់គ្រូបង្រៀនលើការអនុវត្តកម្មវិធីសិក្សា"។

## ៤.៣ លទ្ធផលសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងលើឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ

ការអនុវត្តកម្មវិធីសិក្សា គឺសំខាន់ណាស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀន ពីព្រោះគ្រូបានដើរតួនាទីយ៉ាងសំខាន់ក្នុងសាលារៀន គ្រូជាអ្នកអនុវត្តគោលការណ៍ និងវិន័យក្នុងសាលារៀន ហើយឥរិយាបថក្នុងការ អនុវត្តកម្មវិធីសិក្សារបស់គ្រូក៏បានឆ្លុះបញ្ចាំងដល់ប្រព័ន្ធប្រតិបត្តិសាលារៀន លើសពីនេះគ្រូបង្រៀន គឺជាអ្នកនាំមុខក្នុងការផ្តល់សេវាបង្រៀន គាំពារការសិក្សារបស់សិស្ស ចែករំលែកចំណេះដឹង បទពិសោធន៍ជាមួយសិស្ស និងសហការីយ៉ាងស័ក្តិសិទ្ធិ។ ក្នុងន័យនេះ ការចែករំលែកពីឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូគឺពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីសិក្សាក៏ដូចជាការពង្រឹងលទ្ធផលសិក្សារបស់សិស្ស ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ។

តារាង៤.៦៖ទិន្នន័យសរុបលើការឆ្លើយតបរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាទៅលើឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបលើការឆ្លើយតបរបស់គ្រូបង្រៀន | 4.16 | 0.48 | ល្អ |
| ២ | ទិន្នន័យសរុបលើការឆ្លើយតបរបស់គណៈគ្រប់គ្រង | 4.20 | 0.38 | ល្អ |
| **សរុប** | | **4.18** | **0.43** | **ល្អ** |

យោងតាមទិន្នន័យនេះ បង្ហាញថាគ្រូបង្រៀន និងគណៈគ្រប់គ្រង បានឆ្លើយតបទៅលើឥរិយាបថ

របស់លោកគ្រូ-អ្នកគ្រូក្នុងការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ ក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.១៨)។

កម្មវិធីសិក្សា គឺផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនរួមមាន គោលបំណង ខ្លឹមសារមេរៀន លទ្ធផលសិក្សារបស់សិស្ស (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) ម៉ោងសិក្សា វិធីសាស្ត្របង្រៀន ការវាយតម្លៃ (កម្មវិធីសិក្សាលម្អិត, ២០១៨)។ ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា គឺឈរលើដំណើរការបង្រៀនរបស់គ្រូ អោយស្របទៅតាមកម្មវិធីសិក្សាដែលបានកំណត់ ដោយសំដៅដល់ការយកចិត្តទុកដាក់របស់គ្រូក្នុងការបង្រៀន តាមវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ លើសពីនេះប្រសិទ្ធភាពនៃដំណើរការបង្រៀនបានល្អ គឺមានឥទ្ធិពលដល់ភាពប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្ស។ ចំណេះដឹងសមត្ថភាព បំណិនបង្រៀន និងការប្តេជ្ញាចិត្តលើមុខវិជ្ជាបង្រៀនរបស់គ្រូបង្រៀន មានឥទ្ធិពលជាវិជ្ជមានទៅលើដំណើរការបង្រៀន និងការរៀនរបស់សិស្ស(Steward, 2009 & Zepeda, 2012)។ ហើយមានការទទួលស្គាល់ជាទូទៅថា គុណភាពសិក្សារបស់សិស្ស អាស្រ័យយ៉ាងខ្លាំងលើគុណភាពរបស់គ្រូបង្រៀន ក្នុងនោះដែរលោក Darling-Hammond(2006) បានលើកឡើងនៅក្នុងទស្សនាវដ្តីស្តីពីការអប់រំគ្រូបង្រៀននៅសតវត្សរ៍ទី២១ថា ក្នុងចំណោមធនធានអប់រំទាំងអស់ សមត្ថភាពគ្រូបង្រៀន ជាចំណែកដ៏សំខាន់បំផុតដែលនាំមកនូវជោគជ័យក្នុងការសិក្សារបស់សិស្ស។ គ្រូដែលមានគុណភាពខ្ពស់ ពូកែបង្រៀនសិស្សឱ្យទទួលបានចំណេះដឹង និងបំណិនចាំបាច់ និងព្រមទាំងបណ្តុះឥរិយាបថថ្លៃថ្នូរ (Klecka, Odell, Houston, & McBee, 2009) រីឯដំណើរការបង្កើតចំណេះដឹងទាំងនេះតម្រូវឱ្យមានការអនុវត្ត និងការបង្ហាត់បង្រៀនដែលមានការគាំពារ (Darling-Hammond, 2014)។ នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស(២០១៦) របស់ក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា គ្រូនៅមធ្យមសិក្សាបឋមភូមិ បានអនុវត្តការបង្រៀនស្របតាមកម្មវិធីសិក្សាបានល្អ នោះធ្វើឱ្យសិស្សទទួលបានចំណេះដឹង និងសមត្ថភាពពេញលេញក្នុងការសិក្សារៀនសូត្រ។ កម្មវិធីសិក្សា ជាផ្នែកមួយដ៏ចាំបាច់បំផុតសម្រាប់ការបង្រៀនរបស់គ្រូ ក្នុងការអនុវត្តចំណេះដឹង និងបទពិសោធន៍ដែលមានឡើង ដោយមានវិធីសាស្ត្រថ្មីៗត្រឹមត្រូវស្របតាមគរុកោសល្យក្នុងការបង្រៀនសិស្ស ជួយឱ្យការបង្រៀនចប់ខ្លឹមសារមេរៀន

តាមកម្មវិធីសិក្សា នឹងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ សម្រួលដល់ការរៀបចំ និងអនុវត្តតាមកាលវិភាគបង្រៀន ម៉ោងកំណត់យ៉ាងត្រឹមត្រូវ ការគ្រប់គ្រងថ្នាក់ប្រកបដោយប្រសិទ្ធភាព ផ្តល់ភាពងាយស្រួលដល់ការស្រាវជ្រាវបន្ថែមលើចំណេះដឹងជំនាញវិជ្ជាជីវៈរបស់គ្រូមុនបង្រៀន។ លើសពីនេះការអនុវត្តកម្មវិធីបានត្រឹមត្រូវគឺសំដៅដល់ការអភិវឌ្ឍសិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ទុក សម្រាប់ប្រកបកិច្ចការរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សា ស្របតាមចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សា គឺជានាអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទាកាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។ យោងតាមមហាសន្និបាតអប់រំ(២០០៩) បានបង្ហាញថា "ការបង្រៀន និងរៀននៅតាមសាលាប្រកបដោយគុណភាព និងប្រសិទ្ធភាពបានលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សា" នៅក្នុងន័យនេះសកម្មភាពរបស់គ្រូក្នុងការអនុវត្តកម្មវិធីសិក្សា គឺឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការបំពេញការងារ ឆ្លើយតបទៅលើក្របខណ្ឌកម្មវិធីសិក្សាឥរិយាបថរបស់គ្រូ សំដៅលើសកម្មភាព ឬការអនុវត្តកម្មវិធីសិក្សាដែលបានបង្ហាញតាមរយៈដំណើរការបង្រៀនរបស់គ្រូ។ ក្នុងន័យនេះ ដំណើរការបង្រៀនរបស់គ្រូបានល្អ នាំឱ្យការអនុវត្តកម្មវិធីសិក្សាទទួលបានប្រសិទ្ធភាពខ្ពស់ ធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រកប ដោយសមត្ថភាពនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងបន្តការសិក្សាទៅភូមិសិក្សាទុតិយភូមិ ឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ និងបំពេញទៅតាមតម្រូវការទីផ្សារការងារប្រកួតប្រជែង ក្នុងសតវត្សរ៍ទី២១ ដែលត្រូវការមូលធនមនុស្សដែលមានសមត្ថភាពចំណេះជំនាញច្បាស់លាស់។

ទន្ទឹមនឹងឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សាបានល្អតាមរយៈទិន្នន័យដែលបានឆ្លើយតបដោយគ្រូបង្រៀន បង្ហាញឱ្យឃើញថា ដំណើរការសិក្សារបស់សិស្សនៅមានចំណុចអវិជ្ជមាន ដែលទាមទារឱ្យមានការបំពេញបន្ថែម ដើម្បីឱ្យដំណើរការបង្រៀន និងការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាពកាន់តែប្រសើរឡើង នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ការងាយយល់ទៅលើខ្លឹមសារមេរៀនរបស់សិស្សសំខាន់ណាស់ ក្នុងការជួយសម្រួលដល់ដំណើរការបង្រៀន ក៏ដូចជាការផ្ទេរចំណេះដឹងពីគ្រូទៅសិស្ស ព្រមទាំង

ជួយដល់ការអនុវត្តកម្មវិធីសិក្សារបស់គ្រូតាមមុខវិជ្ជានីមួយៗ នៅក្នុងថ្នាក់រៀន។ ការដែលសិស្សពុំយល់លើខ្លឹមសារមេរៀនបង្កឱ្យសិស្សមានភាពធុញទ្រាន់ក្នុងម៉ោងសិក្សា ក៏បណ្តាលឱ្យការបង្រៀនរបស់គ្រូពុំមានប្រសិទ្ធភាព ចំណែកឯការអនុវត្តកម្មវិធីសិក្សាក៏ពុំចប់តាមកាលកំណត់ ដែលទាមទារឱ្យគ្រូត្រូវបន្តលើកកម្ពស់បន្ថែម ក្នុងដំណើរការសិក្សារបស់សិស្ស ឱ្យមានការយល់បន្ថែមទៅលើខ្លឹមសារមេរៀន គឺត្រូវពង្រឹងទៅលើការងាយយល់លើខ្លឹមសារមេរៀន និងត្រូវមានចំណាប់អារម្មណ៍លើសិស្សគ្រប់រូបនៅពេលបង្រៀនដោយសារសិស្សមួយចំនួននូវពុំទាន់យល់លើខ្លឹមសារមេរៀនបានស៊ីជម្រៅនៅឡើយ ទាមទារឱ្យគ្រូត្រូវផ្តោតយ៉ាងខ្លាំងទៅលើការសិក្សា អារម្មណ៍ ឥរិយាបថ និងការចូលរួមសកម្មភាព ផ្សេងៗរបស់សិស្សនៅក្នុងថ្នាក់។ តាមរយៈគោលការណ៍នៃការបង្រៀនទាំង៤ គឺគោលការណ៍ទី១ ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដោយប្រើប្រាស់វិធីសាស្ត្រគោលវិធីសិស្សមជ្ឈមណ្ឌល។ គោលការណ៍ទី២ ការបង្រៀនគឺជាសកម្មភាពជួយ និងលើកទឹកចិត្តសិស្សឱ្យចេះរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្មមានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃដោយប្រើប្រាស់វិធីសាស្ត្រទំនើបដូចជាសហការ អង្កេត។ គោលការណ៍ទី៣ ការបង្រៀនត្រូវបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណងចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សា។ គោលការណ៍ទី៤ ការបង្រៀនត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីវិទ្យាសាស្ត្រ សម្ភារៈឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព។ លើសពីនេះ គ្រូបង្រៀនត្រូវបន្តលើកកម្ពស់អភិវឌ្ឍវិជ្ជាជីវៈ ដើម្បីឱ្យឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សារបស់ខ្លួនមានភាពល្អប្រសើរគឺ សំដៅទៅលើដំណើរការ និងសកម្មភាព ដែលបង្កើតឡើងដើម្បីពង្រឹងចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ សម្រាប់អ្នកអប់រំ ក៏ដើម្បីបង្រៀនសិស្សកាន់តែមានភាពល្អប្រសើរឡើង ការពិតគ្រូបង្រៀនដែលមានសមត្ថភាព ពិតជាបានជួយវិភាគទានក្នុងការបង្រៀនសិស្ស និងលើកស្ទួយកម្រិតគុណភាពអប់រំ (Phin, 2014)។

ដូច្នេះ ដំណើរការសិក្សារបស់សិស្សសំខាន់ណាស់ពីព្រោះវាឋិតក្នុងដំណើរការនៃការផ្ទេរចំណេះដឹង

ពីគ្រូទៅដល់សិស្ស បើសិនជាដំណើរការនៃការអប់រំនេះទទួលបានជោគជ័យ ឬពុំជោគជ័យ គឺអាស្រ័យលើការសិក្សារបស់សិស្ស ប្រសិនបើសិស្សទទួលបានដំណើរការសិក្សាពុំបានល្អនោះទេ ឆ្លុះបញ្ចាំងឱ្យឃើញថាដំណើរការនៃការបង្រៀន ឥរិយាបថ ឬក៏សកម្មភាពនៃការអនុវត្តកម្មវិធីសិក្សាក៏ពុំបានល្អនោះដែរ។ ហេតុនេះទើបឥរិយាបថរបស់គ្រូពិតជាសំខាន់ណាស់ក្នុងតួនាទីអភិវឌ្ឍកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ព្រោះ បើឥរិយាបថគ្រូក្នុងការអនុវត្តកម្មវិធីសិក្សាមិនបានត្រឹមត្រូវនោះទេ ធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមិនទទួលបានជោគជ័យ ហើយក៏ធ្វើឱ្យប្រសិទ្ធិភាពនៃការអប់រំ និងប្រព័ន្ធប្រតិបត្តិការសាលារៀនពុំបានល្អប្រសើរផងដែរ លើសពីនោះក៏មានផលប៉ះពាល់ខ្លាំងដល់គុណភាពមូលធនមនុស្សដែលត្រូវបម្រើដល់កម្លាំងពលកម្មផ្នែកសេដ្ឋកិច្ច ស្របតាមតម្រូវការទីផ្សារដែលជាដំណើរឆ្ពោះទៅសង្គមពុទ្ធិ បដិវត្តន៍ឧស្សាហកម្មទី៤ និងពលរដ្ឋសកល។

សរុបសេចក្ដីមក បើទោះបីជាការអនុវត្តកម្មវិធីសិក្សាបានល្អយ៉ាងណាក៏ដោយ ក៏ត្រូវតែលើកកម្ពស់ដំណើរការបង្រៀនជាប្រចាំ ពីព្រោះដំណើរការបង្រៀនរបស់គ្រូ គឺមានសារៈសំខាន់ណាស់ក្នុងការប្រតិបត្តិប្រចាំថ្ងៃដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាចាំបាច់ពីគ្រូគ្រប់ពេលវេលា។ ព្រោះការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននឹងស្តែងឱ្យឃើញ ពីឥរិយាបថឆ្លើយតបក្នុងការអនុវត្តកម្មវិធីសិក្សាក្នុងការបង្រៀន បើឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូបានល្អ នោះធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សក៏ទទួលបានលទ្ធផលល្អ ដែលប្រកបដោយសមត្ថភាព គុណភាព និងប្រសិទ្ធភាពខ្ពស់នៅកម្រិតមធ្យមសិក្សាបឋមភូមិដែលជាមូលដ្ឋានគ្រឹះនៃចំណេះដឹង ដើម្បីបន្តទៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងស្របតាមតម្រូវការសង្គមនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែ បើឥរិយាបថអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនពុំបានល្អនោះនឹងធ្វើឱ្យជះឥទ្ធិពលដល់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិផ្ទាល់ ព្រមទាំងមធ្យមសិក្សាទុតិយភូមិ លើសពីនេះនឹងប៉ះពាល់ដល់កំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ដែលទាមទារឱ្យមានកម្លាំងពលកម្មប្រកបដោយគុណសម្បទាកម្រិតខ្ពស់ រួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយា

សម្បទាដែលឆ្លើយតបទៅនឹងទីផ្សារការងារក្នុងសតវត្សរ៍ទី២១។ ទើបនៅក្នុងកំណែទម្រង់ក្រសួងអប់រំយុវជន និងកីឡា បានផ្តោតសំខាន់លើកំណែទម្រង់គុណភាពរបស់គ្រូ និងកំណែទម្រង់លើកម្មវិធីសិក្សាគ្រប់ភូមិ ដើម្បីឱ្យសិស្សទទួលបានលទ្ធផលនៃការសិក្សាល្អប្រសើរឆ្លើយតបទៅលើតម្រូវការសង្គមជាតិ ដែលបាន បង្កើតឱ្យមានកម្មវិធីអប់រំពេលរដ្ឋពេញលេញ ពោលគឺ គុណភាពរបស់គ្រូដែលអាចបង្ហាញថាល្អ ឬមិនល្អ អាស្រ័យលើគ្រូមានចំណុចគោលមួយដែលតម្រូវឱ្យអនុវត្តតាមនោះគឺកម្មវិធីសិក្សាអប់រំពេលរដ្ឋពេញលេញ។ ក្នុងករណីដែល គ្រូគាត់មានឥរិយាបថអវិជ្ជមានទៅលើការអនុវត្តកម្មវិធីសិក្សា នោះលទ្ធផលសិក្សារបស់ សិស្សក៏ពុំបានល្អដែរ ក្នុងករណីការសិក្សារបស់សិស្សមិនបានល្អ នោះកំណែទម្រង់នៅក្នុងវិស័យអប់រំជាច់ ខាតនៅតែត្រូវបន្តទៀត។

**សំណើសុំផ្សេងៗ ពីគណៈគ្រប់គ្រង និងគ្រូបង្រៀន៖**

- ផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈដល់គ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាអប់រំពេលរដ្ឋពេញលេញ។
- បន្តយន្តការចុះជួយ និងកែលម្អលើការបង្រៀន និងរៀនរបស់គ្រូបង្រៀន ដើម្បីបំពេញបន្ថែមលើចំណុចខ្វះខាត់ និងផ្តល់បទពិសោធន៍ថ្មីៗ។

## ៤.៤ ទិន្នន័យឆ្លើយតបរបស់គ្រូនៅលើបញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សា

ការអនុវត្តកម្មវិធីសិក្សា គឺ សំខាន់ណាស់ក្នុងការ អនុវត្តចំណេះដឹង និងបទពិសោធន៍ដែលមាន ដើម្បីអភិវឌ្ឍដល់ការសិក្សារបស់សិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ ទុក។ កម្មវិធីសិក្សា ផ្តោតទៅលើខ្លឹមសារ ម៉ោងសិក្សា វិធីសាស្ត្រ និងការវាយតម្លៃ។ ក្នុងន័យនេះ ការចែក រំលែកពីបញ្ហាប្រឈមរបស់លោកគ្រូ-អ្នកគ្រូ ក្នុងការអនុវត្តកម្មវិធីសិក្សាគឺ ពិតជាបានចូលរួមចំណែកយ៉ាង សំខាន់ក្នុងការអនុវត្តកម្មវិធីសិក្សា ក៏ដូចជាការពង្រឹងលទ្ធផលសិក្សារបស់សិស្ស ដើម្បីឆ្លើយតបទៅនឹង កំណែទម្រង់វិស័យអប់រំផងដែរ។

តារាង៤.៧៖ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យម ភាគ | គម្លាត ស្តង់ដា | កម្រិតចង្អុល បង្ហាញ |
|---|---|---|---|---|
| ១ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជានីមួយៗ | 4.02 | 0.61 | ល្អ |
| ២ | ផ្តល់សៀវភៅពុម្ពសម្រាប់គ្រូ អោយបានគ្រប់គ្រាន់ | 4.13 | 0.82 | ល្អ |
| ៣ | មានវគ្គបំប៉នដល់គ្រូ លើការអនុវត្តកម្មវិធីសិក្សា | 3.42 | 0.85 | ល្អ |
| ៤ | បានរៀបចំ ការបណ្តុះបណ្តាលនៃវិធីសាស្ត្របង្រៀនថ្មី | 3.65 | 0.76 | ល្អ |
| ៥ | ជម្រុញសកម្មភាពសិស្ស ក្នុងការសិក្សា និងមករៀនទៀងទាត់ | 4.10 | 0.50 | ល្អ |
| ៦ | បានពង្រឹងការផ្សព្វផ្សាយពីគោលនយោបាយអប់រំ ពាក់ព័ន្ធគ្រូបង្រៀន អោយដល់ថ្នាក់ក្រោមជាតិ សាលារៀន | 3.81 | 0.49 | ល្អ |
| ៧ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់គ្រូ ផលិតសម្ភារៈឧបទេស | 3.96 | 0.66 | ល្អ |
| ៨ | គ្រូបង្រៀនទទួល បានការលើកទឹកចិត្តគ្រូពីសហគមន៍ | 3.75 | 0.71 | ល្អ |
| ៩ | មានការទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ | 4.23 | 0.55 | ល្អណាស់ |
| ១០ | គ្រូបង្រៀនបានសម្តែងការពេញចិត្តនៅពេលអ្នកដទៃបង្ហាញពីចំណុចខ្វះខាត និងចំណុចដែលត្រូវកែលម្អ | 4.08 | 0.52 | ល្អ |
| **សរុប** | | **3.92** | **0.65** | **ល្អ** |

តាមតារាង៤.៧ខាងលើ បានបង្ហាញថាមធ្យមភាគនៃបញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៩២)។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ= ៤.២៣) គឺ "មានការទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ"។ សូចនាករទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៣.៤២) គឺ "មានវគ្គ

បំប៉នដល់គ្រូ លើការអនុវត្តកម្មវិធីសិក្សា” ។

តាមរយៈលទ្ធផលនៃការពិភាក្សា លើឥរិយាបថឆ្លើយតបរបស់គ្រូបង្រៀន ទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ បានបង្ហាញថាគ្រូបង្រៀនមានឥរិយាបថក្នុងកម្រិតល្អឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ការអនុវត្តដំណើរការបង្រៀនរបស់គ្រូបង្រៀន តាមកម្មវិធីសិក្សាពិតជាមានសារៈសំខាន់ណាស់ នៅមធ្យមសិក្សាបឋមភូមិ សំដៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់រៀននីមួយៗ និងមុខវិជ្ជាវិទ្យាសាស្ត្រពិត ក៏ដូចជាមុខវិជ្ជាវិទ្យាសាស្ត្រ សង្គម។ លើសពីនេះយោងតាមទិន្នន័យខាងលើ បង្ហាញឱ្យឃើញថាគ្រូបង្រៀនបានយកចិត្តទុកដាក់លើការអនុវត្តកម្មវិធីសិក្សា ដោយអនុវត្តស្របតាមវិជ្ជាជីវៈលើដំណើរការបង្រៀនសិស្ស និងការពិនិត្យតាមដានលើក្របខណ្ឌគុណភាពនៃការសិក្សា។ កម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺមានភាពចាំបាច់ណាស់សម្រាប់គ្រូក្នុងដំណើរការបង្រៀនគ្រប់មុខវិជ្ជា ព្រោះថាការពុំមានកម្មវិធីសិក្សា បានធ្វើឱ្យការបង្រៀនរបស់គ្រូជួបនូវឧបសគ្គក្នុងការធ្វើបាយម៉ោងមុខវិជ្ជានីមួយៗ បច្ចេកទេសក្នុងការបង្រៀន ឬវិធីសាស្ត្របង្រៀន និងការប្រើប្រាស់សម្ភារឧបទេស នឹងធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្ស ក៏ដូចជាគុណភាពអប់រំ។ លោកReeves (2004) បានសន្និដ្ឋានថាអថេរសំខាន់បំផុតដែលប៉ះពាល់ដល់សមិទ្ធិផលសិស្សគឺជាគុណភាពនៃការបង្រៀន លោកបានបញ្ជាក់ថាគុណភាពរបស់គ្រូគឺស្ទើរតែសំខាន់ទ្វេដងជាងរាល់អថេរដទៃទៀត ក្នុងនោះដែរគ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគុណភាពសាលារៀនដោយសារតែពួកគាត់គឺជាកម្លាំងស្នូលដែលមានភារៈបំពេញមុខងារជាច្រើន ដូចជា ការបង្រៀន ការស្រាវជ្រាវ និងការផ្ដល់សេវាសហគមន៍ (Zepeda, 2012)។

គ្រូនៅមធ្យមសិក្សាបឋមភូមិ មានការទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ បានធ្វើឱ្យការបង្រៀន និងរៀនគុណភាព និងបានធ្វើឱ្យសិស្សទទួលបានចំណេះដឹង សមត្ថភាពពេញលេញក្នុងការសិក្សារៀន ងាយស្រួលក្នុងការទទួលបានចំណេះដឹងពីគ្រូ។ ការទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់គ្រូពិតជាសំខាន់ណាស់ ព្រោះគ្រូជាវិស្វករព្រលឹង នោះការអប់រំប្រកបដោយគុណភាពខ្ពស់ទាមទារឱ្យគ្រូបង្រៀនមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្រប

តាមក្រមសីលធម៌វិជ្ជាជីវៈ ស្តង់ដាវិជ្ជាជីវៈ ដើម្បីទទួលបានលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរ ដែលជាមូលធនធានមនុស្សចាំបាច់របស់ប្រទេសជាតិ។ គ្រូបង្រៀនត្រូវមានចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណៈសម្បត្តិដែលជាតម្រូវការចាំបាច់ស្របតាមការប្រែប្រួលទៅតាមតម្រូវការ ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យានៃសង្គមពុទ្ធិ (គោលនយោបាយស្តីពីគ្រូបង្រៀន, ២០១៣)។ ដូច្នេះគ្រូត្រូវមានទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវរួមទាំងចំណេះដឹង និងបំណិនថ្មីៗ លើមុខវិជ្ជាឯកទេសរបស់ខ្លួន ក្នុងនោះមានការរៀបចំកម្មវិធីសិក្សា គរុកោសល្យ ការវាយតម្លៃផ្អែកលើលទ្ធផល និងការស្រាវជ្រាវឱ្យទាន់តាមសម័យកាល ម្យ៉ាងវិញទៀត គុណភាពអប់រំអាស្រ័យយ៉ាងខ្លាំងលើសមត្ថភាព និងគុណផលការងាររបស់គ្រូ (Steward, 2009)។ ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូ គឺសំដៅដល់បទពិសោធន៍អប់រំ ពាក់ព័ន្ធនឹងកិច្ចការរបស់បុគ្គលណាម្នាក់ ហើយដែលគេបានរៀបចំឡើងដើម្បីកែលម្អកិច្ចប្រតិបត្តិ និងលទ្ធផលសិក្សារបស់សិស្ស (Patton, Parker, & Tannehill, 2015) ក្នុងន័យនេះគ្រូត្រូវផ្លាស់ប្តូរទម្លាប់បង្រៀន និងទម្លាប់រៀនសូត្រក្នុងសាលា។

តាមរយៈទិន្នន័យដែលបានឆ្លើយតបដោយគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ បង្ហាញឱ្យឃើញថាការអនុវត្តកម្មវិធីសិក្សា នៅមានចំណុចខ្វះខាត ដែលទាមទារឱ្យមានការបំពេញបន្ថែម ដើម្បីប្រសិទ្ធភាពក្នុងដំណើរការបង្រៀន និងការអនុវត្តកម្មវិធីសិក្សា នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ការមានវគ្គបំប៉នដល់គ្រូ លើការអនុវត្តកម្មវិធីសិក្សាគឺមានភាពចាំបាច់ណាស់ សម្រាប់ការបង្រៀន ព្រោះវគ្គបំប៉នលើការអនុវត្តកម្មវិធីសិក្សា បានជួយលើកកម្ពស់សមត្ថភាព ព្រមទាំងជួយពង្រឹងដល់ការប្រើប្រាស់វិធីសាស្ត្រថ្មីៗ បច្ចេកទេសបង្រៀនដើម្បីសម្រួលដល់ការបញ្ជាបចំណេះដឹងពីគ្រូដល់សិស្ស បានជួយដល់ដំណើរការប្រព្រឹត្តទៅនៃការអនុវត្តវិធីសាស្ត្របង្រៀនរបស់គ្រូដែលបានចូលរួមចែករំលែកក្នុងវគ្គបំប៉ន និងទទួលបានបទពិសោធន៍នៃការអនុវត្តកម្មវិធីសិក្សាពីគ្រូដែលជាសិក្ខាម។ Frey (2001) បានពិពណ៌នាអំពីបញ្ហាប្រឈមដែលជាទូទៅជានីតិវិធី គឺត្រូវតែមានដើម្បីធានាថាគ្រូមានការគាំទ្រក្នុងការអនុវត្តកម្មវិធីសិក្សា គ្រូក៏ត្រូវការឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈដែលកំពុងបន្តផងដែរ ដើម្បីឱ្យពួកគាត់ចេះប្រើប្រាស់កម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព ដូច្នេះគ្រូបង្រៀនត្រូវត្រៀមខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្ស។

ការបំប៉នសមត្ថភាពគ្រូពុំគ្រប់គ្រាន់ បានធ្វើឱ្យគ្រូមានសមត្ថភាពមិនពេញលេញក្នុងការអភិវឌ្ឍខ្លួនតាមបរិបទនៃការអប់រំសម័យថ្មី វិធីសាស្រ្តនៃការបង្រៀនមានភាពចាស់កម្រិល ដែលមិនសមស្របតាមក្របខណ្ឌកម្មវិធីសិក្សាសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។ ការសិក្សាផ្សេងមួយទៀតដោយ (Ros & Oleksiyenko, 2017) បានរកឃើញថា ស្ថាប័នគ្រប់គ្រងគ្មានធនធានគ្រប់គ្រង និងទឹកចិត្តក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដល់បុគ្គលិក។ ហើយក៏មានកត្តាប្រាំមួយ ដែលមានឥទ្ធិពលលើភាពជោគជ័យនៃសមាហរណកម្មបច្ចេកវិទ្យាៈ កង្វះធនធាន កង្វះខាតចំណេះដឹង និងជំនាញច្បាស់លាស់ រចនាសម្ព័ន្ធស្ថាប័ន ឥរិយាបថគ្រូ និងជំនឿទៅលើបច្ចេកវិទ្យា ប្រភេទនៃការវាយតម្លៃ និងវប្បធម៌មុខវិជ្ជានីមួយៗ (Hew, 2007)។ លើសពីនេះកម្មវិធីសិក្សា ក៏ជាកត្តាដ៏សំខាន់មួយដែលវា ជាការផ្សំឡើងនូវបទពិសោធទាំងឡាយដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ(Caswell & Campbell, 1935 )។ កម្មវិធីសិក្សា មុខវិជ្ជាសិក្សាសង្គម បច្ចុប្បន្នបានបណ្តុះកុមារកម្ពុជា ឱ្យមានសមត្ថភាពចងចាំ តាមរយៈកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលដោយផ្តោតលើខ្លឹមសារ នាំឱ្យកុមារកម្ពុជាភាគច្រើនទទួលបានត្រឹមតែវិជ្ជាសម្បទា។ ដោយហេតុនេះហើយ ធ្វើឱ្យគ្រូបង្រៀនភាគច្រើន អនុវត្តកម្មវិធី ផ្តោតទៅលើវិធីសាស្រ្តបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល។ តាមរយៈកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាដែលសម្បូរបែបទៅដោយខ្លឹមសារ បានធ្វើឱ្យកុមារដែលបញ្ចប់ការសិក្សាតាមភូមិសិក្សានីមួយៗ ប្រឈមនឹងបញ្ហាជាច្រើនដូចជា គ្រូបង្រៀនភាគច្រើន ប្រើប្រាស់វិធីសាស្រ្តបង្រៀនតាមបែបឧទ្ទេស (គ្រូមជ្ឈមណ្ឌល) សកម្មភាពរៀនសូត្ររបស់សិស្សភាគច្រើនមានតែនៅក្នុងថ្នាក់រៀន សកម្មភាពរៀន និងបង្រៀន មិនមានអន្តរកម្មរវាងសិស្ស និងសិស្ស និងរវាងគ្រូនិងសិស្ស ដើម្បីជំរុញការរៀនសូត្រ ចំណេះដឹង បំណិនដែលសិស្សទទួលបានមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្រ្ត មិនបានបណ្តុះស្មារតីឱ្យមានភាពក្លាហាន និងគំនិតសិក្សាស្រាវជ្រាវ ដំណើរការតាមដានលើការអនុវត្តកម្មវិធីសិក្សាលើមុខវិជ្ជាសង្គមនៅមានកម្រិត (ឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល, ២០២០)

ឆ្លើយតបទៅលើបញ្ហាប្រឈមខាងលើទាមទារឱ្យគ្រូស្គាល់ពី តួនាទី កាតព្វ ក្រមសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀនដែលជាអ្នកអប់រំ ក៏ជាគំរូល្អក្នុងសង្គម លើសពីនេះជាអ្នកបណ្តុះមូលធនមនុស្សប្រកបដោយ

គុណភាព និងប្រសិទ្ធភាព ព្រោះឥរិយាបថនៃការអប់រំរបស់គ្រូនៅក្នុងគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅគឺជារឿងចាំបាច់បំផុតទាមទារឱ្យគ្រូត្រូវតែបន្តការអភិវឌ្ឍវិជ្ជាជីវៈស្របតាមស្តង់ដារគ្រូបង្រៀនសតវត្សរ៍ទី២១។ ព្រមទាំងត្រូវចូលរួមគ្រប់សកម្មភាព និងការផ្លាស់ប្តូរបទពិសោធន៍ពីគ្រូដ៏ទៃផ្សេងទៀតក្នុងសាលារបស់ខ្លួនជាប្រចាំ ដើម្បីឱ្យប្រព័ន្ធប្រតិបត្តិសាលារៀនមានដំណើរការល្អ។ លើសពីនេះក៏ធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាពឆ្លើយតបទៅនិងកំណែទម្រង់វិស័យអប់រំ ដែលផ្តោតលើការពង្រឹងគុណភាពអប់រំ និងការអភិវឌ្ឍកម្មវិធីសិក្សាថ្មី។

សរុបសេចក្តីមក គ្រូជាកត្តាលីករ ជាមគ្គុទេសន៍ ជាអ្នកលើកស្ទួយ និងពង្រឹងភាពច្នៃប្រឌិតរបស់សិស្ស ស្វ័យសិក្សាដោយខ្លួនឯង និងតាមដានភាពរីកចម្រើនរបស់សិស្ស។ ហើយបើគ្រូខ្លួនឯងពុំមានទំនួលខុសត្រូវលើតួនាទី ភារកិច្ច កាតព្វកិច្ចរបស់ខ្លួនទេនោះ វានឹងបង្កើតឱ្យមានបញ្ហាប្រឈមទៅលើគុណភាពនៃការបង្រៀន ក៏ដូចជាការអនុវត្តកម្មវិធីសិក្សា និងមិនអាចផ្តល់ឱ្យសិស្សគ្រប់គ្នាទទួលបាននូវចំណេះដឹងដែលជាតម្រូវការ ឬបំណិនកំណត់នៅក្នុងកម្មវិធីសិក្សា។ ជាហេតុទាមទារឱ្យការបណ្តុះបណ្តាលទាំងសមត្ថភា ចំណេះដឹង បច្ចេកទេស និងវិធីសាស្ត្របង្រៀនថ្មីដែលបានបញ្ចូលក្នុងប្រព័ន្ធអប់រំ និងក្នុងកម្មវិធីសិក្សាថ្មីលើសពីនេះគ្រូខ្លួនឯងត្រូវពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈបន្ថែមជានិរន្តរ៍។

**សំណើសុំផ្សេងៗពីគណៈគ្រប់គ្រង និងគ្រូបង្រៀន**

- ផ្តល់ការចូលរួមដល់គ្រូបង្រៀនក្នុងការកែសម្រួលលើសៀវភៅសិក្សាគោលនូវចំណុចខុស ឬខ្វះខាត់ ព្រមទាំងធ្វើការផ្គត់ផ្គង់សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូឱ្យបានគ្រប់គ្រាន់ ទាន់ពេលវេលា។
- ផ្តល់បន្ទប់សម្រាប់ពិសោធន៍ និងសម្ភារៈពិសោធន៍ឱ្យស្របតាមតម្រូវការមេរៀន ដើម្បីឱ្យសិស្សអនុវត្តលើមេរៀនជាក់ស្តែង។

## ៤.៥ ទិន្នន័យឆ្លើយតបរបស់គ្រូបង្រៀនលើការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងក្នុងការអនុវត្តកម្មវិធីសិក្សា

ការចុះពិនិត្យតាមដាន និងវាយតម្លៃគឺ សំខាន់ណាស់ដើម្បីជួយជានាដល់ការលូតលាស់វិជ្ជាជីវៈរបស់គ្រូបង្រៀន ឬមានន័យថាសង្កេត និងរៀនអំពីវឌ្ឍនភាពនៃការបង្រៀន ការជួយបង្កើនបំណិន និងចំណេះដឹងរបស់គ្រូនៅក្នុងសាលារៀន។ ការវាយតម្លៃការរៀន និងបង្រៀន ជាដំណើរការជានិរន្តរ៍មួយសម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងកស្តុតាងអំពីកម្រិតសមត្ថភាពសិស្ស ក្រោយពីដំណើរការរៀន និងបង្រៀនទាំងក្នុងថ្នាក់ទាំងក្រៅថ្នាក់ ឱ្យឆ្លើយតបតាមលទ្ធភាពដែលបានរំពឹងទុកក្នុងកម្មវិធីសិក្សាជាតិ ការវាយតម្លៃមានលក្ខណៈវិនិច្ឆ័យ ឱ្យសមស្របទៅនិងកម្រិតលទ្ធផលសិក្សានៃកម្រិតថ្នាក់នីមួយៗ។

តារាង៤.៨៖ ទិន្នន័យឆ្លើយតបរបស់គ្រូលើការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សា

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បានរៀបចំការធ្វើផែនការមេរៀន លើលទ្ធផលរំពឹងទុក | 4.00 | 0.28 | ល្អ |
| ២ | មានកិច្ចតែងការបង្រៀន មុនដំណើរការថ្នាក់រៀនចាប់ផ្តើម | 4.33 | 0.47 | ល្អណាស់ |
| ៣ | មានសមត្ថភាពវិជ្ជាជីវៈ លើជំនាញច្បាស់លាស់ | 4.25 | 0.44 | ល្អណាស់ |
| ៤ | មានភាពបត់បែន ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន | 4.10 | 0.36 | ល្អ |
| ៥ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស | 4.02 | 0.37 | ល្អ |
| ៦ | មានកំណត់ហេតុ ស្តីពីសិស្សរៀនយឺតក្នុងថ្នាក់ | 3.88 | 0.43 | ល្អ |
| ៧ | បានបង្រៀនមេរៀន តាមមុខវិជ្ជាឯកទេសទាន់កម្មវិធីសិក្សា | 4.08 | 0.59 | ល្អ |
| ៨ | បានគោរពភារកិច្ចតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលារៀន | 4.19 | 0.40 | ល្អ |
| ៩ | មានទំនាក់ទំនងល្អ ជាមួយសហគមន៍សាលារៀន | 3.98 | 0.50 | ល្អ |

| | | | | |
|---|---|---|---|---|
| ១០ | មានគ្រប់កំណត់ហេតុ ក្នុងសៀវភៅកិច្ចការគ្រូ | 4.02 | 0.61 | ល្អ |
| ១១ | បានទទួល ការណែនាំលើដំណើរការបង្រៀនពីគណៈគ្រប់គ្រង | 4.12 | 0.38 | ល្អ |
| **សរុប** | | **4.09** | **0.44** | **ល្អ** |

តាមតារាង៤.៨ខាងលើ បានបង្ហាញពីមធ្យមភាគនៃការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ=៤.០៩)។ សូចនាករទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ=៤.៣៣)គឺ "មានកិច្ចតែងការបង្រៀន មុនដំណើរការថ្នាក់រៀនចាប់ផ្ដើម"។ សូចនាករទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៣.៨៨)គឺ "មានកំណត់ហេតុ ស្ដីពីសិស្សរៀនយឺតក្នុងថ្នាក់" ។

ការដំណើរការថ្នាក់រៀនបានល្អ គឺជាការចាំបាច់បំផុតដែលគ្រូបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងកម្រិតខ្ពស់។ ការបង្រៀន និងរៀនមានប្រសិទ្ធភាពបានលុះត្រាតែគ្រូ មានកិច្ចតែងការបង្រៀន មុនដំណើរការថ្នាក់រៀនចាប់ផ្ដើម រៀបចំការធ្វើផែនការមេរៀនលើលទ្ធផលដែលរំពឹងទុក មានសមត្ថភាពល្អពវិជ្ជាជីវៈលើជំនាញច្បាស់លាស់ ចេះបត់បែនតាមស្ថានភាពនៅពេលបង្រៀន។ ហើយការមានកិច្ចតែងការបង្រៀនមុនដំណើរការថ្នាក់រៀនចាប់ផ្ដើម នោះមានន័យថាគ្រូបានត្រៀម និងគ្រោងសកម្មភាព ឬមេរៀនដែលត្រូវបង្រៀនរួចជាស្រេច ព្រមទាំងបានអនុវត្តតាមកម្មវិធីសិក្សាដែលជា កម្មវិធីសិក្សាគោល កម្មវិធីសិក្សាលម្អិត និងស្តង់ដាកម្មវិធីសិក្សា មានការប្រើប្រាស់គរុកោសល្យ និងវិធីសាស្ត្រគ្រប់គ្រាន់ពាក់ព័ន្ធនឹងគោលបំណងនៃការបង្រៀនមេរៀនបានល្អស្របតាមសមត្ថភាពវិជ្ជាជីវៈ។ លើសពីនេះយើងដឹងបានតាមរយៈការវាយតម្លៃ ជាការវាស់ស្ទង់សមត្ថភាពសិស្ស ដើម្បីឱ្យដឹងថាលទ្ធផលសិក្សារបស់សិស្ស ទទួលបានកម្រិតណា សំដៅរកព័ត៌មាន ឬភស្តុតាងដើម្បីសន្និដ្ឋាន សម្រេចចិត្ត និងរកវិធីផ្តល់ជាតុចូល ដើម្បីជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ ដោយផ្អែកលើកម្មវិធីសិក្សាលម្អិត និងស្តង់ដាកម្មវិធីសិក្សាដែលជួយឱ្យដឹងថាលទ្ធផលសិក្សារបស់សិស្សសម្រេចបានតាមកម្មវិធីសិក្សាលម្អិត និងស្តង់ដា

កម្មវិធីសិក្សាដែរ ឬទេ នៅពេលបង្រៀនចប់ខ្លឹមសារនីមួយៗ។ ដែលគ្រូចាំបាច់មានកំណត់ហេតុស្តីពីសិស្សរៀនយឺតក្នុងថ្នាក់ ដើម្បីតាមដានការសិក្សារបស់សិស្ស និងជួយដល់សិស្សដែលមានបញ្ហាក្នុងការសិក្សា។ យោងតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍវិស័យអប់រំឆ្នាំ២០១៩-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា បានកំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់១៥ចំណុច ដោយឈរលើសរសរស្តម្ភសំខាន់ៗ ចំនួន៥។ ការកែលម្អកម្មវិធីសិក្សា ដើម្បីធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ដែលជាគោលនយោបាយអប់រំទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់តាំងពីឆ្នាំ២០១៥។ ម្យ៉ាងទៀតការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស មិនថានៅកម្រិតថ្នាក់រៀន ឬកម្រិតប្រព័ន្ធនោះទេ គឺជាធាតុគន្លឹះដ៏សំខាន់មួយក្នុងចំណោមធាតុគន្លឹះសំខាន់ផ្សេងទៀតនៅក្នុប្រព័ន្ធអប់រំ។ វាមិនត្រឹមតែវាស់អំពីសម្មិទ្ធផលសិក្សារបស់សិស្សតាមចំណុចដៅណាមួយនោះទេ ប៉ុន្តែវាក៏ដើរតួជាប៉ារ៉ាម៉ែត្រសម្រាប់ពិនិត្យមើលលើកម្មវិធីសិក្សា និងសម្រាប់ធ្វើការវាយតម្លៃការបង្រៀន និងរៀនផងដែរ (UNESCO, 2015)។ វត្តមាននៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ ជាការបង្ហាញពីការធានាថា ផែនការយុទ្ធសាស្រ្ត និងសកម្មភាពផ្សេងៗនៅកម្រិតគោលនយោបាយ និងកម្រិតសាលារៀន មានភាពពាក់ព័ន្ធគ្នាព្រមទាំងឆ្ពោះទៅរកការបង្កើនគុណភាពអប់រំ និងការអប់រំប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះតាមរយៈទិន្នន័យខាងលើដែលឆ្លើយតបដោយគ្រូបង្រៀននៅកម្រិតបឋមភូមិ បង្ហាញឱ្យឃើញថា ការមានកំណត់ហេតុ ស្តីពីសិស្សរៀនយឺតក្នុងថ្នាក់នៅមានភាពខ្វះចន្លោះ ក្នុងន័យនេះគ្រូត្រូវតែបន្តធ្វើការជួយសិស្សដែលរៀនយឺត ឬខ្សោយក្នុងថ្នាក់ជាចាំបាច់ ជាពិសេសត្រូវមានកំណត់ច្បាស់លាស់ ដើម្បីធ្វើការតាមដានការសិក្សា និងងាយស្រួលដល់ការជួយពង្រឹងលើសមត្ថភាពសិក្សារបស់សិស្ស។ លើសពីនេះអាចឱ្យសិស្សដែលមានកម្រិតចំណេះដឹងខ្ពស់ជាងគេដែលនៅក្នុងថ្នាក់ ជួយដល់សិស្សដែលរៀនខ្សោយក្នុងថ្នាក់ផងដែរ គ្រូត្រូវផ្តល់ព័ត៌មានត្រឡប់ទៅកាន់គណៈគ្រប់គ្រងសាលា ក៏ដូចជាអាណាព្យាបាលលើការសិក្សារបស់សិស្ស ដើម្បីរកដំណោះស្រាយជួយបំប៉នបន្ថែមសិស្សដែលខ្សោយទាំងនៅសាលា និងផ្ទះ។ ការមានកំណត់ហេតុនៃការសិក្សារបស់សិស្សច្បាស់លាស់ នោះការបង្រៀន និងរៀនក៏ទទួលបាន

ភាពល្អប្រសើរ ហើយក៏កាត់បន្ថយដល់ការរាំងស្ទះដល់ការអនុវត្តកម្មវិធីសិក្សាដោយសារសិស្សរៀនយឺត ដូច្នេះគ្រូគ្រប់ឯកទេសចាំបាច់ត្រូវបន្តពង្រឹងលើការធ្វើកំណត់ហេតុស្តីពីសិស្សរៀនយឺតក្នុងថ្នាក់។ ដើម្បីឱ្យការពង្រឹងនេះទទួលបានភាពល្អប្រសើរ ទាមទារឱ្យមានការគណៈគ្រប់គ្រងបានធ្វើការពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូជាប្រចាំ។ យោងតាមតារាងទិន្នន័យ៤.៥ ដែលទទួលបានការយល់ស្របក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ៤.៣៣) បង្ហាញឱ្យឃើញថា ភាគច្រើននៃការឆ្លើយតបរបស់គណៈគ្រប់គ្រងក្នុងការចុះពិនិត្យតាមដានគ្រូបានចុះពិនិត្យតាមដានល្អណាស់ និងមានភាពញឹកញាប់ ជាក់លាក់ដោយឡែកគ្រូដែលជាអ្នកទទួលបានការចុះពិនិត្យតាមដាន បានឱ្យឃើញថាការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងក៏នៅមានភាពចន្លោះខ្វះរបស់គណៈគ្រប់គ្រង ក្នុងការចុះពិនិត្យតាមដាន និងវាយតម្លៃដែរ។ បើយោងតាមរយៈតារាងទិន្នន័យ៤.៨ ក៏បានឆ្លុះបញ្ចាំងឱ្យឃើញពីកម្រិតយល់ស្របរបស់លោកគ្រូ-អ្នកគ្រូទៅលើការចុះពិនិត្យតាមដាន និងវាយតម្លៃពីសំណាក់គណៈគ្រប់គ្រងគឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ៤.០៩) បញ្ជាក់ឱ្យឃើញថាគណៈគ្រប់គ្រងពុំបានធ្វើការពិនិត្យតាមដាន និងវាយតម្លៃបានពេញលេញទេ។ គណៈគ្រប់គ្រងគឺជាអធិការអេចិន្ត្រៃយ៍ ដែលមានតួនាទីត្រួតពិនិត្យ តាមដានរាល់ការបំពេញ ការងាររបស់គ្រូបង្រៀនក្រោមឱវាទ ជាពិសេសទៅលើការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារ សម្រាប់ជំនួយដល់ការបង្រៀន និងសកម្មភាពបង្រៀនផ្ទាល់ក្នុងថ្នាក់។ ការធ្វើអធិការកិច្ចផ្ទៃក្នុងលើម៉ោងបង្រៀន បានជួយឱ្យគ្រូបង្រៀន បង្រៀនបានត្រឹមត្រូវតាមខ្លឹមសារមេរៀន និងអាចឱ្យសិស្ស ទទួលបាននូវវត្ថុបំណងរបស់មេរៀន។ ការចូលធ្វើអធិការកិច្ចម៉ោងបង្រៀន គឺជាការជួយកែលម្អគ្នាទៅ វិញទៅមក ដើម្បីរកភាពរីកចម្រើនក្នុងអង្គភាព ទាំងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សដែលជាវត្ថុបំណងដ៏សំខាន់ក្នុងបេសកម្មរបស់សាលានីមួយៗ។ ការជុះខាត់សមត្ថភាពបំណិនរបស់គ្រូបង្រៀនជាប្រចាំតាមរយៈការធ្វើអធិការកិច្ចផ្ទៃក្នុងលើម៉ោងបង្រៀន និងការប្រជុំបច្ចេកទេស ឬការធ្វើថ្នាក់និទស្សន៍ជាដើម បានជួយពង្រឹង និងពង្រីកគុណវុឌ្ឍិរបស់គ្រូបង្រៀនឱ្យកាន់តែរឹងមាំឡើងបន្ថែមទៀត ក្នុងន័យនេះដែរការសិក្សារបស់សិស្សប្រាកដជាល្អប្រសើរឡើង។

ប៉ុន្តែទោះបីជាការចុះពិនិត្យតាមដាន និងវាយតម្លៃ បានជួយដល់ការបង្រៀន និងរៀនឱ្យមានការប្រែ

ប្រួលទៅរកភាពវិជ្ជមានយ៉ាងណាក្ដីក៏ការអនុវត្តសកម្មភាពនេះ នៅមានកម្រិតនៅឡើយ។ គណៈគ្រប់គ្រងសាលាដែលជា អធិការអេចិន្ត្រៃយ៍ មិនអាចធ្វើអធិការកិច្ចម៉ោងបង្រៀនរបស់គ្រូក្នុងសាលារបស់ខ្លួនបាន ១០០% នៅឡើយទេដោយសារតែកត្តាមួយចំនួនដូចជា ការត្រូវបំពេញភារកិច្ចផ្សេងៗជាច្រើនទៀត ទាំងការងារក្នុងសាលា និងការងារសង្គមដែលថ្នាក់លើតម្រូវឱ្យធ្វើ ដែលជាបញ្ហារាំងស្ទះដល់ការអនុវត្តសកម្មភាពនេះ មិនបានគ្រប់ជ្រុងជ្រោយ។ ហើយមានតែប្រធានក្រុមបច្ចេកទេស ដែលជាអ្នកទទួលរាប់រងភារកិច្ចនេះជំនួសឱ្យគណៈគ្រប់គ្រង។

សរុបសេចក្ដីមក ការចុះពិនិត្យតាមដាន និងវាយតម្លៃរបស់គណៈគ្រប់គ្រងសាលា និងប្រធានក្រុមបច្ចេកទេសពិតជាមានសារៈសំខាន់ណាស់ក្នុងការកែលម្អគុណភាពបង្រៀន និងរៀនក្នុងសាលា ក៏ដូចជាប្រព័ន្ធអប់រំទាំងមូល។ លើសពីនេះគ្រូបង្រៀនអាចដឹងពីចំណុចខ្វះខាតដែលត្រូវធ្វើការកែលម្អ និងចំណេះដឹងថ្មីគ្រប់រូបភាព ទាំងបច្ចេកទេសបង្រៀនតាមរយៈការចុះពិនិត្យដាន និងវាយតម្លៃ តែប្រសិនបើមានការខ្វះចន្លោះលើការពិនិត្យតាម និងវាយតម្លៃនោះធ្វើឱ្យបរិបទនៃការបង្រៀន និងរៀននៅក្នុងសាលាពុំមានការអភិវឌ្ឍន៍ដើរមិនទាន់ការរីកចម្រើននៃប្រព័ន្ធអប់រំបែបទំនើប អ្វីដែលសំខាន់នោះគឺប៉ះពាល់ដល់ការសិក្សា និងលទ្ធផលសិក្សារបស់សិស្សា ដែលជាមូលធនមនុស្សដ៏ចាំបាច់បំផុតក្នុងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត។

**សំណើសុំបន្ថែមពីគណៈគ្រប់គ្រង និងគ្រូបង្រៀន**

- ជម្រុញការយកចិត្តទុកដាក់លើការចុះជួយ តាមរយៈការពិនិត្យតាមដាន និងវាយតម្លៃលើការបង្រៀន និងរៀនដោយធ្វើថ្នាក់និទស្សន៍ ដើម្បីពង្រឹងក៏ដូចជាកែលម្អលើការអនុវត្តកម្មវិធីសិក្សាឱ្យកាន់តែប្រសើរឡើង។
- ផ្ដល់ការលើកទឹកចិត្តដល់គ្រូបង្រៀនឱ្យរៀបចំធ្វើថ្នាក់និទស្សន៍ ដើម្បីពង្រឹងបន្ថែមលើដំណើរការបង្រៀន និងផ្លាស់ប្ដូរបទពិសោធន៍របស់គ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ ឱ្យការបង្រៀនកាន់តែប្រសើរឡើង។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ឥរិយាបថក្នុងការអនុវត្តកម្មវិធីសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមកំណែទម្រង់ប្រព័ន្ធអប់រំ ក៏ជាការកំណែទម្រង់គុណភាពរបស់គ្រូ ដើម្បីឱ្យសិស្សទទួលបានលទ្ធផលនៃការសិក្សាល្អប្រសើរឆ្លើយតបទៅលើតម្រូវការសង្គមជាតិ ដែលបានបង្កើតឱ្យមានកម្មវិធីអប់រំពលរដ្ឋពេញលេញ។ ការស្រាវជ្រាវនេះបានផ្តល់ជារបកគំហើញថ្មីមួយ ស្តីពី ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ គោលបំណងសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ព្រមទាំងការពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងទៅលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ។ វិធីសាស្ត្រស្រាវជ្រាវដែលអ្នកស្រាវជ្រាវបានប្រើគឺ អនុវត្តតាមបែបបរិមាណវិស័យ ដោយធ្វើការប្រមូលទិន្នន័យតាមរយៈកម្រងសំណួរក្នុងចំនួន៤ មធ្យមសិក្សាបឋមភូមិនៅខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប៦១នាក់ លោកគ្រូ-អ្នកគ្រូចំនួន៥២នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន៩នាក់។ ការវិភាគទិន្នន័យសិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា គ្រូបង្រៀនមានឥរិយាបថក្នុងកម្រិតល្អ ឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ការអនុវត្តដំណើរការបង្រៀនរបស់គ្រូបង្រៀន តាមកម្មវិធីសិក្សាពិតជាមានសារៈសំខាន់ណាស់ នៅមធ្យមសិក្សាបឋមភូមិសំដៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមថ្នាក់រៀននីមួយៗ និងមុខវិជ្ជាវិទ្យាសាស្ត្រពិត ក៏ដូចជាមុខវិជ្ជា វិទ្យាសាស្ត្រសង្គម។ ឥរិយាបថជាវិជ្ជមានក្នុងការអនុវត្តតាមកម្មវិធីសិក្សា ក៏តម្រូវឱ្យគ្រូបង្រៀនផ្តោតការ យកចិត្តទុកដាក់ទៅលើដំណើរការសិក្សារបស់សិស្សជាប្រចាំផងដែរ ព្រោះដំណើរការបង្រៀនអាចទទួល បានលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមានអាស្រ័យលើការចូលរួមពីដំណើរការសិក្សារបស់សិស្សគ្រប់រូបផងដែរ។ លទ្ធផលនៃការសិក្សាបានបង្ហាញ ពីបញ្ហាប្រឈមមួយចំនួន ទាក់ទងទៅនឹងកង្វះសៀវភៅសិក្សាគោល ការប្រើ

ប្រាស់គ្រូបង្រៀនមិនស្របតាមនិយាម និងសម្ភារឧបទេសពុំទាន់ឆ្លើយតបខ្លឹមសារមេរៀនជាដើម។ បញ្ហាប្រឈមដែលបានលើកឡើង គឺពិតជារាំងស្ទះដល់ដំណើរបង្រៀនរបស់គ្រូ ប៉ះពាល់ដល់ការអនុវត្ត កម្មវិធីសិក្សាពុំទាន់តាមកាលកំណត់ និងប្រសិទ្ធភាពក្នុងការសិក្សារបស់សិស្សផងដែរ។ ការពិនិត្យតាម ដានជាប្រចាំក្នុងការអនុវត្តតាមកម្មវិធីសិក្សាលើដំណើរការបង្រៀនរបស់គ្រូ គឺជាយន្តការដើម្បីពង្រឹងការ ធានាគុណភាព ឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងរដ្ឋាភិបាល ក្នុងវិស័យអប់រំ លើសមត្ថភាព ចំណេះដឹង និងជំនាញរបស់សិស្សានុសិស្ស ដែលជាកម្លាំងពលកម្មបម្រើ ដល់ វិស័យសេដ្ឋកិច្ច ក៏ដូចជាសង្គមជាតិ។

ជារួមឥរិយាបថឆ្លើយតបជាវិជ្ជមានរបស់គ្រូបង្រៀនទៅលើកម្មវិធីសិក្សាបានបង្ហាញពីកម្រិតល្អប្រសើរនៃការអនុវត្តកម្មវិធីសិក្សាបានចប់តាមកាលកំណត់ ដែលបង្កលទ្ធភាពដល់ការប្រសើរឡើងនៃការសិក្សារបស់សិស្ស ការអនុវត្តបានតាមគន្លងអាជីពគ្រូបង្រៀន ការបន្តអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ និងប្រសិទ្ធភាពខ្ពស់នៃការគ្រប់គ្រង និងដឹកនាំសាលារៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ គណៈគ្រប់គ្រងសាលារៀន និងភាគីពាក់ព័ន្ធគួរមានយន្តការបំប៉នកញ្ចប់សមត្ថភាពគ្រូបង្រៀន ដើម្បីឆ្លើយតបទៅ នឹងកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំ។

អ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះអាចជំរុញនិងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីសិក្សាឆ្លើយតបទៅនឹងបញ្ហាប្រឈម ដើម្បីបង្កើតបានសមិទ្ធផលគុណភាពអប់រំ និងលទ្ធផលការសិក្សារបស់សិស្សកាន់តែមានភាពល្អប្រសើរឡើង សមស្របទៅនឹងកំណែទម្រង់គុណភាពរបស់គ្រូ ដើម្បីឱ្យសិស្សទទួលបានលទ្ធផលនៃការសិក្សាល្អប្រសើរឆ្លើយតបទៅលើតម្រូវការសង្គមជាតិ ដែលបានបង្កើតឱ្យមានកម្មវិធីអប់រំពលរដ្ឋពេញលេញ។ ក៏សង្ឃឹមដែរថាគណៈគ្រប់គ្រងនឹងធ្វើការចុះពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សា ក៏ដូចជាការពង្រឹងលើការបង្រៀន និងរៀន ព្រមទាំងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងសម្រេចលទ្ធផលបានជោគជ័យ ត្រចេះត្រចង់ដែលធ្វើឱ្យប្រព័ន្ធនៃការអប់រំរីកចម្រើនជាលំដាប់។

យោងតាមការរកឃើញ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវគំនិតយោបល់ ព្រមទាំងសំណូមពរ

មួយចំនួនសម្រាប់ភាគីពាក់ព័ន្ធដើម្បីចូលរួមលើកកម្ពស់ឱ្យមានការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀន ក្នុងការអនុវត្តកម្មវិធីសិក្សា ឱ្យកាន់តែល្អប្រសើរជាងនេះដូចជា៖

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - ផ្តល់កញ្ចប់បណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈ ដល់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាអប់រំពលរដ្ឋពេញ ក្នុងខេត្តកំពង់ស្ពឺ។
  - ធ្វើបច្ចុប្បន្នភាព លើរបាយការណ៍នៃការអនុវត្តយន្តការពិនិត្យតាមដានកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។
- **មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ**
  - ពង្រឹងកញ្ចប់បណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈ ដល់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញ។
  - បន្តលើកកម្ពស់យន្តការពិនិត្យតាមដាន ការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ស្ពឺ។
- **គណៈគ្រប់គ្រងសាលារៀន**
  - បន្តពង្រឹងបន្ថែមនូវការអភិវឌ្ឍវិជ្ជាជីវៈសមត្ថភាព ការសិក្សាស្រាវជ្រាវចំណេះដឹងថ្មីៗ តាមរយៈការធ្វើថ្នាក់និទស្សន៍ និងប្រជុំបច្ចេកទេស។
  - បន្តជម្រុញអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គ្រូជានិរន្តរ៍ ឱ្យស្របតាមស្តង់ដារគ្រូបង្រៀនសតវត្សរ៍ទី២១ ដើម្បីចូលរួមបណ្តុះធនធានមនុស្សឱ្យចំតម្រូវការសង្គមសេដ្ឋកិច្ច។
- **សម្រាប់ការសិក្សាស្រាវជ្រាវបន្ត**

ប្រធានបទដែលបានសិក្សាស្រាវជ្រាវនេះគឺផ្តោតទៅលើ "ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ" ដែនកំណត់ និងវិសាលភាពនៃការសិក្សានេះគឺ បានជ្រើសរើសក្រុង/ស្រុកចំនួន ២ក្នុងខេត្តកំពង់ស្ពឺ គឺ៖ ក្រុងច្បារមន និងស្រុកភ្នំស្រួច ដោយយកមធ្យមសិក្សាបឋមភូមិចំនួន៤ មានសំណាកសរុបចំនួន ៦១នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងសាលា

រៀនចំនួន៩នាក់ និងគ្រូបង្រៀនបឋមភូមិចំនួន៥២នាក់។ សម្រាប់ការសិក្សាស្រាវជ្រាវបន្តគួរតែផ្តោតទៅលើ៖

- "ទស្សនៈនៃការយល់ឃើញរបស់គ្រូបង្រៀនទុតិយភូមិ លើការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តកំពង់ស្ពឺ"។
- "ស្ថានភាពនៃការអនុវត្តការងារឆ្លើយតបគន្លងអាជីពគ្រូបង្រៀន នៅមធ្យមសិក្សាចំណេះទូទៅ ក្នុងខេត្តកំពង់ស្ពឺ"។
- "ប្រសិទ្ធភាពនៃការបំពេញការងារ លើក្របខណ្ឌកំណែទម្រង់នៃវិស័យអប់រំ នៅក្នុងកម្រិតបឋមសិក្សារបស់ខេត្តកំពង់ស្ពឺ"។

# ឯកសារយោង


ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ(២០១៩) កាលិកបត្រស្រាវជ្រាវអប់រំកម្ពុជា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ(២០១៨) កាលិកបត្រស្រាវជ្រាវអប់រំកម្ពុជា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០២០) ឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៩) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៩) ឯកសារសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) កម្មវិធីសិក្សាលម្អិត ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៥) ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៥) បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងការអប់រំចំណេះទូទៅនៅកម្ពុជា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ភ្នំពេញ

ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០១៣) គោលនយោបាយស្តីពីគ្រូបង្រៀន ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០១១) គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០០៩) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០០៩) ករណីសិក្សាស្រាវជ្រាវការអនុវត្តម៉ោងបង្រៀន ក្នុងខេត្តកំពង់ស្ពឺ ព្រះវិហារ ក្រចេះ និងរាជធានីភ្នំពេញ ភ្នំពេញ អង្គការយូនីសែហ្វ។
ក្រសួងអប់រំ យុវជន និងកីឡា(២០០៥) កម្មវិធីកុមារមេត្រី ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០០៤) គរុកោសល្យសម្រាប់បម្រើកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន នៅអនុវិទ្យាល័យ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(២០០៣) ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥ ភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា(១៩៨០) ទស្សនាវដ្តីអប់រំ ទំ៤៨។
ក្រសួងអប់រំ យុវជន និងកីឡា(១៩៩៧) សកម្មភាពបណ្តុះបណ្តាលគ្រូបង្រៀន និងថ្នាក់អនុវិទ្យាល័យ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ(២០២០) សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០១៩-២០២០ ច្បារមន មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ។
សម្តេចព្រះសង្ឃរាជ ជួន ណាត(១៩៦៨) វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ រាជធានីភ្នំពេញ។

ហាក់ សៀងលី(២០១៦, ឧសភា ២៦) Wikipedia Retrieved from ចិត្ត-គរុកោសល្យ៖ គំនិតខ្លះៗ https://km.m.wikipedia.org

The Performance Juxtaposition Site. (1995). Bloom's Taxonomy of learning Domains. http://www.nwlink.com/~donclark/hrd/bloom.html

Badri, M. A. (2016). *Preception of teachers'professional development needs,impacts,and barriers: The abu dhabi case.* SAGE Open,6(3), 1-15

Bastug, M. (2014). *The Structural Relationship of Reading Attitude, Reading Comprehension and Academic Achievement, International J. Soc. Sci. & Education,4(4).*

Benett, Y. (1980). *Teachers' attitudes to curriculum innovation: Making explicit a psychological perspective.* The Vocational Aspect of Education, 32:83, 71-76. doi:10.1080/10408347308001381

Best, J. W. (1981). *Research in Education.* Englewood Cliffs, 4th Edition ed., New York, Jersey: Prentice Hall, Inc.

Buczynski, S., & Hansen, C. B. (2010). *Impact of professional development on teacher practice: Uncovering connection.* Teacher and Teacher Education, 26, 599-607.

Darling-Hammond, L. (2006). Constructing 21 st-Century teacher education*. Journal of Teacher Education*. *57*(3), 300-314. doi:10.1177/0022487105285962.

Darling-Hammond, L. (2014). Strengthening clinical preparation: The Holy Grail of teacher education. *Peabody Journal of Education. 89*(4), 547-561.

Dewey, J. (2015). Retrieved from P21 Framwork Definitions: WWW.p21.org

Frey, A. (2001). *Implementting a standards-based curriculum: You're not done yet.*

Retrieved October 28, 2005, from http://alliance.brown.edu/investigation/spotlight/archive/apr01.htm1

Hang Chuon, N. (2017). The paths of education reform. *Cambodia Education Review, l(1),* 5-31.

Klecka, C. L., Odell, S. J., Houston, R. W., & McBee, R. H. (Eds) (2009). *Visions for Teacher Educators.* Phymouth, UK: Association of Teacher Educators and Rowman & Littlefield Education.

Ministry of Education Youth and Sport. (2008). *Time teaching and learning .* Phnom Penh: Unicef/Sida.

NGO Education Partnership. (2005). *Effective teaching hours:* A report on the group reasearch project. Phnom Penh: UNICEF.

Parker, M., & Tannehill, D. (2015). *Helping teachers help themselves: Professional development that make a difference.* NASSP Bulletin, 99(1),26-42.

Patton, K., Parker, M., & Tannehill, D. (2015). Helping teachers help themselves: Professional development that make a difference*. NASSP Bulletin, 99*(1), 26-42.

Phin, C. (2014). Challenges of Cambodian Teachers in Contributing to Human and Social Development: Are They Well-Trained? *Internatonal Journal of Social Science and Humanity,4*(5),344 .

Reeves, D. (2004). *Accountability for learning: How teachers and school leaders can take charge.* Alexandria: ASCD.

Ros, V., & Oleksiyenko, A. (2017). *Policy misalignments and development challenges in the Cambodian academic profession: Insights from public university lecturers.*

Higher Education Policy.

Steward, A. (2009). *Continuing your professional development in lifelong learning.* London: Continuum International Publishing Group.

Zepeda, S. J. (2012). *Professional development: What words (2nd ed).* New York: Taylor and Francis.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"

## កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ

នាងខ្ញុំឈ្មោះ ហៃ សុខអេង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ទិន្នន័យប្រមូលបានពីលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រង មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះសូមលោកគ្រូ-អ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យនាងខ្ញុំអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. ជាគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ ដែលកំពុងបង្រៀន ☐ បាទ/ចាស ☐ ទេ

២. បម្រើការងារនៅ៖.........................................................ឃុំ/សង្កាត់៖.................................

ក្រុង/ស្រុក/ខណ្ឌ៖...................................................ខេត្ត៖....................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ១៨-២៣ ឆ្នាំ ☐ ២៤-២៩ឆ្នាំ ☐ ៣០-៣៥ឆ្នាំ ☐ លើពី៣៥ឆ្នាំ

៥.កម្រិតវប្បធម៌ □ ចប់ថ្នាក់ទី១២ □ បរិញ្ញាបត្រ □បរិញ្ញាបត្រជាន់ខ្ពស់ □ ផ្សេងៗ

៦.បទពិសោធន៍បង្រៀន៖□១ ដល់ ៥ ឆ្នាំ □៦ ទៅ១០ ឆ្នាំ□ ១១ទៅ១៥ ឆ្នាំ □លើសពី១៥ឆ្នាំ

៧. មុខវិជ្ជាឯកទេស៖.....................................................បង្រៀនថ្នាក់ទី៖..........................

**ផ្នែកទី២៖ ឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ**

ការណែនាំ៖ នៅក្នុងបទពិសោធន៍នៃការបង្រៀនរបស់លោកគ្រូ អ្នកគ្រូកន្លងមក តើលោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ មានការយល់ឃើញ ទៅលើការអនុវត្តកម្មវិធីសិក្សា យ៉ាងដូចម្តេចខ្លះ? សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ-អ្នកគ្រូ ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| ក. ឥរិយាបថរបស់លោកគ្រូ-អ្នកគ្រូ | | ១ | ២ | ៣ | ៤ | ៥ |
| ១ | មានទស្សនៈវិស័យ និងគោលដៅសំខាន់ៗក្នុងការបង្រៀន | | | | | |
| ២ | មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន( ការគោរពម៉ោងពេលចេញ ចូល) | | | | | |
| ៣ | មានស្មារតី និងភាពជឿជាក់លើការបង្រៀន ដើម្បីការអប់រំមានគុណភាព និងប្រសិទ្ធភាពខ្ពស់ | | | | | |
| ៤ | បង្រៀនតាមកិច្ចតែងការដែលបានរៀបចំ | | | | | |
| ៥ | មានលំហាត់ ឬលើកឧទាហរណ៍ ក្នុងការពន្យល់និងបំណកស្រាយ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | បានរៀបចំសម្ភារៈឧទ្ទេសដែលឆ្លើយតបនឹងខ្លឹមសារមេរៀន | | | | | |
| ៧ | មានឆន្ទៈចូលរួមប្រជុំបច្ចេកទេសជាប្រចាំ | | | | | |
| ៨ | បានរៀបចំផែនការបង្រៀនជាប្រចាំ (សប្ដាហ៍ ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ) | | | | | |
| ៩ | ការបង្រៀន មានភាពជាប់ពាក់ព័ន្ធគ្នាពីមួយមេរៀនទៅមួយមេរៀន | | | | | |
| ១០ | សំឡេងគ្រូច្បាស់ៗទៅកាន់សិស្សនៅពេលបង្រៀនខ្លឹមសារមេរៀន | | | | | |
| ១១ | មានស្មារតីសហការចូលរួមធ្វើការជាក្រុម | | | | | |
| ១២ | បានទទួលការបំប៉នសមត្ថភាពលើកម្មវិធីសិក្សា | | | | | |
| ១៣ | ការសម្រេចចិត្ត ដោយផ្អែកលើភស្តុតាងជាក់ស្តែង ច្បាស់លាស់ | | | | | |
| ខ. ការអនុវត្តកម្មវិធីសិក្សា | | | | | | |
| ១ | បង្រៀនចប់ខ្លឹមសារមេរៀនតាមកម្មវិធីសិក្សា | | | | | |
| ២ | មានវិធីសាស្ត្រថ្មីត្រឹមត្រូវតាមគរុកោសល្យ ក្នុងការបង្រៀនសិស្ស | | | | | |
| ៣ | បានរៀបចំ និងអនុវត្តតាមកាលវិភាគបង្រៀនយ៉ាងត្រឹមត្រូវ | | | | | |
| ៤ | បានធ្វើថ្នាក់និទស្សន៍ ដើម្បីចែករំលែកបទពិសោធន៍ | | | | | |
| ៥ | បង្រៀនតាមកាលវិភាគ និងម៉ោងកំណត់ | | | | | |
| ៦ | ការគ្រប់គ្រងថ្នាក់រៀន | | | | | |
| ៧ | បានស្រាវជ្រាវបន្ថែមលើចំណេះដឹង ជំនាញវិជ្ជាជីវៈរបស់ខ្លួន | | | | | |
| ៨ | បានអនុវត្តតាមកម្មវិធីសិក្សា និងបំណែងចែកកម្មវិធីសិក្សាបានត្រឹមត្រូវ | | | | | |
| គ. ដំណើរការសិក្សារបស់សិស្ស | | | | | | |
| ១ | ការឆ្លើយតប និងបកស្រាយចម្ងល់សិស្ស បានក្បោះក្បាយ | | | | | |
| ២ | បានជម្រុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | | | | | |
| ៣ | មានចំណាប់អារម្មណ៍លើសិស្សគ្រប់រូប | | | | | |
| ៤ | ទាញចំណាប់អារម្មណ៍សិស្ស ផ្ដោតលើមេរៀន ពេលសិស្សបាត់បង់ប្រយ័ត្ន | | | | | |
| ៥ | តាមរយៈការប្រឡង បង្ហាញថាសិស្សងាយយល់លើខ្លឹមសារមេរៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | គ្រូ និងសិស្ស មានទំនាក់ទំនងល្អក្នុងដំណើរការបង្រៀន | | | | | |
| ៧ | ផ្តល់ការណែនាំដល់សិស្សឡើងវិញពេលគ្រូសង្កេតឃើញសិស្សមិនចូលរួម | | | | | |
| ៨ | បានបង្កើតបរិយាកាសរៀនសូត្រ ដែលផ្តល់ការលើកទឹកចិត្តដល់សិស្សក្នុងថ្នាក់រៀន | | | | | |
| ៩ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | | | | | |

**មតិយោបល់បន្ថែម៖**

ក. អំពីការអនុវត្តកម្មវិធីសិក្សា

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ខ. ការរៀបចំសម្ភារៈឧបទ្ទេសសម្រាប់បង្រៀន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

គ. ការគ្រប់គ្រងថ្នាក់រៀន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ឃ. ឥរិយាបថសិក្សារបស់សិស្ស

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## ផ្នែកទី៣៖ បញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាបឋមភូមិខេត្តកំពង់ស្ពឺ

ការណែនាំ៖ នៅក្នុងការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ-អ្នកគ្រូ នៅមធ្យមសិក្សាបឋមភូមិខេត្តកំពង់ស្ពឺ នាពេលកន្លងមក បានជួបបញ្ហាប្រឈមដូចម្តេចខ្លះ? សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការយល់ស្របរបស់លោកគ្រូ-អ្នកគ្រូ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជានីមួយៗ | | | | | |
| ២ | ផ្តល់សៀវភៅពុម្ពសម្រាប់គ្រូបានគ្រប់គ្រាន់ | | | | | |
| ៣ | មានវគ្គបំប៉នដល់គ្រូ លើការអនុវត្តកម្មវិធីសិក្សា | | | | | |
| ៤ | បានរៀបចំ ការបណ្តុះបណ្តាលនៃវិធីសាស្ត្របង្រៀនថ្មី | | | | | |
| ៥ | ជម្រុញសកម្មភាពសិស្ស ក្នុងការសិក្សា និងមករៀនទៀងទាត់ | | | | | |
| ៦ | បានពង្រឹងការផ្សព្វផ្សាយពីគោលនយោបាយអប់រំ ពាក់ព័ន្ធគ្រូបង្រៀន អោយដល់ថ្នាក់ក្រោមជាតិ សាលារៀន | | | | | |
| ៧ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់គ្រូ ផលិតសម្ភារៈឧបទេស | | | | | |
| ៨ | គ្រូបង្រៀនទទួល បានការលើកទឹកចិត្តពីសហគមន៍ | | | | | |
| ៩ | មានការទទួលខុសត្រូវចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ | | | | | |
| ១០ | គ្រូបង្រៀនបានសម្តែងការពេញចិត្តនៅពេលអ្នកដទៃបង្ហាញពីចំណុចខ្វះខាត និងចំណុចដែលត្រូវកែលម្អ | | | | | |

**មតិយោបល់បន្ថែម៖**

១. តើមានចំណុចខុសគ្នាអ្វីខ្លះទៀត ដែលលោកគ្រូ អ្នកគ្រូជួបប្រទះក្នុងពេលបង្រៀន?

................................................................................................................................

................................................................................................................................

................................................................................................................................

**ផ្នែកទី៤៖ ការចុះពិនិត្យតាមដាននិងវាយតម្លៃពីគណៈគ្រប់គ្រងសាលារៀន ក្នុងការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ**

ការណែនាំ៖ នៅការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ របស់លោកគ្រូ-អ្នកគ្រូក្នុងខេត្តកំពង់ស្ពឺ បាន ធ្លាប់ទទួលការចុះពិនិត្យតាមដាន និងវាយតម្លៃពីគណៈគ្រប់គ្រងសាលារៀនយ៉ាងដូចម្ដេចខ្លះ? សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការយល់ស្របរបស់លោកគ្រូ អ្នកគ្រូ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | បានរៀបចំការធ្វើផែនការមេរៀន លើលទ្ធផលរំពឹងទុក | | | | | |
| ២ | មានកិច្ចតែងការបង្រៀន មុនដំណើរការថ្នាក់រៀនចាប់ផ្ដើម | | | | | |
| ៣ | មានសមត្ថភាពវិជ្ជាជីវៈ លើជំនាញច្បាស់លាស់ | | | | | |
| ៤ | មានភាពបត់បែន ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន | | | | | |
| ៥ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស | | | | | |
| ៦ | មានកំណត់ហេតុ ស្ដីពីសិស្សរៀនយឺត ក្នុងថ្នាក់ | | | | | |
| ៧ | បានបង្រៀនមេរៀន តាមមុខវិជ្ជាឯកទេសទាន់កម្មវិធីសិក្សា | | | | | |
| ៨ | បានគោរពភារកិច្ចតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលារៀន | | | | | |
| ៩ | មានទំនាក់ទំនងល្អ ជាមួយសហគមន៍សាលារៀន | | | | | |
| ១០ | មានគ្រប់កំណត់ហេតុ ក្នុងសៀវភៅកិច្ចការគ្រូ | | | | | |
| ១១ | បានទទួល ការណែនាំលើដំណើរការបង្រៀនពីគណៈគ្រប់គ្រង | | | | | |

**មតិយោបល់បន្ថែម៖**

១. តើគណៈគ្រប់គ្រង និងប្រធានមុខវិជ្ជា មានផ្តល់យោបល់កែលម្អលើវិធីសាស្ត្របង្រៀន ដល់លោកគ្រូ-អ្នកគ្រូអ្វីខ្លះ ?

.................................................................................................................................

.................................................................................................................................

.................................................................................................................................

២. តើមានចំណុចខ្វះខាតអ្វីខ្លះទៀត ដែលលោកគ្រូ អ្នកគ្រូធ្លាប់បានទទួល ?

.................................................................................................................................

.................................................................................................................................

.................................................................................................................................

សូមអរគុណ!

# ឧបសម្ព័ន្ធ "ខ"
# ទិន្នន័យទទួលបានពីគ្រូបង្រៀនលើព័ត៌មានទូទៅ

| ល.រ | បរិយាយ | | អនុវិទ្យាល័យ | | | | សរុបរួម | |
|---|---|---|---|---|---|---|---|---|
| | | | អនុ.ទីរួមខេត្ត | អនុ.ឆាយធុប | អនុ.គីរីវ័ន្ត | អនុ.ព្រៃក្មេង | ចំនួន | ភាគរយ |
| ១ | គ្រូបង្រៀនថ្នាក់ទី | ថ្នាក់ទី៧ | 5 | 5 | 3 | 4 | 17 | 32.69% |
| | | ថ្នាក់ទី៨ | 5 | 5 | 4 | 4 | 18 | 34.62% |
| | | ថ្នាក់ទី៩ | 5 | 5 | 3 | 4 | 17 | 32.69% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |
| ២ | ភេទ | ប្រុស | 8 | 6 | 6 | 6 | 26 | 50.00% |
| | | ស្រី | 7 | 9 | 4 | 6 | 26 | 50.00% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |
| ៣ | អាយុ | ១៨ - ២៣ ឆ្នាំ | 0 | 0 | 0 | 0 | 0 | 0.00% |
| | | ២៤ - ២៩ ឆ្នាំ | 0 | 1 | 2 | 3 | 6 | 11.54% |
| | | ៣០ - ៣៥ ឆ្នាំ | 5 | 3 | 3 | 4 | 15 | 28.85% |
| | | លើសពី៣៥ ឆ្នាំ | 10 | 11 | 5 | 5 | 31 | 59.62% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |
| ៤ | កម្រិតសញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | 0 | 2 | 1 | 1 | 4 | 7.69% |
| | | បរិញ្ញាបត្រ | 11 | 10 | 9 | 5 | 35 | 67.31% |
| | | ចប់ថ្នាក់ទី១២ | 4 | 3 | 0 | 6 | 13 | 25.00% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |
| ៥ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ ឆ្នាំ | 0 | 0 | 0 | 1 | 1 | 1.92% |
| | | ៦ ដល់ ១០ ឆ្នាំ | 1 | 2 | 4 | 4 | 11 | 21.15% |
| | | ១១ ដល់ ១៥ ឆ្នាំ | 3 | 1 | 3 | 2 | 9 | 17.31% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | លើសពី១៥ឆ្នាំ | 11 | 12 | 3 | 5 | 31 | 59.62% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |
| ៧ | មុខវិជ្ជាឯកទេស | ភាសាខ្មែរ | 1 | 3 | 2 | 2 | 8 | 15.38% |
| | | ភាសាបរទេស | 2 | 2 | 1 | 2 | 7 | 13.46% |
| | | គណិតវិទ្យា | 4 | 2 | 0 | 1 | 7 | 13.46% |
| | | វិទ្យាសាស្ត្រ | 5 | 5 | 3 | 3 | 16 | 30.77% |
| | | សិក្សាសង្គម | 3 | 3 | 4 | 4 | 14 | 26.92% |
| | | **សរុប** | **15** | **15** | **10** | **12** | **52** | **100%** |

## ឧបសម្ព័ន្ធ "គ"

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ

នាងខ្ញុំឈ្មោះ ហៃ សុខអេង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាស្វែងយល់ពីឥរិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ។ ទិន្នន័យប្រមូលបានពីលោក-លោកស្រី ជាគណៈគ្រប់គ្រង មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូ-អ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យនាងខ្ញុំអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

### ផ្នែកទី១៖ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. តួនាទី៖....................................................មុខវិជ្ជាឯកទេស៖...............................................

២. បម្រើការងានៅ៖..........................................................ឃុំ/សង្កាត់៖...................................

ក្រុង/ស្រុក/ខណ្ឌ៖....................................................ខេត្ត៖.....................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ២៥-៣០ ឆ្នាំ ☐ ៣១-៣៥ឆ្នាំ☐ ៣៦-៤០ឆ្នាំ ☐ លើពី៤០ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ ចប់ថ្នាក់ទី១២ ☐ បរិញ្ញាបត្រ ☐បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ

៦.បទពិសោធន៍បង្រៀន៖☐១ ដល់ ៥ ឆ្នាំ ☐៦ ទៅ១០ ឆ្នាំ☐ ១១ទៅ១៥ ឆ្នាំ ☐លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ ការិយាបថឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា របស់លោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ**

ការណែនាំ៖ សំនួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូនាពេលកន្លងមក តើលោកគ្រូ-អ្នកគ្រូនៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ មានការយល់ឃើញ ទៅលើការអនុវត្តកម្មវិធីសិក្សា យ៉ាងដូចម្តេចខ្លះ? សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ-អ្នកគ្រូ ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | គ្រូបង្រៀន មានទស្សនៈវិស័យក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន | | | | | |
| ២ | គ្រូបង្រៀន មានឆន្ទៈចូលរួមប្រជុំបច្ចេកទេសជាប្រចាំ | | | | | |
| ៣ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើមុខវិជ្ជាកំពុងបង្រៀន | | | | | |
| ៤ | គ្រូបង្រៀន បានបង្រៀនមេរៀន ស្របតាមកម្មវិធីសិក្សា# | | | | | |
| ៥ | គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់# | | | | | |
| ៦ | គ្រូបង្រៀន មានស្មារតីសហការចូលរួមធ្វើការជាក្រុម | | | | | |
| ៧ | គ្រូបង្រៀន មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន( ការគោរពម៉ោងពេលចេញ ចូល) | | | | | |
| ៩ | គ្រូបង្រៀនមានស្មារតី និងភាពជឿជាក់លើការបង្រៀន ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ | | | | | |
| ១០ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | | | | | |
| ១១ | គណៈគ្រប់គ្រង បានផ្ដល់មតិយោបល់ កែលម្អ ក្នុងការធ្វើថ្នាក់និទស្សន៍របស់គ្រូបង្រៀន | | | | | |
| ១២ | គណៈគ្រប់គ្រង បានជួយគាំទ្រលើកទឹកចិត្តក្នុងការបំពេញការងារ ដល់បុគ្គលិកក្នុងអង្គភាព# | | | | | |
| ១៣ | គណៈគ្រប់គ្រង បានពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូជាប្រចាំ | | | | | |
| ១៤ | គណៈគ្រប់គ្រង បានផ្ដល់វគ្គបំប៉នសមត្ថភាព ដល់គ្រូបង្រៀនលើការអនុវត្តកម្មវិធីសិក្សា | | | | | |
| ១៥ | គណៈគ្រប់គ្រងបានចែករំលែកចំណេះដឹងពីការបណ្ដុះបណ្ដាល ទៅដល់លោកគ្រូ-អ្នកគ្រូផ្សេងទៀត | | | | | |
| ១៦ | សហគមន៍បានចូលរួម ជាមួយសាលារៀនលើការសិក្សារបស់សិស្ស | | | | | |
| ១៧ | ជារួម លោកគ្រូ-អ្នកគ្រូ គឺមានការពេញចិត្ត និងភាពច្បាស់លាស់ ទៅលើការអនុវត្តកម្មវិធីសិក្សា នៅមធ្យមសិក្សាបឋមភូមិ | | | | | |

**មតិយោបល់បន្ថែមៈ**

១. តើលោក-លោកស្រី មានជួបប្រទះការលំបាកអ្វីខ្លះ ក្នុងការអនុវត្តកម្មវិធីសិក្សា?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

២. ពេលជួបការលំបាកខាងលើ តើលោក-លោកស្រី បានដោះស្រាយយ៉ាងដូចម្ដេចខ្លះ?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

សូមអរគុណ!

# ឧបសម្ព័ន្ធ "ឃ"

# ទិន្នន័យទទួលបានពីគណៈគ្រប់គ្រងលើព័ត៌មានទូទៅ

| ល.រ | បរិយាយ | | អនុវិទ្យាល័យ | | | | សរុបរួម | |
|---|---|---|---|---|---|---|---|---|
| | | | អនុ.ទីរួមខេត្ត | អនុ.ឆាយធុប | អនុ.គីរីវ័ន្ត | អនុ.ព្រៃក្មេង | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 2 | 2 | 2 | 1 | 7 | 77.78% |
| | | ស្រី | 1 | 1 | 0 | 0 | 2 | 22.22% |
| | | **សរុប** | **3** | **3** | **2** | **1** | **9** | **100%** |
| ២ | អាយុ | ២៥ - ៣០ ឆ្នាំ | 0 | 0 | 0 | 0 | 0 | 0.00% |
| | | ៣១ - ៣៥ ឆ្នាំ | 0 | 0 | 0 | 1 | 1 | 11.11% |
| | | ៣៦ - ៤០ ឆ្នាំ | 0 | 0 | 1 | 0 | 1 | 11.11% |
| | | លើសពី៤០ឆ្នាំ | 3 | 3 | 1 | 0 | 7 | 77.78% |
| | | **សរុប** | **3** | **3** | **2** | **1** | **9** | **100%** |
| ៣ | កម្រិតសញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | 0 | 1 | 0 | 0 | 1 | 11.11% |
| | | បរិញ្ញាបត្រ | 2 | 1 | 2 | 0 | 5 | 55.56% |
| | | ចប់ថ្នាក់ទី១២ | 1 | 1 | 0 | 1 | 3 | 33.33% |
| | | **សរុប** | **3** | **3** | **2** | **1** | **9** | **100%** |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ ឆ្នាំ | 0 | 0 | 0 | 0 | 0 | 0.00% |
| | | ៦ ដល់១០ឆ្នាំ | 0 | 0 | 0 | 0 | 0 | 0.00% |
| | | ១១ ដល់ ១៥ ឆ្នាំ | 0 | 0 | 0 | 1 | 1 | 11.11% |
| | | លើសពី១៥ឆ្នាំ | 3 | 3 | 2 | 0 | 8 | 88.89% |
| | | **សរុប** | **3** | **3** | **2** | **1** | **9** | **100%** |

# ឧបសម្ព័ន្ធ "ខ"
# លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ០៤៥ វជអ.

## លិខិតបង្គាប់ការ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត **ហៃ សុខអេង** ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត ឈាង សង្វាត

២-គ្រូដឹកនាំរង

លោក ចាប រតនា

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
**ជ.នាយកវិទ្យាស្ថានជាតិអប់រំ**
**នាយករង**

បណ្ឌិត.នួន_វីរ៉ា

**កន្លែងទទួល៖**
- -ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**លេខ :..១..៥៣..ខជអ.**

**គោរពជូន**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ**

**កម្មវត្ថុ៖** សម្រួលដល់ការចុះប្រមូលទិន្នន័យរបស់និស្សិតឈ្មោះ **ហៃ សុខអេង** នៅតាមអនុវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ។

**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថានិស្សិត **ហៃ សុខអេង** កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ បណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា បានសិក្សាលើប្រធានបទស្តីពី«**ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។ ក្នុងន័យនេះ និស្សិត **ហៃ សុខអេង** មានគម្រោងចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE) ពីលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រង នៅតាមអនុវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ ដែលរួមមាន៖ អនុវិទ្យាល័យទីរួមខេត្ត អនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យគីរីវ័ន្ត និងអនុវិទ្យាល័យព្រៃក្មេង ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :១៥៣ វជអ.

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ
ចូល លេខ 408 អ.ល.ព
ថ្ងៃទី 20 ខែ 07 ឆ្នាំ 2020

គោរពជូន
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ**

**កម្មវត្ថុ៖** សម្រួលដល់ការចុះប្រមូលទិន្នន័យរបស់និស្សិតឈ្មោះ **ហៃ សុខអេង** នៅតាមអនុវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ។

**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថានិស្សិត **ហៃ សុខអេង** កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ បណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា បានសិក្សាលើប្រធានបទស្តីពី **«ឥរិយាបថឆ្លើយតបរបស់គ្រូទៅលើការអនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺ»** ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។ ក្នុងន័យនេះ និស្សិត **ហៃ សុខអេង** មានគម្រោងចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE) ពីលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រង នៅតាមអនុវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ ដែលរួមមាន៖ អនុវិទ្យាល័យទីរួមខេត្ត អនុវិទ្យាល័យឆាយធុប អនុវិទ្យាល័យគិរីវន្ត និងអនុវិទ្យាល័យព្រៃក្មេង ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

បានឃើញ និងឯកភាព
ថ្ងៃទី 20 កក្កដា 2020

ចន_ចាវរិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :..............វជអ.

# លិខិតអញ្ជើញ

**សូមគោរពអញ្ជើញ ៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

*ព័ត៌មានបន្ថែម ៖*

- ✓ *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវធំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- ✓ *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*